៧

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ៤១ ខែ កក្កដា

ព.ស. ២៥១៣ គ.ស. ១៩៦៩

-ភ្នំពេញ-

៧

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បេញរាល់ខែ ពី ពុទ្ធសាសនបណ្ឌិត្យ

អត្ថបទ | ផ្នែកសាសនា | ទំព័រ

១— មជ្ឈិមសីល លោក ប៊ូ-ប៉ូ រៀបរៀង . . . . . . ៦៦៥
២— រឿងឧបគុត្ត និង មារ លោក ញុង-សឿង រៀបរៀង. . . . . ៦៧៣

## ផ្នែកអក្សរសាស្ត្រ

៣— វិបារណកថា . . . . . . . . . ៦៨៣
៤— វចនានុក្រមសំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង ខាត់ . . . . ៦៨៨
៥— រឿងសាមកុក (ត) ឧកញ៉ានូ-កន ប្រែរៀបរៀង . . . . ៦៩១
៦— រឿងគ្រោះថ្នាក់នាវាដោយខ្យល់ព្យុះ សហជីវិនី ពេជ-សល់ ប្រែរៀបរៀង ៦៩៩
៧— ពាក្យកាព្យ : រាត្រីបតុមុខ លោក ញុង-សឿង រៀបរៀង . . ៧១០
៨— ឯកសារ : ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង ឧកញ៉ា
ប្រសើរលិខិតម៉ែន-ទន់ រៀបរៀង . . . . . . ៧១៦
៩— ប្រវត្តិភូមិក្បាលអ្នក ឬ ភូមិ ប៉ូអង់ លោក ហ៊ុន-សារីរៀបរៀង . . ៧៤៧
១០— ល្បើកអក សហ. លី-ធាមតេង ស្រាវជ្រាវ . . . . ៧៣៤
១១— សិលាចារឹកព្រះគោ សហ. ឌិក-ធាម ស្រាវជ្រាវ . . . . ៧៥១

## ផ្នែកកំណត់-ប្រវត្តិការណ៍

១២— សេចក្ដីជូនដំណឹង អំពីលទ្ធផលនៃការប្រឡងប្រជែងខាងទំនៀមទម្លាប់
នៅខែមាសទី១ ឆ្នាំ ១៩៦៩ . . . . . . ៧៨៤

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០រ០០ ។

## ផ្នែកសាសនា

| | |
|---|---|
| ពាក្យឃាត់មិនឲ្យ | ធ្វើការអាក្រក់ |
| ជាការណាមក | ឲ្យធ្វើល្អទៅ, |
| ឲ្យដុសខាត់ចិត្ត | កុំឲ្យហ្មងសៅ |
| បីនេះលោកហៅ | ពុទ្ធសាសនា ។ |

ប. ព

# មជ្ឈិមសីល (១)

លោក ញ៉ូ-ញ៉ូ រៀបរៀង

មួយវិញទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយ ៗ នូវការធ្វើនូវពីជគាម និងភូតគាមឲ្យវិនាសមានសភាពដូច្នេះ ។ ពីជគាមនិងភូតគាមនោះ តើដូចម្ដេចខ្លះ ។ គឺ មើមឬឫសជាពូជ ១ ដើមជាពូជ ១ ថ្នាំងជាពូជ ១ ចុងឬត្រួយជាពូជ១ គ្រាប់ជាពូជ១ ជាគម្រប់៥ ។ ភិក្ខុវៀរចាកនូវការធ្វើនូវពីជគាមនិងភូតគាមឲ្យវិនាស មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេយកឲ្យដោយសទ្ធាហើយ តែសម-ណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយ ៗ នូវការបរិភោគវត្ថុដែលសន្សំ

១- ចម្លងត្រង់តាមច្បាប់ដើម ពីព្រះត្រៃបិដក ប្រែ ឥតកែប្រែ ឬ បញ្ចេញបញ្ចូលឡើយ ។

ទុក មានសភាពដូច្នេះ ៗ ការសន្សំទុកនោះ តើដូចម្តេច ៗ គឺសន្សំបាយទុក ១ សន្សំទឹកទុក១ សន្សំសំពត់ទុក ១ សន្សំយានទុក ១ សន្សំទីដេកទុក ១ សន្សំគ្រឿងក្រអូបទុក ១ សន្សំគ្រឿងអាមិសទុក ១ ភិក្ខុជាអ្នកវៀរចាកការបរិភោគវត្ថុ ដែលសន្សំទុក មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេឲ្យដោយសទ្ធាហើយ តែសម-ណព្រាហ្មណ៍ទាំងនោះរមែងប្រកបរឿយៗ នូវការមើលនិងស្តាប់នូវល្បែង ដែលជាសត្រូវដល់កុសលធម៌មានសភាពដូច្នេះ ៗ ល្បែងជាសត្រូវដល់កុសលធម៌នោះ តើដូចម្តេច ៗ គឺ ល្បែងរាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ មហោស្រពខ្លះ ចម្រៀងមហាភារតៈនិងរាមកេរ្តិ៍ជាដើមខ្លះ គងខ្លះ រគាំងខ្លះ ស្គរមានជ្រុងបួនខ្លះ គួរគំនូររូបរបាំខ្លះ ល្បែងដុំដែកខ្លះ ល្បែងប៉ាវខ្លះ ល្បែងលាងឆ្អឹងខ្លះ ដំរីដល់គ្នាខ្លះ សេះប្រទាំគ្នាខ្លះ ក្របីជល់គ្នាខ្លះ គោជល់គ្នាខ្លះ ពពែជល់គ្នាខ្លះ កែះជល់គ្នាខ្លះ មាន់ជល់គ្នាខ្លះ ចាបជល់គ្នាខ្លះ ល្បែងគុនដំបងខ្លះ ប្រដាល់ខ្លះ ចម្បាប់ខ្លះ ចម្បាំងខ្លះ ទីគេកប់ពលខ្លះ ទីលំនៅគណទ័ពខ្លះ ទីមើលពួកសេនាដែលប្រកបដោយអង្គ ៤ ខ្លះ ៗ ភិក្ខុជាអ្នកវៀរចាកការមើលនិងស្តាប់នូវល្បែង ដែលជាសត្រូវដល់កុសល-ធម៌ មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយៗ នូវល្បែងបាស្កា ដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទមានសភាពដូច្នេះ ។ ល្បែងបាស្កានោះតើដូចម្ដេចខ្លះ ។ គឺ បាស្កាមានក្រឡាប្រាំបី(១)ខ្លះ បាស្កាមានក្រឡាដប់(២)ខ្លះ បាស្កាដែលលេងឰដ៏អាកាស(៣)ខ្លះ ល្បែងវាងផ្លូវដែលគូរវាង(៤)ខ្លះ ល្បែងផ្ទាត់គ្រាប់មានគ្រាប់ក្រួសជាដើមខ្លះ លេងបាស្កាក្នុងទីលានសម្រាប់លេងខ្លះ ល្បែងហ៊ឹងឬកូនគោលខ្លះ ល្បែងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ ល្បែងអង្គុញខ្លះ ល្បែងផ្លុំប៉ីស្លឹកខ្លះ ល្បែងនង្គ័លតូចខ្លះ ល្បែងដាំដូងខ្លះ ល្បែងកង្ហារខ្លះ ល្បែងវាល់ដីទ្រាប់ (បាយឡុកបាយឡ)ខ្លះ ល្បែងរថតូចខ្លះ ល្បែងធ្នូតូចខ្លះ ល្បែងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ ល្បែងទាយចិត្ត (ស្ដេចចន្ទ)ខ្លះ ល្បែងកំប្លែងត្រាប់គេខ្លះ ។ ឯភិក្ខុជាអ្នកវៀរចាកល្បែងបាស្កាដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ មានសភាពដូច្នេះឯង ។ នេះ ជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវឧច្ចាសយនមហាសយនៈ

---

១- បត្រង្គមានក្រឡា ៨ ។ ២ បត្រង្គមានក្រឡា ១០ ន័យខ្លះថាបាយខ្ញុំ ។ ៣ បត្រង្គឥតក្ដារ លេងតែមាត់ទទេ ។ ៤ ប្រហែលជាលេងបិទមុខបិទពួន ។

(ទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើ) មានសភាពដូច្នេះ ៗ ឧច្ចាសយនមហាសយនៈនោះ តើដូចម្តេចខ្លះ ៗ គឺអាសនៈដែលខ្ពស់ហួសប្រមាណខ្លះ គ្រែដែលមានជើងវិចិត្តដោយរូបសត្វសាហាវខ្លះ ព្រំដែលមានរោមវែងជាង ៤ ធ្នាប់ខ្លះ កម្រាលដែលធ្វើដោយរោម វិចិត្រដោយរូបសត្វសាហាវខ្លះ កម្រាលមានពណ៌សដែលធ្វើដោយរោមសត្វខ្លះ កម្រាលដែលធ្វើដោយរោមសត្វ មានផ្កាដេរដាសខ្លះ កម្រាលដែលញាត់ដោយសំឡីជាប្រក្រតីខ្លះ កម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវមានសីហៈនិងខ្លាធំជាដើមខ្លះ កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងឡើងតែម្ខាងខ្លះ កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងឡើងទាំងសងខាងខ្លះ កម្រាលដែលធ្វើដោយឱិទខ្សែសយមាស និងសូត្របាក់ស្រែះដោយរតនវត្ថុមានមាសជាដើមខ្លះ កម្រាលដែលធ្វើដោយសរសៃសូត្រ បាក់ស្រែះដោយរតនវត្ថុខ្លះ កម្រាលដែលធ្វើដោយរោមសត្វល្មមចុះពួកស្រីរបាំ ១៦ នាក់ឈររាំបានខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងដំរីខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងសេះខ្លះ កម្រាលសម្រាប់ក្រាលលើរថខ្លះ កម្រាលដែលធ្វើដោយស្បែកខ្លាខ្លះ កម្រាលដ៏ឧត្តមដែលធ្វើដោយស្បែកសត្វឈ្មុសខ្លះ ខ្នើយមានពណ៌ក្រហមទាំង ២ ខាង គឺខ្នើយក្បាលនិងខ្នើយជើង ព្រមទាំងពិតានមានពណ៌ក្រហមខ្លះ ៗ ភិក្ខុជាអ្នកវៀរចាកឧច្ចាសយនមហាសយនៈ មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណៈព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកងកាយ មានសភាពដូច្នេះ ។ វត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកងកាយនោះ តើដូចម្តេចខ្លះ ។ គឺ ការដុសខាត់បំបាត់ក្លិនអាក្រក់ (គ្រឿងអប់)ខ្លះ ការច្របាច់រឹតខ្លះ ការផ្ងូតទឹកខ្លះ ការគក់ច្របាច់ខ្លះ កញ្ចក់ខ្លះ វត្ថុសម្រាប់លាបគ្រឿងប្រដាប់ខ្លះ ផ្កាកម្រងនិងគ្រឿងក្រអូបនិងគ្រឿងលាបខ្លះ គ្រឿងលម្អិតសម្រាប់ប្រស់មុខខ្លះ វត្ថុសម្រាប់លាបមុខខ្លះ គ្រឿងប្រដាប់ដៃខ្លះ ចំណងផ្នួងសក់ខ្លះ ដំបងខ្លះ បំពង់ថ្នាំខ្លះ ដាវខ្លះ ព្រះខាន់ខ្លះ ឆត្រខ្លះ ស្បែកជើងវិចិត្រខ្លះ មកុដប្តូក្បាំងមុខខ្លះ (ស្នៀតសក់) កែវមណីខ្លះ ផ្លិតធ្វើដោយរោមកន្ទុយសត្វខ្លះ សំពត់សខ្លះ សំពត់មានជាយវែងខ្លះ ។ ភិក្ខុ ជាអ្នកវៀរចាកការប្រកបរឿយៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកងកាយ មានសភាពដូច្នេះឯង ។ នេះ ជាសីលរបស់ភិក្ខុនោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗ នូវតិរច្ឆានកថា (ពាក្យនិយាយទទឹងផ្លូវសួគ៌ និងផ្លូវព្រះនិព្វាន) មានសភាពដូច្នេះ ។ តិរច្ឆានកថានោះតើដូចម្តេចខ្លះ ។ គឺ និយាយអំពីស្តេចខ្លះ និយាយអំពីចោរខ្លះ និយាយ

អំពីអាមាត្យធំខ្លះ និយាយអំពីសេនាពាហនខ្លះ និយាយអំពីភ័យខ្លះ និយាយអំពីចម្បាំងខ្លះ និយាយអំពីបាយម្ហូបចំណីខ្លះ និយាយអំពីទឹកផឹកខ្លះ និយាយអំពីសំពត់ខ្លះ និយាយអំពីទីដេកខ្លះ និយាយអំពីផ្កាកម្រងខ្លះ និយាយអំពីគ្រឿងក្រអូបខ្លះ និយាយអំពីញាតិខ្លះ និយាយអំពីយានខ្លះ និយាយអំពីស្រុកខ្លះ និយាយអំពីនិគមខ្លះ និយាយអំពីនគរខ្លះ និយាយអំពីជនបទខ្លះ និយាយអំពីស្ត្រីខ្លះ និយាយអំពីបុរសខ្លះ និយាយអំពីយោធាដែលក្លៀវក្លាខ្លះ និយាយអំពីច្រកផ្លូវខ្លះ និយាយអំពីកំពង់ទឹកខ្លះ និយាយអំពីញាតិ (ដែលចាកឋានទៅកាន់បរលោកហើយ) ខ្លះ និយាយអំពីពាក្យឥតប្រយោជន៍មានសភាពផ្សេង ៗ ខ្លះ និយាយអំពីលោកខ្លះ និយាយអំពីសមុទ្រខ្លះ និយាយអំពីសេចក្តីចម្រើន និងមិនចម្រើនខ្លះ ៗ ភិក្ខុជាអ្នកវៀរចាកតិរច្ឆានកថា មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវពាក្យប្រណាំងប្រដែងមានសភាពដូច្នេះ ៗ ពាក្យប្រណាំងប្រដែងនោះ តើដូចម្តេចខ្លះ ៗ គឺ ពាក្យថា អ្នកមិនមែនចេះដឹងនូវធម៌និងវិន័យនេះទេ ខ្ញុំទើបដឹងនូវធម៌និងវិន័យនេះ, អ្នកនឹងបានឈ្មោះថាចេះដឹងនូវធម៌និងវិន័យនេះ ដូចម្តេចបាន អ្នកជាអ្នកប្រតិបត្តិខុស ខ្ញុំទើបជាអ្នកប្រតិបត្តិត្រូវល្អ, ពាក្យរបស់ខ្ញុំ ទើប

ប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ទេ សម្តីដែលគេត្រូវនិយាយមុន អ្នកត្រឡប់ជានិយាយក្រោយវិញ សម្តីដែលគេត្រូវនិយាយក្រោយ អ្នកត្រឡប់ជានិយាយមុនវិញ ពាក្យផ្ទុយអ្នកប្រព្រឹត្តមកជាយូរអង្វែងហើយ ទោសគឺសម្តីរបស់អ្នក ខ្ញុំបានលើកឡើងហើយ អ្នកជាមនុស្សត្រូវខ្ញុំសង្កត់សង្កិនបាន អ្នកចូរទៅសិក្សា ដើម្បីដោះស្រាយនូវទោសគឺសម្តី ឬបើអ្នកអាច ចូរអ្នកដោះស្រាយឲ្យរួចទោសចុះ ៗ ភិក្ខុជាអ្នកវៀរចាកពាក្យប្រណាំងប្រជែង មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុនោះដែរ ៗ

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយៗនូវទូតកម្ម គឺការនាំសំបុត្រឬពាក្យបណ្តាំដល់គ្រហស្ថ និងទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ មានសភាពដូច្នេះ ៗ ទូតកម្មជាដើមនោះ តើដូចម្តេចខ្លះ ៗ គឺ ពាក្យដែលស្តេច មហាមាត្យរបស់ស្តេច ក្សត្រ ព្រាហ្មណ៍ គហបតិ ឬកុមារក្តី បញ្ជូនទៅថា លោកចូរទៅកន្ទីនេះដូច្នេះក្តី លោកចូរទៅកន្ទីឯណោះ ដូច្នេះក្តី លោកចូរនាំយករបស់នេះទៅ ដូច្នេះក្តី លោកចូរនាំយករបស់នេះមកអំពីទីឯណោះ ដូច្នេះក្តី ៗ ភិក្ខុជាអ្នកវៀរចាកការប្រកបរឿយៗ នូវទូត-កម្ម គឺការនាំសំបុត្រឬពាក្យបណ្តាំដល់គ្រហស្ថ និងទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ មានសភាពដូច្នេះឯង ៗ នេះ ជាសីលរបស់ភិក្ខុ

នោះដែរ ។

ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចម្រើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ជាអ្នកកុហកគឺញ៉ាំងសត្វលោកឲ្យកោត ឲ្យស្ងើច (ឲ្យជ្រះថ្លាដោយការប្រើប្រាស់បច្ច័យជាដើម) ខ្លះ ជាអ្នកនិយាយរាក់ទាក់ (នឹងគ្រហស្ថ) ខ្លះ ជាអ្នកធ្វើនិមិត្តគឺពោលបញ្ចិតបញ្ចៀងខ្លះ ជាអ្នកជេរប្រទេចខ្លះ ជាអ្នកស្វែងរកនូវលាភដោយលាភខ្លះ ។ ភិក្ខុជាអ្នកវៀរចាកការកុហក និងការនិយាយរាក់ទាក់មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះនោះដែរ ។

ចប់ មជ្ឈិមសីល ។

# រឿង ឧបគុត្ត និង មារ

សហ. ញ៉ុង-សឿង រៀបរៀង

ពុទ្ធសាសនាកន្លងទៅបាន ២១៨ ឆ្នាំ ព្រះបាទធម្មាសោក[1] ប្រារព្ធធ្វើបុណ្យឆ្លងព្រះវិហារ ៨ ម៉ឺន ៤ ពាន់ និងចេតិយ ៨ ម៉ឺន ៤ ពាន់ អស់រយៈកាល ៧ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ មុននឹងផ្ដើមធ្វើបុណ្យនេះ ទ្រង់មានព្រះចិន្ដាថា «អញធ្វើបុណ្យនេះធំហើយយូរផង គួរតែអញចូលទៅថ្វាយបង្គំព្រះសង្ឃសិន ដើម្បីឲ្យព្រះសង្ឃទាំងនោះជួយការពារឧបស័គ្គផ្សេង ៗ ដែលកើតឡើងដល់ការកុសលនេះ» ។ លុះទ្រង់ព្រះចិន្ដាហើយ ក៏ចូលទៅកាន់អារាមថ្វាយបង្គំព្រះសង្ឃ ទូលអំពីរាជបំណងសព្វគ្រប់ប្រការហើយត្រឡប់មកកាន់ព្រះបរមរាជវាំងវិញ ។

លំដាប់នោះ ភិក្ខុសង្ឃសន្និបាត រំពឹងគិតពិចារណាក៏បានដឹងច្បាស់ថា «ក្នុងពេលដែលស្ដេចប្រារព្ធធ្វើបុណ្យនេះ មារាធិរាជ នឹងមកធ្វើអុកឡុកឲ្យអន្ដរាយការកុសលនេះ ។ សង្ឃសន្និបាត ក៏ទូលដល់ព្រះសង្ឃត្ថេរ[2] ថា «បពិត្រព្រះថេរៈដ៏ចម្រើន លោកម្ចាស់អាចការពារនូវមារាធិរាជកុំឲ្យធ្វើអន្ដរាយដល់ការកុសលនេះបានឬទេ?» ។ ព្រះថេរៈថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមានកិច្ចធុរៈច្រើន ទាំងកាយទៀតសោត ក៏ទុព្វលភាព

---

១ សៀវភៅ រឿងឧបគុត្ត និងមារ នៅពុទ្ធសាសនបណ្ឌិត្យលេខ ម-១៣-៦៨ ដែលលោក Paroiselle សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ នៃប្រទេសកម្ពុជាធ្វើជាភាសាបារាំង ដាក់ថា «ព្រះបាទអសោក» ។ ២- ព្រះសង្ឃត្ថេរក្នុងវេលានោះ [illegible] ។

ណាស់ហើយ មិនអាចនឹងការពារនូវមាពធិកជបានទេ ។ សង្ឃសន្និបាត ក៏សួរអនុក្រមតាមលំដាប់រហូតដល់ភិក្ខុ ទើបនឹងបួសថ្មី តែគ្មានភិក្ខុអង្គណាមួយអាចការពារបានឡើយ ។

ព្រឹកឡើងនៃថ្ងៃទី ២ សង្ឃសន្និបាត ក៏ប្រជុំដើម្បីពិភាក្សាជ្រើសរើសរកភិក្ខុដែលអាចការពារនូវមាពធិកជទៀត ។ ខណៈនោះ មាននាគរាជមួយ ឡើងមកពីពិភពនាគ ដើម្បីធ្វើនមស្ការចំពោះភិក្ខុសង្ឃ ។ ពេលនោះមានស្ដេចគ្រុឌមួយ ហើរមកពីកណ្ដាលចក្រវាឡ មើលមកឃើញនាគ ក៏សម្ទុះស្ទាបចុះមកចម្រុងចាប់ស្ដេចនាគ ធ្វើជាភក្សាហារ ។

ស្ដេចនាគឃើញ ក៏តក់ភ័យយ៉ាងខ្លាំង រត់ចូលទៅក្នុងទីសង្ឃសន្និបាត សូមឲ្យសង្ឃសន្និបាតជួយ ។ សង្ឃសន្និបាតប្រាប់ថា យើងមិនអាចជួយការពារមហាភពជបានទេ ។ គ្រានោះមានសាមណេរ(១)មួយរូបមានជន្មវស្សា ១៧ ឆ្នាំ ទើបតែនិមន្តមកដល់ ។ ព្រះសង្ឃទាំងអស់ ក៏និយាយទៅកាន់សាមណេរថា "ម្នាលសាមណេរ អ្នកអាចការពារនូវភ័យរបស់ស្ដេចនាគបានឬទេ?" ។ សាមណេរបង្គំទូលថា "បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណា ជាសាមណេរនៅក្មេងណាស់ មិនអាចការពារបានទេ" ។ ពេលនោះ ព្រះសង្ឃសន្និបាតអង្វរករសាមណេរនោះជាច្រើនលើកច្រើនគ្រា រហូតដល់សាមណេរទទួលការពារនូវភ័យនៃស្ដេចនាគនោះ ។

ក្នុងពេលដែលស្ដេចគ្រុឌហោះពួយចុះមកចម្រុងចាប់នាគធ្វើជាភក្សា-

១- មិនឃើញមានប្រាប់នាមសាមណេរនោះទេ ។

ហារនោះ សាមណេរក៏ចូលឈានសមាបត្តិសម្ដែងបាដិហារិយ៍ធ្វើឲ្យខ្យល់ព្យុះយ៉ាងខ្លាំង ក្ដួចយកស្ដេចគ្រុឌទៅដាក់ទួលកំពែងចក្រវាឡ ។ ស្ដេចនាគរួចជីវិតដោយសារសាមណេរនោះ សរសើរនូវគុណូបការៈនៃសាមណេរជាអនេកប្បការ ហើយថ្វាយបង្គំលាភិក្ខុសង្ឃនិងសាមណេរនោះទៅកាន់ពិភពនាគវិញ ។

ភិក្ខុសង្ឃទាំងនោះ លើកទោសសាមណេរនោះថា "នៃសាមណេរអ្នកឯង កាលភិក្ខុសង្ឃនិយាយពីដំបូង អ្នកឯងមិនព្រមធ្វើតាមបង្គាប់ព្រះសង្ឃ លុះព្រះសង្ឃអង្វរជាច្រើនលើកច្រើនគ្រា ទើបអ្នកឯងទទួលធ្វើ ។ អ្នកធ្វើដូច្នេះ ជាការមិនគួរ គឺអ្នកមិនគោរពដល់សង្ឃសោះ សង្ឃនឹងដាក់ទណ្ឌកម្មដល់អ្នកឯង" ។ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណានេះប្រព្រឹត្តខុសហើយ ព្រះសង្ឃនឹងដាក់ទណ្ឌកម្មដល់ខ្ញុំយ៉ាងណា ខ្ញុំនឹងទទួលនូវទណ្ឌកម្មយ៉ាងនោះគ្រប់ទាំងអស់ ។ ព្រះសង្ឃថា "នៃសាមណេរព្រះធម្មាសោក ជាពុទ្ធសាសនូបត្ថម្ភក៏ព្រះអង្គនឹងធ្វើបុណ្យឆ្លងចេតិយ អស់រយៈកាល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ អ្នកឯងត្រូវទៅការពារមាពធិពជ កុំឲ្យមកធ្វើអន្តរាយដល់បុណ្យនោះ ។ សាមណេរឆ្លើយថា "បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណានេះ ជាសាមណេរនៅក្មេងមានអានុភាពតិចណាស់ មិនអាចការពារបានទេ លោកដែលមានអានុភាពច្រើនអាចទូន្មានមាពធិពជនោះបាននៅមាន ហេតុអ្វី ក៏ព្រះសង្ឃមិនទៅនិមន្តលោកអង្គនោះមក" ។ ព្រះសង្ឃក៏សួរថា លោកដែលមានអានុភាពច្រើននោះ មាននាមដូចម្ដេច

លោកគង់នៅទីណា? ។ លោកមាននាមថា តិស្សនាគឧបគត លោកនិម្មិតប្រាសាទកែវនៅក្នុងផ្ទៃនៃមហាសមុទ្រ ហើយគង់សម្រាកឥរិយាបថក្នុងទីនោះ ។ កាលឮពាក្យសាមណេរប្រាប់ភ្លាម ព្រះសង្ឃទាំងឡាយ មានចិត្តប្រាមោទ្យត្រេកអរពន់ពេក ហើយ មានថេរបញ្ជាប្រើភិក្ខុ[១]ពីររូប ដែលសុទ្ធតែបានអភិញ្ញា ឲ្យទៅអារាធនាតិស្សនាគឧបគត ។ ភិក្ខុពីររូប កាលទទួលសង្ឃបញ្ជាហើយ ក៏ជ្រែកមហាប្រឹថពីទៅផុសនៅប្រាសាទនៃព្រះថេរៈតិស្សនាគ ឧបគត ។

តិស្សនាគឧបគត កាលទទួលអារាធនាហើយ ក៏ឲ្យភិក្ខុទាំងពីររូបនោះត្រឡប់ទៅមុន ។ កាលភិក្ខុទាំងពីររូបចេញផុតទៅ តិស្សនាគឧបគតក៏សម្ដែងឥទ្ធិបាដិហារិយ៍ ហោះទៅដល់ទីសង្ឃសន្និបាត មុនភិក្ខុទាំងពីររូបនោះ ។ ដោយអស្ចារ្យពេក ភិក្ខុពីររូបនោះ ក៏ពោលអួតគុណវិសេសរបស់តិស្សនាគឧបគតប្រាប់ដល់សង្ឃសន្និបាតថា៖ ព្រះថេរៈនេះប្រាកដជាមានអានុភាពច្រើនមែន ។

កាលមកដល់ហើយ ថ្វាយបង្គំសង្ឃត្ថេរហើយសួរថា ព្រះសង្ឃមានការអ្វី? ប្រធាននៃសង្ឃសន្និបាត និយាយថា ម្នាលអាវុសោ ឧបគត អ្នកឯងជាអត្តទត្តបុគ្គល មិនមករួមធ្វើឧបោសថជាមួយនឹងសង្ឃ មិនគោរពសង្ឃ ។ នឹងដាក់ទណ្ឌកម្មដល់អ្នក ។ ឧបគតឆ្លើយថា៖ តោះបើព្រះសង្ឃដាក់ទណ្ឌកម្មដល់ខ្ញុំព្រះករុណាដូចម្ដេច ខ្ញុំព្រះករុណានឹងធ្វើតាមដូច្នោះ។

---

១- ភិក្ខុពីររូបនេះ មិនឃើញមានប្រាប់នាមទេ ។

ព្រះសង្ឃត្ថេរពោលថា ម្នាលអាវុសោឧបគុត្ត ក្នុងពេលឆាប់ៗនេះ ព្រះបាទធម្មាសោកជាសាសនូបត្ថម្ភក៍ ស្ដេចបម្រុងធ្វើបុណ្យធ្លងចេតិយ ៨ ម៉ឺន ៤ ពាន់ និងព្រះស្តូបធំក្នុងព្រះនគរ ។ អ្នកឯងត្រូវការពារមារពិកជ កុំឲ្យមកធ្វើអន្តរាយដល់ការកុសលរបស់ព្រះមហាក្សត្រ នេះជាទណ្ឌកម្មដែលសង្ឃដាក់ដល់អ្នកឯង ។

ក្នុងពេលដែលសង្ឃសន្និបាត មិនទាន់បញ្ចប់ផង ព្រះមហាក្សត្រស្ដេចយាងចូលទៅកាន់អារាមថ្វាយបង្គំព្រះសង្ឃ រួចទ្រង់ត្រាស់សួរថា "បពិត្រព្រះសង្ឃដ៏ចម្រើន ភិក្ខុដែលអាចការពារនូវមារពិកជៈនោះ តើព្រះសង្ឃជ្រើសរើសបានហើយឬនៅ" ? ។ ប្រធានសង្ឃនៃសន្និបាតថ្វាយព្រះពរថា "បពិត្រមហារាជ ភិក្ខុដែលអាចនឹងការពារនូវមារពិកជនោះបានហើយគឺភិក្ខុឈ្មោះតិស្សនាគឧបគុត្តនេះឯង" ។ ព្រះសង្ឃបន្ថែមប្រាប់ ។ ភិក្ខុអង្គនេះលោកប្រកបដោយសីល សមាធិ បញ្ញា មានអានុភាពច្រើន ។

ព្រះរាជា ស្ដេចទ្រង់ចូលទៅថ្វាយបង្គំតិស្សនាគឧបគុត្ត ទ្រង់ទតឃើញកាយស្គាំងស្គម ទ្រង់គិតក្នុងព្រះរាជហឫទ័យថា "ភិក្ខុនេះមានកាយស្គាំងស្គមណាស់ ហេតុអ្វីក៏ព្រះសង្ឃប្រាប់អញថា អាចការពារនឹងមារបាន បើដូច្នេះ អញនឹងល្បងមើល ឲ្យដឹងថាមានឫទ្ធិឬឥតឫទ្ធិ ព្រោះជានឹងមិនសមចក្ខុនៃអាត្មាអញសិន" ។

ថ្ងៃព្រឹកឡើងតិស្សនាគឧបគុត្ត ចូលទៅបិណ្ឌបាតក្នុងព្រះបរមរាជវាំង ព្រះរាជាទ្រង់ឧបត្ថម្ភចង្ហាន់ បិណ្ឌបាតយ៉ាងប្រណីត ។ កាលបានចង្ហាន់

បិណ្ឌបាតហើយ ក៏ត្រឡប់ទៅអាកមវិញ ។ ក្នុងពេលដែលលោកត្រឡប់មកវិញនោះ ព្រះពជាទ្រង់បញ្ជាឲ្យហ្មដំរី លែងដំរីចុះប្រេងកាចសាហាវ ដេញព្រេច ។ តិស្សនាគឧបគតក្រឡេកឃើញដំរីក៏ដឹងថា ព្រះពជាទ្រង់ល្បងរិទ្ធិ ហើយចូលឈានសមាបត្តិ អធិដ្ឋានឲ្យដំរីនោះក្លាយទៅជាថ្មឈរនៅនឹងថ្កល់ ។ ព្រះពជាទ្រង់យាងតាមក្រោយ ដើម្បីលបមើល កាលឃើញដំរីក្លាយទៅជាថ្ម ក៏ដឹងថាព្រះថេរៈអង្គនេះប្រាកដជាមានឫទ្ធិមែន ទ្រង់ស្ងើចសរសើរព្រះថេរៈយ៉ាងក្រៃលែង ហើយចូលទៅថ្វាយបង្គំសូមព្រះថេរៈអត់ទោសឲ្យ ។ ព្រះថេរៈអត់ទោស ហើយធ្វើដំរីនោះឲ្យក្លាយទៅដូចប្រក្រតីដើមវិញ ។

ព្រះពជានិងមហាជនានុជនក្នុងព្រះនគរ ជ្រះថ្លាស្ងើចសរសើរបារមីព្រះថេរៈគ្រប់ ១ គ្នា ។

ចាប់តាំងពីថ្ងៃនោះមក ព្រះពជាក៏ចាប់ផ្តើមពិធីបុណ្យឡើង មានអុជប្រទីបផ្កាលាក្លៃព្រោងព្រាតគ្រប់ព្រះស្តូបទាំងអស់ ។ ព្រះសង្ឃនិងមហាជនដែលជាពុទ្ធសាសនិក មកចូលរួមរួមក្នុងពិធីបុណ្យនោះយ៉ាងកុះករ ។

ពេលនោះ មារពធិរាជ មានចិត្តបាប បង្កើតជាខ្យល់ព្យុះនិងភ្លៀងយ៉ាងខ្លាំង ដើម្បីធ្វើភ្លើងដែលអុជទាំងនោះឲ្យរលត់ ។ តិស្សនាគឧបគតក៏ចូលឈានសម្តែងរិទ្ធិឃួបយកខ្យល់និងភ្លៀងនោះ ទៅពោលក្រៅកណ្តាប់ចក្រវាឡ ។ មារពធិរាជ ក៏បណ្តាលជាភ្លៀងគ្រាប់គ្រួស ភ្លៀងដុំថ្ម ភ្លៀង

រងើកភ្លើង និងភ្លៀងអាវុធផ្សេង ៗ ឲ្យធ្លាក់ចុះមកទៀត ព្រះថេរៈនេះ ក៏សម្តែងឫទ្ធិកួចយកភ្លៀងទាំងនោះ ចោលទៅក្រៅចក្រវាឡទៀត ។ មារា-ធិរាជបណ្តាលឲ្យងងឹតគ្រប់ទិសសានុទិស ។ ព្រះថេរៈ ធ្វើឲ្យងងឹតនោះអន្តរធានទៀត ។ មារាធិរាជ ក្រេវក្រោធយ៉ាងខ្លាំងនិម្មិតជាគោយ៉ាងធំ ប្រាលទៅបម្រុងនឹងបុកពិធីនោះឲ្យវិនាសសូន្យសុង ។ ព្រះថេរៈនិម្មិតជាខ្លាដេញខាំគោនោះ គោភិតភ័យស្រែកទូវសម្រែកយ៉ាងខ្លាំង ហើយក្លាយខ្លួនទៅជាស្តេចនាគមានក្បាល ៧ ខ្លាធំក្លាយទៅជាស្តេចគ្រុឌចាប់ក្បាលនាគរូសចេញ , នាគក្លាយខ្លួនទៅជាស្តេចយក្សយ៉ាងធំ កាន់ដំបងទង់ដែងប៉ុនដើមត្នោត គ្រវីគ្រវាសបួលមកបម្រុងប្រហារស្តេចគ្រុឌ ។ ស្តេចគ្រុឌក្លាយខ្លួនទៅជាស្តេចយក្ស ធំលើសនោះ ២ ដង ដៃទាំងពីរកាន់ដំបងយ៉ាងធំ ហើយចេញជាអណ្តាតភ្លើងដេញវាយយក្សមារនោះរហូតដល់បរាជ័យ ។

មារតូចចិត្តណាស់គិតថា អញនិម្មិតខ្លួនទៅជារូបផ្សេង ៗ សមណៈនេះធ្វើបានគ្រប់ទាំងអស់ ហើយមានអានុភាពជាងអញដរាប អាត្មាអញឃើញថានឹងចាញ់សមណៈនេះប្រាកដ ។ កាលគិតដូច្នេះហើយក៏សម្តែងឫទ្ធិឈរនៅចំពោះមុខព្រះថេរៈ ព្រះថេរៈឃើញមារហើយគិតថាអញនឹងធ្វើនូវមារនេះឲ្យអស់ឫទ្ធិ អស់គំនិត មិនអាចនឹងកែខៃតទៅទៀតបាន លុះគិតហើយ ក៏និម្មិតជាខ្មោចស្អុយមានក្លិនអសោចគួរខ្ពើមរអើមក្រៃពេក យកទៅចងកមារាធិរាជ ហើយអធិដ្ឋានថា មនុស្សក្តី ទេវតាក្តី ឥន្ទព្រហ្មក្តី មិនអាចដោះស្រាយនូវចំណងនេះបានឡើយ ។ មារាធិរាជកាល

ត្រូវចំណងដ៏អសោចជាប់នឹងកហើយ អស់រិទ្ធិ អស់តេជះ អស់គំនិត បញ្ញាបារមីរលីងពីខ្លួន នឹងស្រាយចំណង អសោចនោះមិនរួច ក៏ទៅកាន់សំណាក់ចតុលោកបាលទាំង ៤ អង្វរករឲ្យជួយដោះឆ្កែស្អុយចេញពីក ។ ចតុលោកបាលប្រាប់ថា យើងមិនអាចនឹងស្រាយរួចទេ ។ មារទៅកាន់សំណាក់សក្កទេវរាជ រហូតដល់ព្រហ្មលោក ជាទីបំផុត ។ ទេវតាមានសក្កទេវរាជជាដើម មានព្រហ្មជាទីបំផុត ប្រាប់ថាយើងមិនអាចស្រាយចំណងសម្អុយនេះចេញបានទេ ព្រោះតិស្សនាគឧបគត លោកជាព្រះអរហន្តជាសាវ័ករបស់ព្រះមានភាគ តែលោកចងហើយ មនុស្សក្តីទេវតាក្តី ព្រហ្មក្តី មិនអាចស្រាយបានឡើយ ។ ដូច្នេះ អ្នកឯងត្រូវចូលខ្លួនទៅកាន់សំណាក់លោក សុំទោសលោក ។ នឹងស្រាយវិញមិនខាន ។ មារាធិរាជ អស់ទីពឹងហើយ ក៏ត្រឡប់ទៅកាន់សំណាក់ព្រះថេរៈ ថ្វាយបង្គំទាំងអៀនខ្មាស អង្វរសុំទោសព្រះថេរៈ ។ ព្រះថេរៈឮពាក្យអង្វររបស់មារហើយ មានថេរៈវាចាថា នែមារអ្នកឯងចូរទៅកាន់ភ្នំធំឯណោះ ។

មារាធិរាជ ទៅតាមបង្គាប់ព្រះថេរៈ ។ ស្រាយសម្អុយឆ្កែនោះចេញពីក ហើយយកវត្តពន្ធចង្កេះចងកមារភ្ជាប់នឹងភ្នំ ហើយប្រាប់ថាអ្នកឯងត្រូវនៅទីនេះ ឲ្យអស់រយៈកាល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ ព្រះថេរៈនិមន្តមកកន្លែងពិធីបុណ្យវិញ ។ ពិធីបុណ្យនោះ បានប្រព្រឹត្តទៅយ៉ាងអធិកអធមសុខស្រួលរហូតដល់ចប់ ។

នៅពេលពិធីបុណ្យចប់សព្វគ្រប់ហើយ ព្រះថេរៈនិមន្តទៅកាន់ភ្នំ

ដែលបង់មារនោះ តែលាក់ខ្លួន មិនឲ្យមារឃើញប្រុងស្តាប់មារនិយាយ
ពីអ្វី ៗ ពេលនោះមារនិយាយថា ពីដើមអញបានធ្វើអំពើអាក្រក់ជាច្រើន
ចំពោះព្រះសម្មាសម្ពុទ្ធ តែព្រះអង្គមិនប្រទូស្តតបវិញសោះ មានតែព្រះទ័យ
ប្រកបដោយមេត្តានិងខន្តី ឥឡូវនេះសាវ័ករបស់ព្រះអង្គ បែរជាមានចិត្ត
ឃោរឃៅបានធ្វើទណ្ឌកម្មដល់អញយ៉ាងខ្លាំង ៗ

ព្រះថេរៈ គ្រាន់តែឮពាក្យនេះភ្លាម ក៏បង្ហាញខ្លួនហើយស្រាយចំណងនោះចេញប្រាប់ថា ៖ នែមារ យើងធ្វើនេះ ដើម្បីជាកុសលរបស់អ្នក និងជៀរបង់នូវឧបសគ្គគ្រប់បែបយ៉ាងដល់ពិធីបុណ្យព្រះពជា ៗ ឥឡូវនេះ អ្នកត្រូវមានគេស្រឡាញ់និងគោរព ព្រមទាំងបានជាអង្គព្រះសម្មាសម្ពុទ្ធ មួយអង្គទៅអនាគត ៗ មារឆ្លើយថា មានសាវ័កជាច្រើន ដូចជាលោកម្ចាស់ជាដើម គ្មានមេត្តាធម៌បន្តិចសោះ អនាគត បើខ្ញុំបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ខ្ញុំខ្លាចក្រែងតែមានចិត្តឃោរឃៅដូចលោកម្ចាស់ ៗ ព្រះថេរៈថា ៖ នែមារ អ្នកកុំគិតដូច្នោះ គឺដោយសារអានុភាពនៃយើងនេះហើយ ទើបអ្នកនឹងបានជាព្រះសម្មាសម្ពុទ្ធទៅអនាគត ៗ ពេលនោះ មារថា ខ្ញុំអាចនិម្មិតជាតួអង្គព្រះសម្មាសម្ពុទ្ធបានក្នុងកាលឥឡូវនេះ ៗ ព្រះថេរៈថា អ្នកចូលនិម្មិតជាតួអង្គព្រះសម្មាសម្ពុទ្ធឲ្យយើងឃើញផង ព្រោះយើងមិនដែលឃើញព្រះសម្មាសម្ពុទ្ធសោះ ឃើញតែធម៌និងវិន័យតែប៉ុណ្ណោះ ៗ មារថា៖ ខ្ញុំសុខចិត្តធ្វើតែលោកម្ចាស់កុំថ្វាយបង្គំខ្ញុំ ៗ ព្រះថេរៈក៏សុខចិត្ត ៗ មារចូលទៅក្នុងព្រៃហើយនិម្មិតជាតួអង្គព្រះសម្មាសម្ពុទ្ធ ប្រកបដោយមហា-

បុរិសលក្ខណៈ មានរស្មីភ្លឺផ្លេកត្រចះត្រចង់ មានទាំងអគ្គសាវ័កឆ្វេង-ស្តាំ ហែហមចេញពីព្រៃមក ។ ឧបគតក្រឡេកឃើញ ភ្លេចពាក្យប្តេជ្ញាក៏ក្រាបថ្វាយបង្គំ ។ មារផ្លាស់ភេទមកដូចដើមវិញ ហើយសួរឧបគតថា ហេតុម្តេចក៏លោកម្ចាស់ថ្វាយបង្គំខ្ញុំ ។ ឧបគត ថា នែមារ អ្នកកុំថាយើងថ្វាយបង្គំអ្នកដូច្នោះ យើងថ្វាយបង្គំតួអង្គព្រះសម្មាសម្ពុទ្ធ ដែលយើងឃើញអំបាញ់មិញទេតើ ។ មារពាល់ប្រាជ្ញក៏អង្គុយនៅស្ងៀម ។ ចាប់តាំងពីថ្ងៃនោះមក មារក៏ចុះចូលក្នុងព្រះពុទ្ធសាសនារហូតមក ។

—ចប់—

វិចារណកថា

# ព្រះត្រៃបិដកជាមូលដ្ឋានមនោគមជាតិ

---

យើងទាំងអស់គ្នាបានស្ដាប់ ព្រះរាជសុន្ទរកថា ដ៏ពីរោះផ្អែមឆ្ងាញ់ មានសារៈជ្រាលជ្រៅជាអនេកប្បការ របស់សម្ដេចព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដ៏ជាទីគោរព ស្នេហាស្មើជីវិតរបស់យើង កាលក្នុងពិធីសម្ពោធព្រះត្រៃបិដកពីថ្ងៃទី២ មេសា ១៩៦៩ ។ ចំពោះព្រះវាចានៅក្នុងព្រះរាជសុន្ទរកថានោះ ប្រសិនជាយើងគ្រាន់តែស្ដាប់ៗ រសជាតិពីរោះនោះឯង ហាក់ដូចជាធម្មតា ប៉ុន្តែបើយើងត្រិះរិះបណ្ដើរជាមួយព្រះសូរសៀង ឬយកអត្ថបទព្រះរាជសុន្ទរកថានេះ មកពិនិត្យឡើងវិញផងនោះ យើងនឹងរឹងរឹតតែកោតសរសើរស្ញប់ស្ញែងក្នុងចិត្តក្រៃលែងណាស់ ។ ព្រោះសេចក្ដីមួយៗ ក្នុងព្រះរាជវាចានោះ មានន័យធំទូលាយ អាចជាទ្រឹស្ដី ឬឱវាទ ដ៏កម្ររកបាន ឬថា អាចទៅជាមេគំនិតក្នុងលទ្ធិជាតិនិយមជ្រៅជ្រះបំផុត មិនងាយប្រៀបផ្ទឹមបាន ។

ព្រះរាជឱវាទនេះហើយ ជាមូលដ្ឋាននៃមនោគមជាតិ ដែលកំពុងតែត្រូវការឲ្យមានគ្រប់គ្រាន់ នៅក្នុងគ្រាបច្ចុប្បន្ននេះ និងទៅអនាគត ។

ជាបឋម សម្ដេចឪជាអម្ចាស់ ព្រះអង្គទ្រង់ត្រាស់រំឭកចំពោះយុវជនដែលកំពុងតែសិក្សាក្រេបជញ្ជក់រសជាតិវិទ្យាសាស្ត្រសម័យថ្មីព្រមទាំងវិជ្ជាផ្លូវលោកទូទៅ ប្រកបដោយល្បឿនយ៉ាងខ្លាំង ។ សម្ដេចជាអម្ចាស់ ទ្រង់

*ដោយបញ្ជាក់ច្បាស់ពន់ពេកណាស់ ឲ្យយុវជនយើងយល់ថា ការភ័ន្តច្រឡំរបស់អ្នកខ្លះ ដែលរវាតចិត្តចេញពីព្រះពុទ្ធសាសនា ហើយបែរទៅជ្រើសយកគោលទ្រឹស្ដីដែលជាមនោគមវិជ្ជាបរទេសមកជាក់ខ្លួននោះ ជាហេតុនាំឲ្យកើតវិនាសហិនហោចដល់ខ្លួនទៅវិញទេ គឺថា មនោគមវិជ្ជានោះឯង មានប្រយោជន៍ចំពោះជាតិគេមែន រីឯយើងឯនេះវិញ មិនអាចទទួលផលរបស់គេនោះកើតទេ ព្រោះខុសផ្លូវអំពីឧត្តមប្រយោជន៍ជាតិយើង ។*

*ត្រង់នេះ ព្រះរាជបន្ទូលបានថ្លែងថា ៖*

យុវជនយើង បើពុំបានទទួលព្រះពុទ្ធោវាទនិងទស្សនវិជ្ជាតាមផ្លូវព្រះពុទ្ធសាសនាទេ នឹងគ្មានអាវុធអ្វីសម្រាប់ការពារខ្លួន ទល់នឹងមនោគមវិជ្ជាបរទេស ដែលមានតម្លៃតាមរបៀបគេដែរ, ក៏ប៉ុន្តែនៅប្រទេសកម្ពុជា មនោគមវិជ្ជាបរទេសទាំងនោះ គ្មានបានហុចផលអ្វីក្រៅអំពីការច្របូកច្របល់គ្នានិងការភ្លាំងភ្លាត់ស្មារតីដ៏ខ្លោចផ្សា ដែលនាំឱ្យដើរខុសផ្លូវ ផ្ទុយនឹងឧត្តមប្រយោជន៍ជាតិ ហើយដែលយើងចាប់ទទួលផលអាក្រក់ខ្លះៗ ទៅហើយ នោះទេ ។ អាស្រ័យហេតុនេះ ព្រះត្រៃបិដកប្រែ បាលី - ខ្មែរ, ដែលយើងមាន ចាប់តាំងពីពេលនេះទៅ មានសារៈសំខាន់ណាស់ ក្នុងការពង្រីកផ្សព្វផ្សាយព្រះពុទ្ធោវាទ នៃព្រះបរមគ្រូនៅក្នុងសង្គមជាតិយើង ។

*បន្ទាប់ពីនេះ សម្ដេចឪអគ្គមគ្គុទេសក៍ជាតិ ទ្រង់ប្រោសព្រះរាជឱវាទ បញ្ជាក់ចំពោះយុវជនដែលមានការសិក្សាជ្រាលជ្រៅ ទៅក្នុងវិជ្ជាជាន់ខ្ពស់*

សម័យថ្មី ហើយដែលច្រើនយល់ប្រទៀថាក្បួនខ្នាតខាងព្រះពុទ្ធសាសនាមិនសូវជាសារៈប្រយោជន៍សម្រាប់ខ្លួន មានតែព្រះសង្ឃទេដែលលោកត្រូវការរៀនសូត្រ ចំណែកខ្លួនស្ថិតនៅក្នុងវិជ្ជាលោកទំនើបថ្មីផ្សេងៗក្ដីគម្ពីរទាំងនោះ ហើយអ្នកខ្លះហួតដល់ទៅហ៊ានថាវិជ្ជាផ្លូវលោករបស់ខ្លួននោះ មានសុក្រិតភាពលើសលែងផង ។ ចំពោះការដោះស្រាយកំហាត់សំអាងឥតន័យទាំងនេះ សម្ដេចឪជាអម្ចាស់ទ្រង់ត្រាស់ដោយបញ្ជាក់នូវរសជាតិចំណីអាហារកើតពីព្រះត្រៃបិដក មានសេចក្ដីថា៖

ព្រះត្រៃបិដកនេះ មិនផ្ដល់ឧត្ដមប្រយោជន៍ចំពោះតែព្រះសង្ឃទេ យុវជនយើងដែលជាអនាគតរបស់ជាតិ ហើយដែលទទួលចំណេះវិជ្ជាជ្រៅជ្រះខាងច្បាប់ ឬខាងអក្សរសាស្ត្រ, ខាងវិទ្យាសាស្ត្រ ឬខាងវិជ្ជាបច្ចេកទេសសម័យថ្មី ក៏មានលទ្ធភាពអាចក្រេបជញ្ជក់នូវរសជាតិ នៃអាហារខាងផ្លូវចិត្តគំនិតប្រាជ្ញាពីព្រះត្រៃបិដកនេះបាន ដូចព្រះសង្ឃយើងដែរ ។

តពីនេះមកទៀតព្រះបិតាជាតិទ្រង់ក្រើនរំឭកចំពោះអគ្គការរដ្ឋ និងអ្នករាជការទូទៅ សូមឲ្យតាប់អារម្មណ៍យ៉ាងណាស់ទៅលើព្រះត្រៃបិដករបស់ខ្មែរយើងនេះ ដោយព្រះអង្គទ្រង់បង្ហាញហេតុផល ចំពោះការអាន ការសិក្សាព្រះត្រៃបិដក ដែលអាចផ្ដល់មកវិញ នូវការបម្រើនលូតលាស់ខាងផ្លូវចិត្ត ពោលគឺមានប្រាជ្ញាវាងវៃ មានគំនិតទូលំទូលាយ មានការចេះដឹងទូទៅ និងមានចរិយាមារយាទប្រពៃថ្លៃថ្នា សមរម្យថ្លៃថ្នូរទៅតាមសង្គមជាតិដែលមានវឌ្ឍនភាពក្នុងគ្រាសព្វថ្ងៃ ។ មិនតែប៉ុណ្ណោះអាចបណ្ដុះសតិ

ឲ្យជនអ្នកសិក្សានោះឯង មានឆន្ទៈល្អហ្មត់ហ្មងក្នុងការកសាងកម្ពុជរដ្ឋជាប្រទេសជាតិនៃយើង ឲ្យនៅមានលក្ខណៈល្អស្អាតជាខ្មែរព្រមទាំងឲ្យមានសភាពស្អាតស្អំបរិសុទ្ធក្នុងការងារបំរើកិច្ចការរដ្ឋ ពោលគឺការងារអចិន្ត្រៃយ៍របស់អ្នករាជការទាំងនោះ ហើយទីបំផុតអាចជាកម្លាំងមោះមុត ជួយរុញច្រានការកសាងជាតិឲ្យមានប្រសិទ្ធិភាពគ្រប់វិស័យផង ។ ព្រះរាជាបណ្តាំនេះ មានសេចក្តីថា ៖

ខ្ញុំសូមបន្ថែមថា សមាជិកគ្រប់ជាន់គ្រប់ថ្នាក់នៃអង្គការរដ្ឋ និងរាជការយើង ក៏ត្រូវតែចាប់អារម្មណ៍ចំពោះព្រះត្រៃបិដកនេះ ពីព្រោះសមាជិកគ្រប់រូបនោះ បើប្រសិនជាខ្លួនហើយ មានបំណង់ ចង់ល្អលាស់ខាងផ្លូវចិត្ត ហើយមានឆន្ទៈចង់ជួយកម្ពុជរដ្ឋឱ្យនៅជាខ្មែរហើយ ជួយអង្គការរដ្ឋ រាជការជាតិ ឱ្យមានសភាពស្អាតស្អំ និងប្រសិទ្ធិភាពក្នុងវិស័យកសាងជាតិ ត្រូវតែមានព្រះត្រៃបិដកមួយចប់ នៅកំដរដំណេកខ្លួន ។

ព្រះរាជបន្ទូលនៅចុងឃ្លានេះថា „ត្រូវតែមានព្រះត្រៃបិដកមួយចប់នៅកំដរដំណេកខ្លួន„ បានសេចក្តីថា ការសិក្សានេះមិនចាំបាច់ហ្វឹកហ្វឺនក្នុងសាលា ចំពោះមុខគ្រូអាចារ្យណាឡើយ ព្រោះអ្នកសិក្សានេះជាអ្នកចេះដឹងដែរហើយ មានវ័យក៏ចម្រើនដែរហើយ អាចអានសៀវភៅផ្សេងៗជាមួយការត្រិះរិះរបស់ខ្លួនទៅ ក៏អាចនឹងបានយល់ហួរហែដែរ ។ ប្រសិនជានៅងឿងឆ្ងល់ត្រង់អន្លើខ្លះ យើងអាចចាំទុក ឬកត់ត្រាទុក យកទៅសាក

សួរលោកអ្នកប្រាជ្ញណាមួយ ក៏នឹងបានយល់ថែមឲ្យច្បាស់ជាមិនខាន ។ ឯពាក្យថា "នៅកំដរដំណេក" នោះ សម្រាប់ជម្រះសេចក្ដីចង្អៀតចង្អល់របស់ជនខ្លះ ដែលតែងតែត្អូញត្អែរថា "គ្មានពេលទេ មួយថ្ងៃៗ រវល់ណាស់ កិច្ចការច្រើនធ្វើសឹងតែមិនអស់ពីលើតុ" កិច្ចការច្រើនពិតហើយតែនៅពេលមុននឹងសម្រានលក់ គេអាចឆ្លៀតអានសៀវភៅក្បួនខ្នាតទាំងនេះបានខ្លះដែរ ។ ម្ល៉ោះហើយ ក្បួនខ្នាតនេះ ត្រូវនៅជាគ្រឿងកំដរដំណេកជាដរាប ។

មុននឹងបញ្ចប់ព្រះរាជឱវាទក្នុងព្រះសុន្ទរកថានាវេលានោះ សម្ដេចឪព្រះអគ្គមគ្គុទេសក៍ជាតិ ទ្រង់ត្រាស់ផ្ដាំយ៉ាងច្បាស់លាស់ថា ៖

" ខ្ញុំយល់ ហើយជឿជាក់ណាស់ថា យើងពុំអាចរកការពិត និង ផ្លូវត្រូវឃើញ នៅទីដទៃណា ក្រៅពីព្រះធម៌នេះទេ ។ ,,

ព្រះរាជបន្ទូលថា "ព្រះធម៌" ក្នុងទីនេះ សំដៅដល់ព្រះសូត្រ ព្រះវិន័យ និងព្រះអភិធម្ម ដែលមានក្នុងព្រះត្រៃបិដក ដែលអាចចាត់ទុកជាមូលដ្ឋាននៃឧបនោគមជាតិ ព្រោះថាគោលនយោបាយខ្មែរ ដែលសម្ដេចឪព្រះអង្គទ្រង់បង្កើតឡើងនោះ គឺ "សង្គមនិយមព្រះពុទ្ធសាសនា" បានន័យថា យើងយកទ្រឹស្ដីដ៏ពិសិដ្ឋនៃព្រះសម្មាសម្ពុទ្ធធ្វើជាមូលដ្ឋាន ។ ទ្រឹស្ដីដ៏ពិសិដ្ឋនេះហើយ គឺជាតួព្រះត្រៃបិដក ។

រៀប-រៀងសម្រួល ដោយ

លី-ធាមតេង

នៅវិជ្ជាឋាន ពុទ្ធសាសនបណ្ឌិត្យ

# ផ្នែកអក្សរសាស្ត្រ

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

(គ)

*ព្រះមហា ចាំង-ទាត់ រៀបរៀង*

អភិវធិ ធាតុ ភ័យ ។

អភិវន្ទិ ធាតុ ថ្វាយបង្គំ គោរព ។

អភិវន្ទន នបុំ. អភិវន្ទន៍ កិរិយាថ្វាយបង្គំដោយគោរព ។

អភិវណ៌ន នបុំ. អភិពណ៌ន ពិពណ៌នា ។ វណ៌ិត គុ. ដែលពិពណ៌នា ។

អភិវតិន គុ. ដែលទៅដួប ។

អភិវធិន នបុំ. អភិវឌ្ឍន៍ កិរិយាចំរើន ។

អភិវើ បុំ. ភ្លៀង ។ វើិន គុ. ដែលភ្លៀង ។ -វើណា គុ. ដែលភ្លៀង ។ នបុំ. ភ្លៀង កិរិយាភ្លៀង ។

អភិវ្ឫ ធាតុ លោតរំលង ។

អភិវស៑ ធាតុ នៅសំចត ។

អភិវហ៑ ធាតុ នាំទៅ ។

អភិវា ធាតុ ផ្លុំ ។

អភិវញ្ឆ ធាតុ. ចង់បាន ។ វញ្ឆិត គុ. ដែលចង់បាន ។ នបុ. ប្រាថ្នា ៙

អភិវញ្ឆា ស្ត្រី. បំណង ។

អភិវាទ បុំ អភិវាទ កិរិយាបង្គំ ។ សំដីមើលងាយ ។

អភិវាទក គុ. អ្នកថ្វាយបង្គំ ។ -វាទនីយ ឬ វាទ្យ គុ. ដែលគួរថ្វាយបង្គំ ។

អភិវាទិន៑ ការក. អភិវាទិន អ្នកបកភាសា ។

អភិវាគិ៍ ធាតុ. ស្រែកគ្រលួច ។

អភិវាហ្យ នបុំ. កិរិយាគួរនាំយកទៅ កិរិយានាំ ។

អភិវិក្រម គុ. អភិវីក្រម ក្លាហានក្រៃលែង ។

អភិវិខ្យាត គុ. ដែលល្បីល្បាញ ។

អភិវិជ្ញា ធាតុ ដឹងច្បាស់ ។

អភិវិជ្ញេយ គុ. ដែលគប្បីស្គាល់បាន ។

អភិវិធ្វល៑ ធាតុ ឆេះទ្រលោម ។

អភិវិទ៑ ធាតុ ដឹងជាក់ និយាយរឿង ។

អភិវិទ៍ ធាតុ ឃើញ ស្គាល់ ។

អភិវិទីបិត គុ. ដែលឆេះខ្ទក ។

អភិវិទ្ធ គុ. ដែលមុត ដែលត្រូវរបួស ។

អភិវិទ្រ ធាតុ គេចរត់ ។

អភិវិនទ៍ ធាតុ ស្រែកធំទៀល។ -នាទិត គុ ដែលលាន់លឺ ។

អភិវិនីត គុ. ដែលចេះដឹង ជំនាញ ។

អភិវិនុទ៍ ធាតុ ធ្វើឲ្យស្ងប់ ធ្វើឲ្យរីករាយ ។

អភិវិបន្យ គុ. ដែលផ្សេងគ្នាស្រឡះ ។

អភិវិមាន គុ. អភិវិមាន , ដែលមានគំនិត ? ។

អភិវិរាជិ ធាតុ ភ្លឺក្រៃលែង ។ - រាជិត ដែលភ្លឺច្បាស់ ។

អភិវិរុចិ ធាតុ រុងរឿង ព្រោងព្រាយ ។

អភិវិគ៍ ធាតុ ចូលក្រៃលែង ផុងខ្លួន ។-វិគ្គ គុ. ដែលផុងខ្លួន ។

អភិវិគ្គន គុ. ដែលខ្លាច ។

អភិវិគ្រ ធាតុ បែកជាចំណែក ។

[illegible] គុ [illegible]

[illegible] ធាតុ [illegible] ។

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ឆ្ង-កា ង

ប្រែ-រៀបរៀង

(៣)

| | |
|---|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ | អ្នកវាងវៃឆ្លាសបើបានអាន |
| នឹងបេះឧបាយកលចំណាន | ទាំងមានសន្តានស្នេហាជាតិ |

យូរ-អ៊ុន

ខុនបេងបានឃើញដូច្នោះ ក៏តែងតែមានសេចក្តីត្រេកអរពន់ប្រមាណ ណាស់ ក្រាបសំពះដោយសច្ចៈគារពហើយ ក៏ចុះចាកសាលទេព្រ័ក្សឡើង រទេះត្រឡប់មកបន្ទាយ, លុះដល់ពេលព្រឹក ខុនបេងក៏បបួលអងប៉េងនិង ទាហានទាំងពួងដែលគមិនបេះស្តី ស្រូតទៅរើសស្វែកឈើតាមពាក្យ ទេព្រ័ក្សថា, លុះធ្ងន់ភ្នំស័នស្រុកទៅ ចម្ងាយ ២០ សិន ឃើញដើមឈើធំ នៅក្បែរមាត់ជ្រោះ ជាច្រើនណាស់ ហើយមានផ្ទះអ្នកស្រុកនៅក្នុងព្រៃ នោះប្រមាណផ្ទះ ១០ ខ្នង, ខុនបេងបានឃើញក្មេងម្នាក់ដើរមក ក៏អរណាស់ ខំដើររូតរះចូលទៅជិត ទទួលបេងបៀត ពាក់អាវសម្លូកផ្តៅ សក់លឿង ភ្នែកក្រហមដើរចេញមក ឃើញខុនបេងក៏សួរថា អ្នកនេះឬជាមហាឧបរាជ ស្រុកសែឈួន? ខុនបេងសើចហើយថា ហេតុម្តេចបានជាអ្នកស្គាល់ខ្ញុំ ? បេងបៀតឆ្លើយថា ខ្ញុំដឹងស្គាល់មកយូរហើយ ថាមហាឧបរាជលើកកង

ទ័ពមកច្បាំងនឹងបេងហោក នឹងបង្រ្កាបក្នុងដែននេះ, បេងកៀតក៏អញ្ជើញខុនបេងចូលទៅក្នុងផ្ទះអាត្មា; ខណៈនោះខុនបេងនិយាយនឹងបេងកៀតថា គម្រាស់ព្រះចៅឡៅសៀន ឲ្យខ្ញុំលើកទ័ពមកប្រាបប្រាមបេងហោក ឲ្យចំ-ណុះចុះចូលៈឡើងស្តាប់បង្គាប់ស្រុកសែឈួនឲ្យបាន ឥឡូវបេងហោកមិនហ៊ានតដៃ រត់ទៅនៅក្នុងព្រៃភ្នំអិមតង់ស៊ែន ខ្ញុំលើកទាហានទៅដល់ផ្លូវទិសខាងលិចភ្នំ, ពួកទាហានខ្ញុំចុះផឹកទឹកជ្រោះមួយអន្លើ ក៏ទៅជា-គទាំងអស់, ទេព្រ័ក្សប្រាប់ខ្ញុំ ថាមានថ្នាំកែទឹកពុលនោះនៅតំបន់នេះ បានជាខ្ញុំខំស្រូតវូតមករកអ្នក ប្រាថ្នានឹងរកថ្នាំនោះ, អ្នកចូរមេត្តាណែបង្ហាញឲ្យខ្ញុំទៅរកផង ដើម្បីនឹងបានជួយជីវិតមនុស្សឲ្យរស់រួចទៅ ។

បេងកៀតថាខ្លួនខ្ញុំជាអ្នកព្រៃថោកទាបណាស់ មិនគួរមហាឧបរាជទំស្វែងស្វះមកខ្លួនឯងឲ្យព្រួយទេ, បើប្រើតែកូនទាហាន១ ឲ្យមករកខ្ញុំក៏បាន, ឯថ្នាំសោត ក៏មាននៅក្រោយភូមិច្រើនណាស់, បើមហាឧបរាជនឹងត្រូវការដូចម្តេចខ្លះ ក៏ឲ្យមនុស្សទៅរើសយកចុះ; ហើយបេងកៀតក៏ឲ្យក្មេងម្នាក់នាំអង់ប៉េង និងទាហានដែលគនោះចេញទៅដល់ទីជ្រោះ, ទាហានទាំងនោះបានផឹកទឹកជ្រោះទាំងអស់គ្នា ក៏ក្អួតធ្លាក់ស្លែស្មអាក្រក់ចេញមកអស់ ហើយបានស្តីនិយាយគ្នាជាឡើងវិញដូចដើម; បេងកៀតក៏និយាយនឹងខុនបេងថា ផ្លូវដែលលោកនឹងទៅលើភ្នំអិមតង់ស៊ែននោះ ឆ្ងាយដាច់ស្រយាលណាស់ ប្រកបទៅដោយសត្វកាចសាហាវផ្សេង ៗ, លោកចូររើសយកស្លឹកឈើហុយហៀបនេះទៅឲ្យច្រើន នឹងបានការពារអន្តរាយតាមផ្លូវនោះ, ខុនបេង

បានស្ដាប់ពុទ្ធដូច្នោះក៏ឆ្លើយតបថា អ្នកមានសេចក្ដីមេត្រីនឹងខ្ញុំច្រើនណាស់, អ្នកឈ្មោះអ្វី ? សែអ្វី ? បើខ្ញុំបានធ្វើការសម្រេចសេចក្ដីប្រាថ្នាហើយ ខ្ញុំនឹងបានតបស្នងសងគុណអ្នកវិញ ។

បេងចៀតឆ្លើយថា ខ្ញុំឈ្មោះចៀត សែបេង ជាបងបេងហេកបង្កើត, ខុនបេងបានឮជាក់ដូចគេភ្ញាក់ពេលព្រលឹងដក ដង្ហើមធំហើយថា យីដូច្នោះឬ? បេងចៀតថា លោកកុំមានពិការល់ធ្ងល់សង្ស័យចិត្តឡើតតែខ្ញុំជាបងប្អូនដូច្នោះ ព្រោះខ្ញុំជាបងរួមថ្ងៃមួយនឹងបេងហេកក៏មែន តែថាបេងហេក-បេងហ៊ុំ វាជាមនុស្សអន្ធពាលចិត្តបាប វាមិនបានយកច្បាប់តម្រាខ្ញុំជាបងបានជាខ្ញុំលះលែងចងមេត្រីជាសាលោហិតនឹងវា ដកឃ្លាមកពួនទៅទីនេះ ប្រាថ្នានឹងរកសេចក្ដីសប្បាយ, ឥឡូវប្អូនខ្ញុំធ្វើការទាំងឡាយខុសមិនត្រូវនឹងផ្លូវប្រវេណី បានជាមហាឧបរាជមានទីលំបាកមកដល់ស្រុកនេះ, ខ្លួនខ្ញុំជាបង ក៏គង់មានគំណិះគេតិះដៀលបាន, ហេតុនេះ តាមតែមហាឧប-រាជប្រោសប្រាណឲ្យមានអាយុជីវិតតទៅផងចុះ ។

ខុនបេងថា អ្នកកុំព្រួយបារម្ភឡើយ, ឯបេងហេកបេង-ហ៊ុំនោះឃើញថាវាជាមនុស្សផ្លូជាតិមារយោទកាក្រក់ណាស់, វាប្រព្រឹត្តខុសទាស់តែពីខ្លួនវា ខ្លួនអ្នកជាមនុស្សល្អ មានសេចក្ដីសត្យត្រង់នឹងខ្ញុំ ។ ក៏ត្រូវស្រឡាញ់រាប់អានដោយស្មោះ, បើកាលណាខ្ញុំធ្វើការនេះរួចទាំងអស់ត្រឡប់ចូលទៅស្រុកក្រុងវិញ ខ្ញុំនឹងក្រាបទូលព្រះចៅឡើងសៀនឲ្យស្ដេចចេញប្រកាសតាំងអ្នកជាធំក្នុងដែននេះតទៅ ។

បេងបៀតថា ដែលប្រសាសន៍ប្រោសអនុកូលទាំងម៉្លេះ ព្រះតេជព្រះគុណមិនមានទីបំផុត តែចិត្តខ្ញុំបាទស្រឡាញ់តែសេចក្ដីសប្បាយស្ងាត់ ៗ មិនចូលចិត្តនឹងយសសក្ដិសម្បត្តិកស្តុហ៍នជាធំទេសោះ; ខុនបេងឮដូច្នោះ ក៏ឲ្យរបស់ទ្រព្យមានតម្លៃដល់បេងបៀតជាច្រើន, បេងបៀតក៏មិនបានទទួលយករបស់នោះ បែរជាលើកប្រគល់ឲ្យខុនបេងវិញ, ខុនបេងក៏លាបេងបៀតឡើងរទេះគូបនាំទាហានត្រឡប់មកបន្ទាយ ។

ខុនបេងក៏ឲ្យទាហានទាំងឡាយជីកអណ្ដូងក្នុងបន្ទាយ១ អន្លើ ជម្រៅ ៤០ ព្យាម ប្រាថ្នានឹងអាស្រ័យទឹក, ខុនបេងនឹងទាហានទាំងពួង ឃើញអណ្ដូងនោះស្ងួតក្រៀមគ្មានទឹកសោះ ក៏ព្រួយបារម្ភពន់ប្រមាណ លុះវេលាយប់ខុនបេងក៏អុជទៀនធូបអធិដ្ឋានបួងជាទេវតា ហើយប្រកាសថា ខ្ញុំម្ចាស់ខុនបេង តាំងចិត្តធ្វើជការថ្វាយចំពោះព្រះតេជព្រះគុណព្រះចៅឡៅពីដោយសុចរិតបានជាគិតលើកព្រះចៅឡៅសៀនឡើងគ្រងរាជសម្បត្តិ តាំងចិត្តថានឹងឲ្យបណ្ដារាស្ត្របានសេចក្ដីសុខសប្បាយតទៅ ឥឡូវពលទាហានគ្មានទឹកបរិភោគជាកម្លាំងសោះ, បើបុណ្យព្រះចៅឡៅសៀនមិនអស់ នឹងបានជាធំ, ខុនខ្ញុំនៅបានជាអ្នកទំនុកបម្រុងតទៅ, ក៏សូមឲ្យទេវតាមកជួយបើកផ្លូវទឹកក្នុងអណ្ដូងទាំងប៉ុន្មានឲ្យមានបរិបូណ៌ចុះ ដើម្បីជួយឲ្យរស់ជីវិតពលទាហានទាំងអស់នេះតទៅ, បើព្រះចៅឡៅសៀនគ្មានបុណ្យតទៀតទេ, ចូរបណ្ដាលឲ្យខ្ញុំខុនបេងដ៏មានបុព្វអភ័ព្វស្លាប់ក្នុងខណៈនេះទៅចុះ, កុំបីឲ្យខ្ញុំមានអាយុរស់នៅឃើញមុខអ្នកឯណាឡើយ លុះផ្សងសច្ចាហើយ

ក៏ចូលនិទ្រា ។

លុះពេលព្រឹកភ្លឺស្រាងកាលណា ទាហានចូលទៅជម្រាបខុនបេងថា អណ្តូងដែលជីកទុកទាំងប៉ុន្មាន មានទឹកចេញពេញប្រៀបទាំងអស់, ខុន-បេងបានឮដូច្នោះ ក៏សប្បាយចិត្តសោមនស្ស បង្គាប់ឲ្យពលយោធាផង ដួតជីកស្រេចហើយ ក៏លើកទ័ពគ្រឹកឡើងទៅលើភ្នំអិមតងស័ន ហើយ ឲ្យដងទឹកនោះទៅជាកំណាន់សម្រាប់ផឹកតាមផ្លូវ ។

ឯទាហានល្បាត ក៏នាំរឿងទៅប្រាប់បេងហោកថា ឥឡូវខុនបេង លើកទ័ពលួងជួនទៅទិសឯលិច ចូលមកបានហើយ, បេងហោកឮដូច្នោះ ក៏ភ័យណាស់, តោស៊ូតែអង ក៏និយាយទៅបេងហោកថា អ្នកកុំអាល ព្រួយបារម្ភដំណើរដែលឮមកនេះ នៅមិនទាន់សមប្រកបទេ ចាំពិនិត្យ គិតគ្នាឲ្យឮនឹងត្រចៀកឃើញច្បាស់នឹងភ្នែកសិន, តោស៊ូតែអងក៏ឡើង ទៅឈរសម្លឹងមើលលើកំពូលភ្នំ ឃើញខុនបេងលើកទ័ពធំជិតចូលមក ឃើញទាហាននាំយកទឹករែកសែងជាច្រើនណាស់, តោស៊ូតែអងពិភាល់ណាស់ក៏ត្រឡប់ចុះមកប្រាប់បេងហោកថា ខុនបេងលើកទ័ពមកបានមែន ហើយ ខ្ញុំសែនធុញណាស់ ប្រហែលជាទេព្រ័ត្រអ្នកតាបទោប្រាប់ដំណើរ ចំនងខុនបេងជាប្រាកដ ។

បេងហោកថា បើដូច្នោះ ខ្ញុំនឹងបេងហ៊ុំតេវ ទាក់បង្អួន ដឹងណាហោក ចេញទៅតស៊ូខឹង ខុនបេងឲ្យត្រូវតែឃ្លាតជាតែនៅទីនេះចុះ មិនឲ្យទាហាន

ខាងណោះ ចាប់ចងទៅឲ្យខុងបេងមើលមុខទៀតទេ, តោស៊ូតែអងថា ខុងអ្នកនឹងខ្ញុំ ជាពួកជាមួយគ្នា បើអ្នកចាញ់ប្រៀបខុងបេងកាលណា ខ្ញុំជាស្ម័គ្រប័ក្ខពួកដោយសារ ខុងបេងក៏គង់មិនទុកអាយុជីវិតដែរ ។

ខណៈនោះតោស៊ូតែអង ក៏ឲ្យសម្លាប់គោក្របីលៀងស្រាបណ្តាពលទាហានទាំងពួង ដើម្បីនឹងរៀបចំលើកកងទ័ពទៅច្បាំងនឹងខុងបេង, ទទួលមានទាហានចូលមករាយការណ៍ប្រាប់ថា អៀវហេង ដែលជានាយធំនៅក្នុងនិទតិស័ន លើកទាហាន ៣០.០០០ មកជួយ តោស៊ូតែអងបានឮដូច្នោះក៏មានអំណរណាស់ចេញទៅទទួលគំនាប់គ្នាតាមប្រវេណី ហើយនាំទាហាននិងអៀវហេងចូលទៅក្នុងទីលំនៅ ។

អៀវហេងជូតថា កូនខ្ញុំ ៥ នាក់នេះ មានសតិបញ្ញានិងប៉ិនដៃខ្លាំងពូកែណាស់ ទាំងពលទាហានខ្ញុំក៏មានកម្លាំងក្លាហាន ពាក់ក្រោះដែកស្មើគ្រប់គ្នា, បើខុងបេងលើកពលយោធា១៥០មុឺន ចូលមក សូម្បីតែត្រឹមកម្លាំងក៏នឹងសុំអាសាយកជ័យជម្នះឲ្យបាន, ហើយក៏ហៅកូនទាំង ៥ នាក់ឲ្យចូលមកគំនាប់តោស៊ូតែអងនិងបេងហេក ។ ឃើញបុត្រអៀវហេងមានរូបរាងមុតមាំសមដូចខ្លាដ៏កាច ក៏មានសេចក្តីត្រេកអរណាស់ ទើបរៀបតែងតុលៀងអាហារឲ្យអៀវហេងនិងបុត្រ ៥ នាក់បរិភោគជាមួយគ្នា ។

ខណៈកាលកំពុងសេពសុរានោះ អៀវហេង តែងធ្វើស្រវឹងស្រា ហើយសម្តែងឫទ្ធិក្លៀវក្លាផ្សេងៗ មានរាំក្បួនលំពែងនិងក្បួនដែលលោតក្រវែលគ្រវាត់អាវុធថា បើខុងបេងមកកាលណា យើងនឹងកាត់សិរសាដោយ

អាវុធនេះ ទទួលមានស្រី១០នាក់ដែលអៀវហានធ្វើកលមកនោះ រំសាយសក់ដើរចេញមកទះដៃធ្វើជាក្មេង អៀវហានក៏ឲ្យបុត្រយកពែងស្រា ងើយមុខឡើងទឹងផឹក, អៀវហានស្រែកឡើងតាមសញ្ញា, បុត្រអៀវហានក៏ខ្មីខ្មាស្ទុះស្រទៅព្រួតចាប់ចងបេងហេកនិងបេងហ៊ុវបាន, គោស៊ូតៃអងឃើញដូច្នោះក៏ភ័យណាស់ ក្រោកឡើងគិតទឹងរត់ អៀវហាន ក៏ព័ទ្ធចាប់បានទាំង៣នាក់, ស្រី១០នាក់ក៏ស្ទុះប្រញូចប្រញាក់ចូលទៅជួយចងបេងហេក, បេងហេកថា អៀវហាន អ្នកឯងនិងយើង មិនដែលមានទោសទាស់ខុសចិត្តគ្នាអំពីអ្វីសោះ ហេតុម្ដេចអ្នកឯងមានសេចក្ដីអាឃាដព្យាបាទយើងដូច្នេះព្រោះប្រយោជន៍អ្វី? អ្នកឯងធ្វើដូច្នេះ អំណើះទៅមុខគង់នឹងមានទុក្ខក្ដៅក្រហាយ, អៀវហានថា មហាឧបរាជស្រុកសែឈួនមានចិត្តសប្បុរសមេត្តាដល់បណ្ដាសត្វទាំងពួងណាស់ ចាប់បានកូនចៅយើង ច្រើនក្រៃក្រាស់ហើយទុកអាយុមិនសម្លាប់ ត្រឡប់បើកលែងមកវិញអស់, យើងគិតដល់គុណ ដែលគេមានសប្បុរសមេត្តា បានជានាំគ្នាមកចាប់អ្នកឯងយកទៅជូនមហាឧបរាជជាសេចក្ដីតបគុណ ព្រោះយើងឃើញអ្នកឯងជាមនុស្សអាក្រក់សឹងពន់ប្រមាណ គ្មានស្គាល់គុណទោសសោះ គឺជាមនុស្សទុរយសទ្រុស្តអ្នកល្អ,ហើយអៀវហានស្រែកប្រកាសប្រាប់ទាហានទាំងពួងថា បេងហេកធ្វើសេចក្ដីខុស ឲ្យអស់អ្នកពលគ្នាបានសេចក្ដីក្ដៅក្រហាយ, គ្រានេះយើងប្រើកលឧបាយចាប់ខ្លួននាំយកទៅជូនខុងបេងហើយ អ្នកទាំងឡាយចូរត្រឡប់វិលទៅកាន់ភូមិស្រុក នៅជាសុខដោយករិយាបុត្រចុះ, ហើយ

អៀវហេងនោះ ក៏នាំយកខ្លួនបេងហោក បេងហ៊ីវ និង តោស៊ូតៃអង ទាំងចំណងទៅជូនខុនបេងក្រោយបន្ទាយ ។

ខុនបេងដឹងដូច្នោះ ក៏សោមនស្សប្រីតា ហៅអៀវហេងម្នីម្នានាំទៅធ្វើបដិសណ្ឋារៈគំនាប់ដោយប្រពៃ ហើយអៀងហេងក៏ស្រដីជម្រាបខុនបេងថា ខ្ញុំបាទជាមេឃុំត្រួតលើទីក្នុងនិតស័ន មានចិត្តប្រតិព័ទ្ធគិតដល់គុណមហាឧបការដែលបានទុកអាយុជីវិតលែងញាតិមិត្រនិងកូនចៅខ្ញុំបាទ ឲ្យវិលមកស្រុកភូមិវិញ បានជាខ្ញុំបាទអស់អញ្ញលំគេញចិត្តគិតឧបាយ ចាប់ខ្លួនបេង-ហោក-បេងហ៊ីវនាំមកតបស្នងសងគុណលោក, ខុនបេងក៏ឲ្យរង្វាន់ចំណាប់ជាគ្រឿងឧបភោគដល់អៀវហេងច្រើនណាស់ ហើយឲ្យយកខ្លួនបេងហោកចូលទៅ ខុនបេងគ្រះទ្បុកឃើញបេងហោកក៏សើចហើយថា អ្នកឯងនឹងព្រមចំណុះចុះចាញ់យើងហើយឬនៅ? ។

(នៅមានត)

*

* *

# រឿង
# គ្រោះថ្នាក់នាវារដោយខ្យល់ព្យុះ

របស់លោក ពីយែរ្រ ណាត តាម៉ារ

ប្រែសម្រួលដោយអ្នកស្រី ពេជ-សល់

## វគ្គទី ២២

កប៉ាល់ដែលនាងកាមាលានិងពីមេស្វូដិះដល់ម៉ោងហើយក៏ចេញអំពីកាលុនដូទៅ ទៅថ្នាក់លេខមួយនិងថ្នាក់លេខ ២ គ្មានអ្នកដំណើរណាក្រៅអំពីនាងកាមាលានិងពីមេស្វូទេ ពីមេស្វូរៀបចំបាយដាក់ចូលក្នុងបន្ទប់នាងកាមាលា អាស្រ័យទឹកដោះគោមួយកែវរួច ដាក់កៅអីអង្គុយនៅក្បែរមាត់ទ្វារបន្ទប់មើលទេសភាពស្រុកទេស ដែលដើរប្រាសនិងដំណើរកប៉ាល់នាងដិះ ។

– នាងដឹងថា យើងទៅណាទេហ្នឹង ? (ពីមេស្វូសួរ)

– ទៅស្រុកបង ។

-មិនមែនទេ ទៅធ្វើអ្វី បើនាងមិនចង់ទៅ

-ឱ ! មកពីខ្ញុំទេហ្នឹងបានជាបងប្រើចង ? ខ្ញុំនិយាយលេងសោះ មិនគួរបងយកជាមែន គ្រាន់តែនិយាយលេងកំដងដែរ ...

( និយាយហើយនាងធ្វើមុខក្រញូវ )

–ខ្ញុំឥតចងសោះទេ ព្រោះខ្ញុំក៏មិនចង់ទៅដែរ ។

-បើអីចឹងទៅណាទៅវិញ?

– ទៅស្រុកខាងលិច ។

ឮថាទៅស្រុកខាងលិចនាងបើកភ្នែកធំៗ ថែបដូចជាសប្បាយព្រោះនាងធ្លាប់បានឮគេនិយាយថា ស្រុកនោះសម្បូណ៌ប្រាសាទបុរាណ, ព្រៃធំៗ ក្នុងដែលប្រកបដោយព្រឹក្សាលតាវល្លិ៍ចំឡែកៗ ហើយថែមទាំងមានខ្យល់អាកាសត្រជាក់ផងៗ នាងសួរបញ្ជាក់កាំមេស្ហូថា "យើងទៅកន្លែងណា" កាំមេស្ហូឆ្លើយថា "មិនទាន់ប្រាកដទេ" ។

– ប៉ុន្តែយើងមុខជាកាត់តាមមុង្គារ, ប៉ាត់ណា, ទណាបូរ, ប៉ិក្យារ, គាស៊ីបូរីនិងបេណារេស ហើយក្នុងបណ្ដាក្រុងទាំងប៉ុន្មាននេះ យើងមុខជានឹងត្រូវឈប់នៅកន្លែងណាមួយមិនខាន ។

នាងកាមាលាធ្លាប់បានឮឈ្មោះស្រុកទាំងនោះដែរ ឈ្មោះខ្លះទៀត នាងមិនដែលបានឮសោះ ប៉ុន្តែនាងនៅតែគិតឃើញសប្បាយ ។

– មិនដឹងជាសប្បាយយ៉ាងណាទេបង ? ( នាងនិយាយ )

– កុំអាលគិតសប្បាយឥឡូវយើងត្រូវរកអ្វីញ៉ាំសិន ខ្ញុំថាប្រហែលជានាងមិនចូលចិត្តញ៉ាំបាយកប៉ាល់ទេមើលទៅ ?

នាងធ្វើមុខជូរ ព្រោះនាងខ្ពើមអាហារដែលធ្វើមិនស្អាតនាងគិតមួយសន្ទុះទើបប្រាប់ថា :

- ចាំខ្ញុំដាំបាយធ្វើម្ហូបខ្លួនខ្ញុំ ។

– ធ្វើកើតឬទេ ហ្នឹង ? (កាំមេស្ហូថែបមិនទុកចិត្ត )

ហួសចិត្តពេកនាងសើច ៖

—ចុះបងថាខ្ញុំជាមនុស្សអ្វីទៅ ថាខ្ញុំឥតចេះអីសោះទេយ៉ាងមើលទៅ? នៅផ្ទះមាខ្ញុំមានអ្នកណាធ្វើបាយទឹកក្រៅពីខ្ញុំ ។

—ខ្ញុំផ្ដាសតែម្ដងហើយ គិតស្មានខុស រៀបចំធ្វើទៅនាង ។

ក៏មេស្ហរត់ទៅរកខ្ទីជើងក្រានយួរតូចមួយមក ប៉ុន្ដែមិនទាន់គ្រប់សព្វទេ ។ នៅលើកប៉ាល់នោះ មានក្មេងប្រុសម្នាក់ឈ្មោះ អ៊ុយមេស្ហ ដែលជាពួកកាយាស្ត(១) នៅក្រុងបិងហ្គាល់ ចុះពីពួកព្រាហ្មណ៍មកមានតែពួកកាយាស្តនេះឯងទេ ក៏មេស្ហនិយាយជួលក្មេងនោះ ដើម្បីឲ្យជួយដាំស្លរនាងកាមាលា ។

· បានអ្វីញ៉ាំនៅពេលថ្ងៃត្រង់ កាមាលា ? (ក៏មេស្ហសួរ)

- ចា៎ យើងបានអ្វីញ៉ាំថ្ងៃត្រង់ ? បើបងយកតែអង្ករនិងបន្លែមកឲ្យខ្ញុំ តើឲ្យខ្ញុំធ្វើអ្វីកើត ? បងទៅសុំគ្រឿងគ្រៅអ្នកកប៉ាល់បន្តិចមក ។

បន្តិចក្រោយមក ក៏មេស្ហត្រឡប់មកវិញបានទាំងគ្រឿងទេសបន្តិចយកមកហុចឲ្យកាមាលា នាងទទួលយកហើយថា ៖

—ឲ្យខ្ញុំធ្វើម្ដេចទៅ ? បើបងយកគ្រឿងទាំងមូល ៗ មកឲ្យខ្ញុំហើយគ្មានត្បាល់ គ្មានអង្រែ បងនេះចំតែម្ដងហើយ រកមិនបានទេបែបនេះប្រើម្ដងបានមួយមុខ ។

ឮនាងថាដូច្នោះ ក៏មេស្ហរត់ទៅវិញ យកបានប្រដាប់ម្យ៉ាងប្រហែលនឹងត្បាល់ដែរ តែដល់ដាក់គ្រឿងបុកទៅ គ្រឿងខ្ចាតកំពប់អស់ ទ្រាំមិន

(១) វណ្ណៈអ្នកនិពន្ធ ។

បាន សើចទាំងអស់គ្នា នាងកាមាលាយកថោដ៏មួយដែលនាងដាក់ស្ករ ពីក្រុងកាល់គុត្តា មកធ្វើជាថ្នាំងសម្រាប់ស្ង ហើយប្រាប់កាមេស្ហឲ្យទៅដួត ទឹកទៅ ទំពាំងដួតហើយបាយម្ហូបក៏ឆ្អិនល្មមដែរ ។

- លុះដល់កាមេស្ហដួតទឹកស្រេច បាយក៏ឆ្អិនមែន តែនៅបញ្ហាបាន មិនដឹងជាបានបានពីណាមកជួសបាយបរិភោគសោះ ។ កាមេស្ហថា ទៅខ្ចីបានអ្នកកប៉ាល់ទៅ នាងកាមាលាបញ្ចេញទឹកមុខមិនស្រេច ព្រោះនាងប្រកាន់សាសនាណាស់ នាងនិយាយកាត់ក្ខាម :

ការហួស ថាហួសទៅចុះ តែមិនត្រូវធ្វើទៀតទេ ខ្ញុំទ្រាំមិនបានទេបង បើខុសម្តងហើយ ធ្វើលើខុសទៀតនោះ ។ ថាហើយនាងយកគំរបថោដួតយ៉ាងស្អាតជួសបាយដាក់រួចនាងថា ៖

- យកគ្របនេះធ្វើបានទៅ ធ្វើម្តេច ? ញុំាបណ្តោះអាសន្នទៅ ចាំក្រោយសឹមរកអ្វីឲ្យគ្រាន់បើជាងនេះ ។

កាមេស្តក៏ចាប់បរិភោគ ទើបតែទឹងបរិភោគបានពីរម៉ាត់ក៏លាន់មាត់ថា

- យីកាមាលា បេះធ្វើម្ហូបឆ្ងាញ់ផង !

- ណ្ហើយបង កុំសរសើរខ្ញុំឲ្យហត់ធ្វើអី

- ខ្ញុំមិនមែនបញ្ចើចទេ នាងញុំាខ្លួនឯងទៅដឹងហើយ ថាឆ្ងាញ់មែនឬខ្ញុំបញ្ឆោត ។

កាមេស្តត្រូវមាត់ទឹងអាហារនោះក៏បេះតែសុំថែមទៀត នាងកាមាលាសប្បាយចិត្តណាស់ ដោយឃើញកាមេស្ហឆ្ងាញ់បាយ ។

នែ! នាងនៅចាំអីទៀត តិចអស់ខានញ៉ាំ ។

– មិនអីទេបង នៅមានទៀត ។

– ចុះនាងបានទានឯណាដាក់បាយញ៉ាំ ?

– ញ៉ាំក្នុងគំរបធុងជាមួយបងទៅវាថី ?

– ខ្ញុំមិនឲ្យនាងធ្វើដូច្នេះទេ

– ឱ ! ចុះក្រែងខ្ញុំជាប្រពន្ធបងឬ? ណ្ហើយបានហើយបង ខ្ញុំដឹងការណីយកិច្ចរបស់ខ្ញុំពេក គិតតែរឿងបងទៅចុះ ។ អ៊ុយមេស្ហឯណោះ បានទានឯណាដាក់បាយញ៉ាំ ? (នាងកាមាលាងាកសួរទៅក្មេង ) ។

– ជំរាបប្រសាសន៍មិនអីទេទាន ខ្ញុំស្គាល់អ្នកលក់ស្ករនៅឯក្រោមម្នាក់ ចាំខ្ញុំទៅសុំស្លឹកគេបន្តិចមកបានហើយ ។

ឯក៏មេស្ហ គ្រាន់តែឮនាងកាមាលាឆ្លើយថាញ៉ាំបាយជាមួយអ្នក អ្នកយល់ច្បាស់ណាស់ទៅហើយ ប៉ុន្តែអ្នកមិនដឹងរកមធ្យោបាយណានឹងធ្វើឲ្យនាងកាមាលាយល់ថាអ្នកនិងនាងមិនមែនជាប្ដីប្រពន្ធទេ ក៏ឆ្លើយដូច្នោះទៅអ្នកយល់ជាក់ស្ដែងថា នាងត្រៀមខ្លួនចាំតែទទួលភារៈជាប្រពន្ធស្រេចទៅហើយ ។ ការសំអាត ការប៉ុនប្រសប់ ទឹកមុខរីករាយរបស់នាងកាមាលានៅពេលធ្វើការងារទាំងអម្បាលម៉ាន ធ្វើឲ្យក៏មេស្ហពេញចិត្តណាស់ទៅហើយ ប៉ុន្តែក្នុងការពេញចិត្តទាំងនេះ មានគំនិតមួយចេះតែមករំខានឲ្យអ្នកនឹកថា តើនាងនិងអ្នក នឹងទៅជាយ៉ាងម្ដេចទៅ ទៅថ្ងៃមុខទៀត ? តើអ្នកត្រូវទុកឲ្យនាងនៅជាមួយរហូត ឬឲ្យនាងត្រឡប់ទៅវិញ?

គិតសព្វ ៗ ទៅឃើញថាផ្លូវទាំងពីរនេះ ចេញផ្លូវណាក៏មិនរួច ៗ បើដូច្នេះ តើនឹងត្រូវកំរិតការទាក់ទងនឹងនាងកាមាលាត្រឹមណា ? បើប្រសិនជាមាននាងហិមណាលិទីមួយថែមមកទៀត បរិយាកាសដូចជាធូរស្រាលបន្តិច ចុះបើនាងមិននៅជាមួយផងយ៉ាងនេះ . . . ឃើញថាចេញអំពីបញ្ហាទ្វេនេះមិនរួចតែម្ដង ៗ

នៅទីបំផុត អ្នកក៏សម្រេចចិត្តលែងការរក ចាំនិយាយការពិតប្រាប់នាងកាមាលាឲ្យអស់កុំឲ្យសាញាច្រើនទៀត ៗ

—☙☙—

## ភាគទី ២៣ និង ២៤

រសៀលជ្រេបន្តិច កប៉ាល់ទៅគៀងជាប់នៅកន្លែងកោះខ្សាច់មួយ ទោះជាកម្មករកប៉ាល់ខំរុញច្រានយ៉ាងណា ក៏នៅតែមិនរួចសោះ ព្រះអាទិត្យអស្តង្គតទៅហើយ កប៉ាល់នៅតែគៀងចន្លុងដដែល ៗ មើលទៅមាត់ច្រាំង មានឆ្នេរខ្សាច់ដុះតាំងពីស្នាមជាំដែលទឹកជន់ដល់ កាលពីរដូវវស្សា ទេរជំរាលចុះជាលំដាប់រហូតដល់មាត់ទឹក ៗ

ក្រមុំ ៗ នៅភូមិក្បែរមាត់ច្រាំង ដែលនាំគ្នាដើរទាំងហ្វូងមកដងទឹកយកទៅប្រើប្រាស់ កុំឲ្យយប់ងងឹតទាន់ នាំគ្នាឈរមើលកប៉ាល់គៀងរញង់ នាងខ្លះខ្មាសអៀនច្រើន មិនដោះក្រមាចេញពីក្បាលទេ នាងខ្លះបែបមិនសូវអៀន ហ៊ានឈរមើលគេដោយនៅមុខកណ្ដាលវាល ៗ

កុមារតូច ៗ នាំគ្នាលោតកញ្ឆោងស្រែកចំអកឲ្យកប៉ាល់ដែលវាធ្លាប់តែឃើញបើកយ៉ាងក្រអឹតហើយឥឡូវនេះទៅជាគៀងជាប់ច្រាំង ៗ

ក៉ាមេស្ហឈរច្រត់លើក្ដាក់ដែកប៉ាល់ មើលព្រះអាទិត្យអស្ដង្គតដែលលិចបាត់ នៅតែរស្មីក្រហមឆ្អៅ នាងកាមាលាចេញមកឈរនៅមាត់ទ្វារបន្ទប់ ហើយធ្វើជាក្អកដើម្បីឲ្យក៉ាមេស្ហងាក តែក៉ាមេស្ហមិនងាកសោះ នាងក៏ចេះតែធ្វើអ៊ីចេះ-អ៊ីចុះ បន្តិចអង្រួនសោ បន្តិចធ្វើនោះ ទាល់តែក៉ាមេស្ហឮហើយក៏ដើរតម្រង់មកនាង ៗ

- ចង់ហៅខ្ញុំធ្វើអីចឹងឬ កាមាលា ?

- ចា៎ ព្រោះខ្ញុំមិនដឹងធ្វើម្ដេច ក្រៅពីនេះ ៗ

- យី កាមាលាឪពុកម្ដាយខ្ញុំបានឲ្យឈ្មោះខ្ញុំក្រែងសម្រាប់ឲ្យគេហៅឬ ? ចុះបើនាងត្រូវការខ្ញុំ ម្ដេចក៏មិនហៅ "នៃ ក៉ាមេស្ហ-បាប៊ូ" ទៅ ?

គ្រាន់តែក៉ាមេស្ហ និយាយចំអន់បែបនេះភ្លាម នាងឡើងមុខក្រហមផ្លឹមបានទឹងរស្មីព្រះអាទិត្យ ដែលកំពុងតែសន្សឹមចុះ ៗ ដែលពួកស្រីឥណ្ឌាណាហៅប្ដីចំឈ្មោះឬទេ ? នាងស្អប់ណាស់ពាក្យនិយាយលេងបែបនេះ នាងដើរចូលក្នុងបណ្ដើរនិយាយបណ្ដើរថា :

- "បងអញ្ជើញទៅពិសាបាយទៅល្ងាចហើយ ៗ

ខ្យល់ត្រជាក់ចក់ចេញពីផ្ទៃទន្លេ ធ្វើឲ្យក៉ាមេស្ហឆ្ងាញ់អាហារណាស់ តែអ្នកមិនហ៊ានបញ្ចេញវោហារប្រាប់នាងកាមាលាទេ ដើម្បីកុំឲ្យនាងទំធ្វើអស់កម្លាំងដោយសារតែអ្នកណាមួយប៉ុណ្ណោះណាមួយនៅលើកប៉ាល់គ្មាន

សម្ភារៈគ្រប់គ្រាន់នឹងរៀបចំអាហារឲ្យបានឆ្ងាញ់ផង ៗ មនោសញ្ចេតនាមួយយ៉ាងសាំញ៉ាំផុសចេញអំពីគំនិតអ្នក ព្រោះថាពិតមែនហើយ តែអ្នកសប្បាយចិត្តនឹងបានអាហារឆ្ងាញ់ ដើម្បីសម្រន់ការស្រេកឃ្លានរបស់អ្នក ប៉ុន្តែលុះនឹកឃើញថាមានមនុស្សម្នាក់ខំយកចិត្តទុកដាក់ ដើម្បីឲ្យអ្នកស្ថិតនៅក្នុងសុខុមាលភាពបែបនេះ ធ្វើឲ្យអ្នកស្រពោនចិត្តពេក ព្រោះអ្នកមិនសមបើនឹងឲ្យនាងបំរើអ្នកដល់ប៉ុណ្ណឹងសោះ ធ្វើដូច្នេះហាក់ដូចជាបោកបញ្ឆោតនាង ៗ នឹកហើយអ្នកដកដង្ហើមធំ នាងកាមាលាយល់ទាន់ក៏សួរភ្លាមថា :

- បងមិនទាន់ចង់ពិសាបាយនៅឡើយទេឬ ?

ក៉ាមេស្ហឮដូច្នេះខំធ្វើទឹកមុខរីករាយភ្លាម ហើយឆ្លើយតប :

- មិនមែននាងទេដែលហៅខ្ញុំឲ្យចូលមកនេះ គឺពោះខ្ញុំទេតើ ប៉ុន្តែមានអីញ៉ាំនៅទីនេះ មានតែតុ កៅអី ខ្ញុំទំពារម្តេចបែក ៗ

នាងកាមាលាផ្ទុះសំណើចយ៉ាងខ្លាំង ក៉ាមេស្ហសើចតាមដែរ ៗ នាងចូលទៅក្នុងបន្ទប់ជិតនោះ បន្តិចនាងចេញមកវិញបានទាំងចានមួយគ្របដោយស្លឹកស្រស់មកផង នាងដាក់នៅលើកូនព្រំមួយតូច ជិតជើងគ្រែនាងយកជាយសំពត់នាងជូតក្តារក្រាលនៅជិតនោះថែមទៀត ហើយនិយាយបណ្តើរថា :

- ណ្ហើយយកសំពត់ខ្ញុំជូតសិនចុះ ព្រោះខ្ញុំត្រូវផ្លាស់ល្ងាចនេះដែរ ៗ

នាងបើកគ្របស្លឹក យកនំបៀនទិងបន្លែពីក្នុងចានដាក់ឲ្យក៉ាមេស្ហ

បរិភោគ

- នាងបាននំពីណាមក ?

នាងមិនឆ្លើយភ្លាមទេ ទុកឲ្យក៏មេស្ហទាយសិន ។

ក៏មេស្ហនិយាយបន្ថែមទៀត ៖

-ប្រហែលជាព្រះអាទិទេពដែលបំរើចង្កៀងរបស់អាឡាដាំងaladin លោកផ្ញើនំនេះមកឲ្យខ្ញុំពីបាល្ល័ស៊ុល្តង់មកៈទេដឹង បានជានៅក្តៅ ៗ ។

នាងកាមាលាធុញទ្រាន់ការនិយាយលេងប៉ប្រែ គឺនិយាយកាត់ :

— កុំចេះតែនិយាយតាមតែនឹកឃើញនោះបង !

— បើអីចឹង បងគិតកាត់អណ្ដាតបងឲ្យឆ្កែស៊ីហើយ ព្រោះអណ្ដាតនេះវាចេះតែឲ្យបងនិយាយផ្ដេសផ្ដាសមិនដឹងគេខឹង ។

ការពិត គឺនៅពេលកប៉ាល់ចូលផែមុនពេលជាប់គៀងនោះ នាង-កាមាលា សល់ប្រាក់បន្តិចបន្តួចទីងខ្លួន បានប្រើអ៊ុយមេស្ហឲ្យទៅទិញម្សៅនិង ប៊ើរ ខ្លះមកទុកបំរុងធ្វើម្ហូបញ៉ាំតាមផ្លូវទេ ។

នាងសួរទៅ អ៊ុយមេស្ហ ដែលមិនទាន់បានអ្វីបរិភោគនៅឡើយ ។

- ចុះឯងបានអីញ៉ាំ អ៊ុយមេស្ហ ?

- បាទម៉ែ ឲ្យខ្ញុំសុំលុយខ្លះមក ចាំខ្ញុំទៅសុំបែកទឹកដោះគោគេ យើងមាននៅសល់ចេកនិងបាយខ្លះដែរ ប៉ុណ្ណឹងបានហើយ ។

នាងកាមាលាអស់លុយរលីង !

- ចុះឯងគ្មានលុយទេ អ៊ុយមេស្ហ ?

— គ្មានសោះទេម៉ែ ។

ស្ងាប់ហើយ! វាធំហើយ! នាងមិនចង់ហាមាត់សុំអ្វីពីក៉ាមេស្ហសោះ នាងទ្រឹងគិតមួយសន្ទុះ ទើបនិយាយទៅកាន់ក្មេង ៖

— ណ្ហើយចុះ បើទុកជាឯងមិនបានទំទឹកដោះគោឥឡូវ ក៏មានទំនៀនដែរ មក! ទៅជួយលាយម្សៅម៉ែបន្តិច ហើយបើកាលណាឯងឃើញលោកប្រុសឯងចូលមកពីសាបាយ សិមឯងទៅសុំលុយលោកវិញ ។

នៅពេលដែលក៉ាមេស្ហបរិភោគអាហារ អ៊ុយមេស្ហក៏ទៅឈរក្បែរនោះវាចាំឲ្យតែលោកមើលមកវាចំ វានិយាយតិច ៗ អេះក្បាលបណ្តើរ ៖

— ម៉ែឯណាលុយទៅផ្សារ ?

ឮពាក្យថាលុយ ក៉ាមេស្ហហាក់ដូចជាភ្ញាក់ព្រើត

មែនហើយ! បើមនុស្សត្រូវការអាហារ ក៏ពិតជាត្រូវចំណាយប្រាក់ដែរ ព្រោះគេគ្មានបង្គៀនទិញឯណា? ទើបអ្នកនឹកឃើញថាកាលបើប្រគល់ភារៈមេផ្ទះទៅឲ្យនាងកាមាលា អ្នកក៏ត្រូវប្រគល់ប្រាក់កាសឲ្យនាងដែរ ទើបនាងអាចចាត់ការបានតាមនាទីរបស់នាង គិតហើយ ទើបក៉ាមេស្ហយកសំពៀតប្រាក់ប្រគល់ទៅឲ្យនាង ។ លុះបរិភោគរួចហើយ ក៉ាមេស្ហក៏ចេញទៅក្រៅវិញ ។

អ៊ុយមេស្ហបាននំមួយដុំ គ្រាន់តែឃើញវាបរិភោគគួរឲ្យឆ្ងាញ់ នាងកាមាលាឈរនៅជិតវា ហើយសាកសួរអំពីរឿងរ៉ាវផ្សេង ៗ របស់វាតាំង

ពីមុនមក អ៊ុយមេស្ហនិយាយប្រាប់នាងថា វាត្រាំរស់នៅជាមួយម្តាយចុង វាមិនបាន ទើបវាលួចរត់មកនេះ ដើម្បីទៅរកសាច់ញាតិខាងម្តាយវានៅ ឯក្រុងបេណារេស មុននឹងបញ្ចប់វានិយាយទៅនាងកាមាលាថា :

— បើម៉ែអនុញ្ញាតឲ្យខ្ញុំនៅជាមួយម៉ែរហូតទៅ ខ្ញុំសប្បាយរកអ្វីប្រៀប ពុំបានឡើយ ។

ឮសំដីក្មេងកំសត់និយាយដូច្នោះ ថែមទាំងហៅនាងថា ម៉ែ ម៉ែ យ៉ាងស្និត ហាក់ដូចជាដាស់សភាវគតិនាងជាមាតា នាងនឹកអាសូរក្មេងកំព្រាណាស់ក៏និយាយឲ្យវាមានការកក់ក្តៅបន្តិចថា:

— ចុះឯងចង់ទៅណាទៀត ? ហើយមានអ្នកណាគេដេញឯង ? ។

(នៅមានត)

# រាត្រីចតុម្មុខ

សហ. ញូង-សៀង រៀបរៀង

## ពាក្យ ៧

៙ ទិនករគោចរចុះទន់ទាប
ទៅតាមសភាពលោកធម្មតា
បន្ទឹមលាក់ខ្លួនពួកអាត្មា
នាទិសបច្ចិមាពេលរស្មី ។
ក្រហមព្រឿង ៗ លឿងចម្រុះ
ចែងចាំងផ្លាស់ផ្ទុះលើផែនដី
ក្រាលពាសធម្មជាតិស្រទន់ខ្ចី
ព័ណ៌ចិត្រពិសីកាត់ដើងមេឃ ។
លាលឹបលិចចុះសន្សឹមទៅ
មនុស្សសត្វដែលនៅពេញតម្រេក
ស្រងូតស្រងាត់ស្ងប់ស្ងាត់ពេក
វិវេកតឹងតុះស្អុះស្អាប់ប្រាណ ។
វេលាជាសខ្មៅងងឹតឈប់
បិទបាំងពិភពគ្រប់ដែនដាន
ដល់វេនត្រីដណ្ដើមបាន
តាមដោយលំអានជាលំដាប់ ។
ព្រះពាយផាយផាត់កាត់ទៅមក
ចក់រុញពពកពពូនអ័ព្ទ
ខ្មៅកកងងឹតជិតខានខាប់
ព្រានចេញប្រញាប់ឲ្យឃ្លាតឆ្ងាយ ។
អាកាសស្រឡះស្អាតសំខាន់
ព្រះច័ន្ទរះភ្លឺតភ្លឺត្រឆាយ
រស្មីស្រអែតបាំងសព្វសាយ
ឯផ្កាយក៏រះបន្តគ្នា ។
ហោមជាបរិវារការពារពិត
ខ្លះនៅនែបនិត្យជិតចន្ទ្រា
ខ្លះនៅឃ្លាតឆ្ងាយផ្សាយអាកា
ព្រោងព្រាយលាយគ្នាចម្រុះញឹក ។
ពួកដែលស្លុតស្ងប់ថប់ធុញណាយ
បែរបានសប្បាយយ៉ាងពន្លឹក

ដោយសារពន្លឺភ្លឺអធិក ផ្ពួចទឹកចេញចរកែកំសាន្ត ៗ
គន់ផ្លៃទន្ទេបកុមុទ មឹកពេញបន្ទុកពន់ប្រមាណ
លិចអស់គោះត្រើយឥតសល់ខាន ហូរប្រហានក្ដួចប្រហល់កាល់មាត់ច្រាំងៗ
ត្រូវខ្យល់ជំនោរដោរបកមក កើតជារលករំជួយខ្ទាំង
ទូកតូចផ្ទង់ផ្ទោងអុំប្រណាំង តតាំងកាត់ទឹកនឹកភ័យក្រៃល ៗ
ផ្អែកផ្អត់លេកដូចពណ៌ប្រាក់ ផ្ទុក-ផ្ទុកឥតអាក់ហាក់ផេលផែល
ដោយប៉ះពន្លឺព្រះច័ន្ទផែល បែងចាំងឆ្នាត់ថ្លែលស្រស់ស្រទន់ៗ
ខាងឯអស៊ីយ៍ក្សត្រទិសបូព៌ា ប្រទីបផ្កាលាលទ្រោបលន់
បែហតាមមាត់ច្រាំងច្រើនពេកពន់ គយគន់គឺពួកនេសាទត្រី ៗ
ផាកខាងត្រើយជ្រោយបង្អា គ្រោងគ្រោតភ្លឺថ្លាដោយរស្មី
ចង្កៀងរៀងពយតាមវិថី ប្រុសស្រីដើរលេងលំហែកាយ ៗ
នៅខាងមាត់ច្រាំងដំណាក់ផែ នំនែកហូរហែលក់ចែកចាយ
ស្រីយួនខ្លួនស្អាតឡកនាយអាយ ប្រុស-ប្រុសសប្បាយទិញស៊ីលាន់ៗ
យូរ ៗ ឮសូរមាត់ខ្ទង់ស្រោក ស្រែកយំខ្វាក ៗ គួរភ័យក័ន្ត
គេនាំគ្នាដេរប្រទេចផ្ទាន់ រួសកន់ជាមួយសម្រែកក៏ ៗ
មេចោរហៅនហោបខ្ទោបចម្រុះ អន្តរធានចុះកុំយូរយារ
កុំហើរស្រែកយំទំរោក ឲ្យហាងវេទនាស្លាប់ក្សិណក្ស័យ ៗ
តាមចាប់បុកណ្ឌាបានជឿមក សត្វខេះមិនរកស៊ីពេលថ្ងៃ
រកស៊ីតែយប់គេចៃគ្រៃយ័ កែខែបង្អើចបំផ្លាញគេ ៗ

ថាក៏ជាពលនៃស្តេចខ្មោច ចង្រៃអសោចពីបុព្វេ
ស្តេចខ្មោចតែងប្រើហើរពេរ យកព្រលឹងគេសព្វគូមិឋាន ៗ
ខ្លះអើយខ្លះស្រាកលំបាកម្ល៉េះ រកស៊ីសោះអេះហើរហត់ប្រាណ
ត្រូវមាត់គេជេរឥតសល់ខាន កម្មអើយបានជាយ៉ាងហ្នឹង ៗ
កត្រើយប៉ុន្មានបន្តិចទៅ សែនចំនួសនៅច្បាស់រំតែង
ក្លិនសាយជាសពាសពេញទំហឹង ពិះយ៉ះបករ៉ឹងត្រជាក់កាយ ៗ
លើចុងអំពិលខាងមុខពាំង អស់ទាំងសត្វក្អែកបែកខ្ចាត់ខ្ចាយ
ខ្លះហើរចៀសចេញទៅទិសឆ្ងាយ ខ្លែកខ្លូកប្រញាយចិកឈ្មោះគ្នា ៗ
ដើមចមជម្ពោះទំនង់ជាក់ មួយដេកមួយក្ងាក់នាំពាធា
រង្គើមែកអញ្ចាញ់មហិមា ពះវាមិនដឹងគេដេកពួន ៗ
នៅលើដើមម៉ាស៊ីម៉ង់វែង ប្រុសស្រីផ្អែកជ្រែងសំដីលខ្លួន
ខ្លះប៉ះសង្សារទើបជួបជួន គេរេកៀវប្រជួនសប្បាយក្រៃ ៗ
អ្នកខ្លះឥតបានដើងម៉ាទេ ពឹងមាត់ទទេគ្រាន់អាស្រ័យ
អង្គុយសណ្ដូកទប់ជ្រែងដៃ មៀងមើលដលស័យកំសាន្តចិត្ត ៗ
ខ្លះខ្លាចក្រែងស្រីដោះគេចកែ ទំកួតស្បៀបស្បៃយកសុចរិត
ថាបើវៀចវេរក្បត់ផិត ហើយមិនអាណិតផលចរណៃ ៗ
នោះសូមព្រះអង្គជង់កើអើយ កាប់កបង្ក្ហើយឲ្យហិនហៃ
កុំឲ្យខ្ញុំឃើញពន្លឺថ្ងៃ ក្បៀណាក្បៀដដែលដោះរស់ក្បត់ស្រី ៗ
ខ្លះកៀកពេគ្នាឆ្ងាយពីគេ មិនដឹងរឿងរាវពីរឿងអី

តែស្មានមិនខុសប្រុសនិងស្រី
គ្មានអ្វីក្រៅផ្សេងពីការនឹង ។
ខ្លះទៀតផ្ទៀតក្រោមដើមអំពិល
ផងផឹតព្រិលៗ ឃើញខ្មៅស្រុង
ប្រឡែងប្រឡូសគួសព្រយុង
ពីព្រោះវៀងនុំងដៃមើលទៅ ។
អ្នកមានសង្សារសែនសប្បាយ
កៀកកេះក្អាកក្អាយ ទាល់យប់ជ្រៅ
ឯងអត់ក្រៀមផ្សះកេះតែះក្ដៅ
អ៊ូស៊ូនៅលេបទឹកមាត់ ។
មើលគេត្នឹះៗ ចង្គឹះចិត្ត
ព្រោះផ្សិតមានដៃតែប្រាសព្រាត់
ទុកម្នាក់ហ៊ាមកទាំងឃាត់
បំភ្លាត់ឲ្យឃ្លាងពីកល្យាណ ។
ទឹកសព្វៗ ទៅកាន់តែព្រួយ
ស្មើប្រេះលួយក្នុងសន្ដាន
ដល់ណាស់ជាណាស់ទ្រាំមិនបាន
ស្រែកព្រៀនកំសាន្តថាហាហៃ ។

## ពាក្យ ៩

តាំងពីចិត្តគិតពីចង់បង់ស្នេហា

លើដីកាំជាដីតែរមិត្តថ្ងៃ
ទៅមិនស្ងៀមរៀមមិនស្ងាត់បាត់អាល័យ
ហាក់ស្រមៃផ្ទៃស្រមោលពោលជិតប្រាណ ។
ពេលបងគេងលេងបងគងវង់លើខ្នើយ
ធ្លាប់បានតើយហើយបានកិតជិតកុំឃ្លាន
ធ្លាប់ប្រឡែងតែងប្រឡូកលូកស្មោះស្មាន
តែកំសាន្តបានកំសត់កត់កាលណោះ ។
ឥឡូវប្រែតែមិនប្រែបកបង្អូចចិត្ត

ខកខានស្និទ្ធខិតខានស្នេហ៍ថែរថែកស្មោះ
ឥតទឹកនាគ្នាទឹកនិត្យគិតស្រណោះ
ពុំគួរសោះដោះដៃស្ងួនឲ្យណាអូនទៅ ៗ
ប្រសិនប្រាណបានមកប្របកបវិញអេះ
រួមសំណេះកេះសំណាលកាលហួសទៅ
បងបីធោមដោមដុគ្គធើតទើតលើភ្លៅ
នាយប់ជ្រៅទៅយប់ជ្រុលពុលតណ្ហា ៗ
សែនតម្រេកត្រេកតម្រង់អង្គឥតអាក់
ពេញចិត្តស្ម័គ្របាក់ពិត្តស្មោះអស់ក្រឡា
កែក្រឡៃដៃក្រឡិចបិចក័ព្រា
នៃកល្យាណ៍ថ្វាកល្យាណឲ្យបានស្កប់ ៗ
ចាប់ក្រសាកែវក្រសោបឧបមាសផ្អិន
កៀកសង្កិនសិនសង្កត់បត់ប្រឡប់
ស្ទាបបះបាសកោសបវៃលអង្អែលសព្វ
រួចបញ្ចប់គប់បញ្ចើចសើចក្អាកក្អាយ ៗ
ឧបណ្ដូលមូលបណ្ដាច់សាច់ទ្រលន់
ពន់ល្វត់ល្វន់ទន់ល្វតស្វាសនិពសធ្វាយ
បើជាពោះទៅជាពិតដិតពន់កាយ
រៀបស៊ីបាយកាយស៊ីចេញដេញតាមសួន ៗ

តែនេះផុតសុខនេះផុងប្រុងមិនកើត

ព្រោះឆោមឆើតស្អើតឆោមឆាយផាយបាត់ខ្លួន

គ្មានដំណឹងដឹងដំណាលកាលនឹមនួន

នៅស្រុកយួនពួនស្រុកយក្សស្នាក់ត្រង់ណា ។

នេះស្រឡាញ់តាញ់ស្រឡះប៉ះលើក្តៅ

សឹងសោកសៅម៉ៅសោកសាំរកាំផ្សា

នាំធុរធាបជាបធុរឆេះឧក

បង់អាសាណាអសោច៍ខ្លោចផ្សិតស្រី ។

ហេតុដូច្នេះអេះដូច្នឹងគួរប្រឹងខាត់

លះវិបត្តិកាត់វិបាកចាកលោកិយ

រៀនធម៌អាថ៌សារធម៌អាទ៌បាឋ៌បាលី

លាងចិត្តថ្មីបីដូចថ្មតទៅអឹយ ។

ញង-សៀង

" អត្ថបទនេះធ្លាប់បានចុះផ្សាយក្នុងទស្សនាវដ្តី មិត្តសាលាបាលី លេខ ៧ ឆ្នាំ ១៩៥០ "

ឯកសារ

# ប្រវត្តិភូមិ និង កោះនានា នៅខេត្តកោះកុង

ដោយ

ឧកញ៉ាប្រសើរលិខិត ម៉ែន-ខន់

ធ្វើការនៅទីចាត់ការគរុកោសល្យ ភ្នំពេញ

---

## ៤–ប្រវត្តិ វត្តពាមក្រសោប (វត្តសុវណ្ណកោគាទីបារាម)

អ្នកផ្តល់ពត៌មានគឺលោកគ្រូព្រះនាម ពុត-ផ្លូង ចៅអធិការវត្តពាមក្រសោប និង ការពិនិត្យផ្ទាល់ របស់អ្នកនិពន្ធ កាលពីថ្ងៃ ២២-២-៦៨ ។

វត្តពាមក្រសោប ហៅតាមផ្លូវការថា "វត្តសុវណ្ណកោគាទីបារាម" ។ វត្តនេះស្ថិតនៅត្រង់ក្បាលជ្រោយ ជាប់នឹងភូមិពាមក្រសោប ក្នុងសង្កាត់កោះកាពិ ស្រុកកោះកុង ខេត្តកោះកុង ។

វត្តនេះចាប់កសាងពីឆ្នាំ ១៩៤៧ មានលោកគ្រូ ព្រះនាម វេន-មុំ ជាអ្នកផ្តួចផ្តើម នឹងបានជាចៅអធិការ ។ ជាដំបូងមានតែរោងឧបោសថមួយ សង់អំពីឈើ ប្រក់ស្លឹក និងកុដិតូចមួយ កុដិបាយតូចមួយប៉ុណ្ណោះ លុះដល់មកឆ្នាំ ១៩៦១ ទើបរុះរើកសាងជាថ្មីទៀត ដែលមានសភាពមាំមួនជាងមុន គឺព្រះវិហារសង់អំពីឥដ្ឋប្រក់ស័ង្កសី ប៉ុន្តែពុំបានលើកទៀន

ឲ្យខ្ពស់ទេ ។ ក្រៅអំពីព្រះវិហារ មានកុដិធំ ១ សាលាសម្រាប់ធ្វើបុណ្យ ១ កុដិបាយ ១ ដែលសុទ្ធតែសង់អំពីឈើ ប្រក់ស័ង្កសី ។

នៅក្នុងទីធ្លាវត្តគាតខាងជើង មានសាលារៀន ១ គឺសាលាបឋមសិក្សាបំពេញវិជ្ជាពាមក្រសោបនោះឯង ។ នៅខាងជើងសាលារៀនបន្តពីព្រំវត្តទៅទៀត គឺភូមិពុទ្ធបរិស័ទដែលនៅអែបមាត់ព្រែក ។ នៅខាងកើតគឺដៃសមុទ្រ ខាងត្បូងលំហសមុទ្រ និងខាងលិចមានព្រៃលិចទឹកដែលដុះសុទ្ធតែដើមកោងកាង ។

នៅក្នុងវត្តក៏ដូចជាភូមិអ្នកស្រុកដែរ កាលណាដល់ពេលទឹកជោរ ត្រូវលិចទឹកមានជម្រៅពី ០ម២០ ទៅ ០ម៧០ កាលណាពេលទឹកនាច ត្រូវគោកវិញ ប៉ុន្តែមានកន្លែងខ្លះពុំអាចដើរបានទេ នៅសើមល្បៀចៗ ហើយមានកន្លែងខ្លះគោកមែនទែន គឺនៅខាងត្បូង ត្រង់ព្រះវិហារ និងនៅមុខកុដិលោក អាចឲ្យគ្រូនិងសិស្សធ្វៀតហាត់ប្រាណបានខាងវ៉ូឡីកីឡា ៗ ដូច្នេះ ការធ្វើដំណើរពីកុដិ ១ ទៅ កុដិ ១ និងពីសាលា ១ ទៅ សាលា ១ សុទ្ធតែមានស្ពានភ្ជាប់គ្នា រហូតដល់ភូមិអ្នកស្រុក ។

ចៅអធិការវត្តពាមក្រសោប ដែលមានជាលំដាប់ត ៗ គ្នា ចាប់តាំងពីកើតវត្តនេះមក មានដូចតទៅ គឺលោកគ្រូ វ៉ែន-ម៉ុម លោកគ្រូ វៀមតូច លោកគ្រូ វ៉ៃ-ថន លោកគ្រូ សម-វុន លោកគ្រូ ផាក់ ចាង (សុទ្ធតែចាកសិក្ខាបទ) លោកគ្រូ រតន៍-ជី និមន្តទៅធ្វើចៅអធិការវត្តកោះស្រឡៅ និងលោកគ្រូ ពុត-ឌួង ជាចៅអធិការបច្ចុប្បន្ន ។

សព្វថ្ងៃនេះ វត្តពាមក្រសោប មានព្រះសង្ឃ ៤ អង្គ គឺភិក្ខុ ២អង្គ សាមណេរ ២ អង្គ ដែលមានលោកគ្រូ ព្រះនាម ពុត ផូង ព្រះជន្ម៦៦ វស្សា ជាចៅអធិការ ។

## ៥- ចេតិយឃុនឆាង

តាមការពិនិត្យផ្ទាល់ដល់ទីកន្លែងរបស់អ្នកនិពន្ធ កាលពីថ្ងៃ ១៨-២-៦៨ ។
ម៉ែន ទន់

ចេតិយឃុនឆាង ស្ថិតនៅក្នុងស្រុកមណ្ឌលសីមា ខេត្តកោះកុង ទល់មុខក្រុងខេមរភូមិន្ទ នាត្រើយខាងលិច ។ ចេតិយនេះ ត្រូវបានគេកសាងលើផ្ទាំងសិលា ដូចជាកូនកោះមួយ នៅលើផ្ទៃទឹកនៃដៃសមុទ្រ ចម្ងាយ ប្រហែល ១០០ម. ពីមាត់ច្រាំង និងប្រហែល ៥០០ម ខាងទិសអគ្នេយ៍ នៃសាលាស្រុកមណ្ឌលសីមា ។

ផ្ទាំងសីលាដែលចេតិយស្ថិតនៅនោះ មានទំហំបណ្ដោយប្រហែល ២០ម និងទទឹងប្រហែល ១០ម- និងមានសភាពជាផែន ៗ ខ្ពស់-ទាប ត្រួតលើគ្នា ។

ទ្រនាប់ខ្សាច់នៃចេតិយ ៣ម. បួនជ្រុង ឯតួចេតិយ ចាប់ពីចង្កេះឡើងទៅលើមានរាងមូល-ស្រួច មានក្បាច់ព័ទ្ធជុំវិញជាថ្នាក់ ៗ បួនជាន់ និងមានកំពស់ប្រហែល ៥ម ។ តួចេតីយទាំងមូលកសាងពីឥដ្ឋ កំពូលបំផុតកសាងពីឈើ ។ ឥដ្ឋដែលកសាងនោះមានបណ្ដោយប្រហែល

០មៈ និងទទឹងប្រហែល ២៥ម ។ ខាងក្រៅមានបូកកំបោរពណ៌ស កំបោរនោះឃើញមានកំទេចសំបកលៀស-គ្រំ ដែលអាចឲ្យយល់បានថា គេយកសំបកលៀស-គ្រំទៅដុតធ្វើជាកំបោរ ដូចជាកំពែងស្រះសារពើយុគ្គ នៅឧដុង្គដែរ ។

តួចេតិយនៅល្អទាំងអស់ មានតែកំពូលដែលធ្វើអំពីឈើនោះទេ ដែលពុកបាក់ខ្លះទៅហើយ ។ នៅជើងចេតិយនិងចង្កេះចេតិយមានដើមជ្រៃលៀបដុះ ២ កន្លែងនៅតូចៗនៅឡើយ ប៉ុន្តែកំពុងតែចាក់ឫស និងបន្តត្រួយជានិច្ច ។ ក្រៅអំពីនេះ ឃើញមានស្មៅមានកន្ទុយមាន់ដុះនៅតាមកន្ទៀតតួចេតិយនិងមានស្លែខ្មៅៗ កាទ់ពាសពេញ ។

បើមើលពីចម្ងាយ គេឃើញចេតិយនោះហាក់ដូចជាជាប់នឹងផ្ទៃទឹក ប៉ុន្តែលុះចូលទៅជិត ទើបដឹងស្ថិតនៅលើផែនថ្មខ្ពស់ពីទឹកទៅវិញ ។ តាមជំនឿរបស់អ្នកស្រុកខ្លះ គេជំណាលថាចេតិយនេះពុះចេះលិចទឹកទេ ទោះបីមានទឹកជំនន់ធំយ៉ាងណាក៏ដោយ បើខ្លាំងណាស់លិចតែផែនថ្មខាងក្រោមប៉ុណ្ណោះ ។

# ៦ ប្រវត្តិចេតិយយុគរាង

អ្នកផ្តល់ពត៌មាន គឺលោក ទៀវ ចាន់ ស្មៀនសាលាសង្កាត់កោះកាពិ ដែលលោកបានដឹងដោយសារអ្នកស្រុកនៅភូមិនាងកុក ពីឆ្នាំ ១៩៥៩ ហើយ លោកផ្តល់ឲ្យអ្នកនិពន្ធនៅថ្ងៃ ២១-២-៦៨

តាំងពីយូរឆ្នាំណាស់មកហើយពុំដឹងជាសតវត្សទីប៉ុន្មាន និងពុំដឹងជាក្នុងរជ្ជកាលនៃព្រះមហាក្សត្រិយអង្គណា មានគ្រួសារមួយពីរនាក់ប្តីប្រពន្ធ មាននាមពុំប្រាកដ បានតាំងទីលំនៅ និងប្រកបរបរកសិកម្មក្នុងតំបន់មួយ នៅត្រើយខាងលិចនៃឈូងសមុទ្រ ទំនងជានៅខាងលិចសាលាស្រុកមណ្ឌលសេមាសព្វថ្ងៃ ។

គ្រួសារនេះមានធនធានគ្រាន់បើ ហើយជាអ្នកមានសទ្ធាផង ។ អ្នកនៅក្នុងភូមិជាមួយគាត់ក្តី នៅភូមិនាងកុកក្តី សុទ្ធស្រឡាញ់រាប់អានគាត់គ្រប់គ្នា ។ គាត់មានគុណសម្បត្តិពិសេសមួយទៀត គឺបើអ្នកភូមិជិតខាងដែលខ្វះលុយកាក់ឬស្រូវអង្ករ តែងតែរត់រកគាត់ហើយគាត់តែងផ្តល់ឲ្យឥតជ្រើសមុខ ។

នាពេលមួយគាត់ពិចារណារវាងប្តីប្រពន្ធ គិតឃើញថានៅដំបន់នេះមានមនុស្សរស់នៅក្រាស់ក្រែលដែរ ប៉ុន្តែពុំទាន់មានវត្តអារាមសម្រាប់ជាទីសក្ការៈបូជា និងធ្វើបុណ្យទានះ ហើយបើយើងកសាងជាវត្តក៏ដូចជាហួសសមត្ថភាព ដូច្នេះយើងត្រូវកសាងជាចេតិយមួយសម្រាប់ជាបូជនីយ [illegible] តាមគន្ធ

ព្រះពុទ្ធសាសនា ។ គំនិតដ៏ប្រសើរនេះបានយល់ស្របគ្នាទាំង ២ នាក់ប្តីប្រពន្ធ ហើយក៏ចាប់ជ្រើសរើសរកកន្លែងដែលត្រូវកសាងចេតិយ ។

ជាដំបូងគាត់បំរុងកសាងនៅលើដីគោកត្រង់កន្លែងណាមួយ ប៉ុន្តែដូចជាពុំសូវរុងរឿងហើយដូចជាគាត់ទើបឃើញដល់កូនកោះមួយ ដែលមានសុទ្ធតែដុំថ្មភ្រមគ្នា ។ គាត់គិតឃើញម៉្យាងទៀតថា នៅតំបន់នេះ ពួកស្រុកប្រកបមុខរបរខាងនេសាទក៏មាន ខាងស្រែ-ចំការក៏មាន ចំណែកទូក-សំពៅក៏មានស្ទើរតែគ្រប់គ្នា បើបានធ្វើចេតិយលើកូនកោះនេះ ហើយដល់ពេលធ្វើបុណ្យទានម្តងៗ នាំគ្នាធ្វើជាស្ពាន និងយកទូកសំពៅមកចតឲ្យពេញត្រៀបត្រា ឃើញថាមានសភាពរុងរឿង ហើយសប្បាយផង ។

លុះជ្រើសរើសឃើញថា ត្រូវយកទីនេះធ្វើជាកន្លែងកសាងហើយ គាត់ក៏ចាត់ការឲ្យរកជាង និងជុតកំបោរព្រមទាំងសម្ភារៈផ្សេងៗទៀត ។ ចំណែកញាតិមិត្តជិតខាងវិញ ក៏មានសទ្ធាជួយជាកម្លាំងកាយខ្លះ ជួយជាធនធានខ្លះក៏កសាងកើតបានជាចេតិយនេះឡើង ។

ចាប់តាំងពីពេលនោះមក ពុទ្ធបរិស័ទនៅភូមិជិតខាង ដូចជា នៅភូមិនាងកុក ភូមិចាំយាម ភូមិខាត់ព្រែក (ប៉ាកួង) កោះប៉ា ស្ទឹងវែងជាដើម បាននិមន្តព្រះសង្ឃមកប្រជុំគ្នាធ្វើបុណ្យនៅចេតិយនេះជារៀងរាល់រដូវ ។ ពិធីនេះមានសភាពរុងរឿងហើយសប្បាយណាស់ គេបានសង់ជាស្ពានពីដីគោកភ្ជាប់មកនឹងកូនកោះ ហើយនៅលើផ្ទៃទឹកវិញឃើញ

សុទ្ធតែទូក សំពៅ តម្រៀបគ្រៀបគ្រា ដោយមានពេលខ្លះគេអុំ និង បើកក្តោងប្រណាំងគ្នាជាការកំសាន្តផង ។

លុះចំណេរក្រោយមក នៅភូមិឯទៀត ៗ មានវត្តសម្រាប់ធ្វើបុណ្យ ផងដោយតាៗ ជំនាន់មុន ស្លាប់អស់ទៅហើយផង ការប្រជុំគ្នាធ្វើបុណ្យ នៅចេតិយនេះ ក៏រលាយបន្តិចម្តង ៗ រហូតដល់ខានធ្វើសោះ ដរាប ដល់សព្វថ្ងៃ ។

អ្នកផ្តល់ពត៌មានបានបញ្ជាក់ថា រឿងចេតិយនេះមានប្រវត្តិដូចខាង លើ ឯត្រង់មានឈ្មោះថា ចេតិយឃុនឆាងនោះ ពុំដឹងជាមានមកពីត្រឹម ណាទេ ប៉ុន្តែមានទិដ្ឋភាពមួយគួរឲ្យយកមកពិចារណាដែរ គឺនៅត្រើយ ខាងលិច ឃ្លាតពីសាលាស្រុកមណ្ឌលសេមាឆ្ងាយបន្តិចទៅមានដំណែល បុកណោមួយក្នុងភូមិដើងគ្រក់ ឃើញមានស្នាមដូចជាមនុស្សអុកគូថ ហើយ ថាស្នាមនោះ មានរឿងដំណាលដូចតទៅ ៖

ថាឃុនឆាង ជាកូនអ្នកមានសម្បត្តិច្រើន គាត់បានចាប់ចិត្តស្នេហា លើនារីម្នាក់ឈ្មោះនាងកិម ដែលមានរូបសម្បត្តិឥតពីរ ប៉ុន្តែនាងកិម ពុំ ស្រឡាញ់ឃុនឆាងទេ ព្រោះគាត់ក្បាលតំពែក ពោះកំប៉ោង ហើយព្រ-ហើន គឺស្រឡាញ់តែឃុនផែន ដែលជាសុភាពបុរស ។ ពេល ១ ត្រូវ ឃុនឆាង និងឃុនផែន ទាស់ប្រកួតគ្នា ដើម្បីបណ្តិតនាងកិម ដែលជាគូ ស្នេហារបស់ខ្លួនរៀងខ្លួន ប៉ុន្តែដោយសារស្មៀតរបស់ខ្លួនពុំសូវប៉ិន ឃុនឆាង ក៏គាត់ដើរពុកគូទទល់ផ្លូវធ្វើមាត់សេញ ធ្វើឲ្យនាងកិម និងទស្សនិកជន

សើចរីងពោះ ។ រីឯស្នាមដែលយុនធាង ដួលគុកគូទកាលណោះ ក៏គាំង

ក្រាំងរឹងទៅជាថ្មរហូតដល់សព្វថ្ងៃនេះ ។

## ៧–ប្រវត្តិកោះកាពិ

> អ្នកផ្តល់ពត៌មានគឺលោក តាន់-ឡឹក នាយតំបន់អធិការកិច្ចបឋមសិក្សា ស្រុកកោះកុង និងលោក ទាំ.ប៊ុនលឿ ចៅសង្កាត់កោះកាពិ ។ ក្រៅអំពីនេះ ដោយការពិនិត្យផ្ទាល់របស់អ្នកនិពន្ធ កាលពីថ្ងៃ ២១-២-៦៨ ។

ដែលបានឈ្មោះថា កោះកាពិ មកពីកោះនេះមានកំពឹសសមុទ្រ ច្រើន ដែលខ្មែរយើងខ្លះហៅថា គី សៀមហៅថាកាពិ ។ កាលពីដើម ពុំមានមនុស្សនៅទេ ប៉ុន្តែក្រោយមកមានខ្មែរ-ចិន ៣-៤ គ្រួសារមកនៅ ដោយប្រកបមុខរបរធ្វើកាពិ ហើយក៏ជាប់ឈ្មោះថា កោះកាពិ ៗ រហូត ដល់សព្វថ្ងៃ ។

កោះកាពិត្រូវចែកជា ២ ប្រភេទ គឺមួយប្រភេទជាដីភ្នំ មានបណ្តោយ ប្រហែល ៧០០ម ទទឹងប្រហែលជាង ១០០ ម.ស្ថិតនៅប៉ែកខាងជើងនៃ កោះ តាំងនៅទទឹងថ្ងៃ ។ មួយប្រភេទទៀតជាទីទំនាប គិតចាប់ពីជើង ភ្នំទៅជ្រោយគយ សៀមហៅ ខ្លែម ដាន គឺខ្លែម ថាជ្រោយ ដាន ថា គយ ក្លាយមកជា ឡាំ ដាំ មានបណ្តោយប្រហែលជាង ២ គ.ម និងទទឹង ប្រហែល ២០០ ម ស្ថិតនៅប៉ែកខាងត្បូងនៃកោះ ។ ខាងលិច គឺលំហរ សមុទ្រឃើញទឹកនិងមេឃហើយនៅខាងកើត គឺព្រៃនាម ដែលដុះស្ទុះ ដើមកោងកាងលាតសន្ធឹងបណ្តោយតាមឆ្នេរកោះ ។

ប៉ែកខាងជើងជាភ្នំមួយមានទំហំដូចខាងលើ ហើយមានវត្ត ១ ឈ្មោះវត្ត ប្រជុំជនក្រោយមកកែជាវត្ត សុវណ្ណបពិត ប៉ុន្តែគ្រាមភាសា ហៅថាវត្ត កោះកាពិ ។ នៅតាមជម្រាលភ្នំខាងជើងមានសាលាបឋមសិក្សាបំពេញវិជ្ជា មានមន្ទីរកងពលតម្រួត មានក្រុមគង្គា រុក្ខា និងនេសាទ មានសហករណ៍ខាងនេសាទ និងសាលាសង្កាត់កោះកាពិ ។ នៅតាមជើងភ្នំខាងកើត មានផ្សារលក់ដូរតាមផ្លូវ ២ ផ្លូវយ៉ាងវែង ដែលសង់អំពីឥដ្ឋ ប្រក់ក្បឿនខ្លះ និងឈើប្រក់ក្បឿង ឬស័ង្កសីខ្លះ ។ ក្រៅអំពីនេះមានផ្ទះ ២ ផ្លូវទៀតនៅតាមមាត់ព្រែក ដែលច្រើនតែសង់អំពីឈើប្រក់ស័ង្កសី និងឈើប្រក់ស្លឹក គឺជាផ្ទះអ្នកប្រកបរបរនេសាទ ។ ដទៃអំពីផ្ទះលក់ដូរ និងអ្នកនេសាទ នៅមានអ្នកប្រកបអាជីវកម្មឯកជន និងអគ្គាររដ្ឋផ្សេង ៗ នៅលាយឡំគ្នា ដូចជាឧសថស្ថានរង ការិយាល័យនាយដំបន់អធិការកិច្ចបឋមសិក្សា គិលានដ្ឋាន សហករណ៍ឧបភោគបរិភោគ ក្រុមព្រះនគរបាលជាតិ ពេនភាពយន្ត ដំណាងក្រុមហ៊ុន ណាំ.លឿង នៅសិង្ហបុរីខាងការទិញត្រី ប្រឡាក់ត្រី កន្លែងធ្វើក្តាមប្រៃ កន្លែងធ្វើត្រីងៀត កន្លែងធ្វើទឹកត្រី និងធ្វើកាពិ ។

នៅភាគខាងត្បូងមានសាលាស្រុកកោះកុង , មានបន្ទាយកងពលតម្រួត , បន្ទាយផ្នែកសិការង និងបន្ទាយកងនាវាចរ នៅជ្រោយគយ (ឡាំដាំ) ។

ប្រជាពលរដ្ឋនៅកោះកាពិ ១៣២ គ្រួសារ ហើយប្រកបមុខរបរសំខាន់

បំផុតគឺការនេសាទបន្ទាប់មកគឺការលក់ដូរ ប៉ុន្តែពុំមានប្រកបមុខរបរកសិកម្មទេ ។ នៅក្នុងភូមិមានតែដើមដូងនិងដំណាំស៊ីផ្លែបន្តិចបន្តួចដូចជា : ដម្លូង មៀន ត្របែក ទឹកដោះគោ ។

ចំណែកភាសាវិញ គេប្រើភាសាខ្មែរ តែគេចេះចិនហៃណាំ និងសៀម ប៉ុន្តែភាសាទាំងនោះពុំសូវជាច្បាស់លាស់ទេ គឺច្រើនប៉ែឡាំ តាមរបៀបអ្នករស់នៅដោយជាយដែន ។ ចំពោះក្មេងៗជំនាន់ក្រោយវិញពុំចេះភាសាសៀមនិងចិនទេ ហើយអាចនិយាយភាសាខ្មែរយ៉ាងច្បាស់លាស់ដោយមកពីការអប់រំនៃក្រសួងអប់រំជាតិ តាមវិធីបង្រៀនសិស្សសាលាធម្មតាផង តាមវិធីអក្ខរកម្មផង ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះប្រមុខរដ្ឋ និងជាព្រះប្រធាននៃចលនាសង្គមរាស្ត្រនិយម ។

ផ្នែកខាងជំនឿ គេគោរពព្រះពុទ្ធសាសនា ប៉ុន្តែមានគេជឿវត្ថុសក្តិសិទ្ធិទៀតដែរ ដូចជាយាយមៅត្របញ្ញាទរូប និងទេសទ្រទាយ ។

ជីវភាពពលរដ្ឋច្រើនធូរធារគ្រាន់បើ ពុំមានបញ្ហាខ្វះខាតជំពាក់ជំពិនគាបង្កការគ្នាតាមរបៀប ៤ ជា ៦ និង ១០ ជា ១៦ ឡើយ ហើយស្ទើរតែគ្រប់ផ្ទះគេពុំរវល់ពីរឿងបិទទ្វារ-បង្អួចទេ មានផ្ទះខ្លះពុំមានទ្វារ-បង្អួចនោះផង ព្រោះគេពុំដែលទទួលគ្រោះថ្នាក់អំពើចោរកម្ម ។

រីឯសំលៀកបំពាក់វិញ មិនខុសអំពីប្រជាពលរដ្ឋក្នុងខេត្តឯទៀតៗ នៅជិតកង់ឆាងទេ គឺពេលធ្វើការគេស្លៀកពាក់តាមតែបាន ប៉ុន្តែនៅពេលមានបុណ្យទាន គេស្លៀកពាក់ខ្មៅ ហើយច្រើនតែរបស់

មានតម្លៃខ្ពង់ ។ ចំណែកស្រូវច្រើនប្រើឆត្រ និងតាំងយូព្រោះស្រុកនោះសម្បូណ៌ភ្លៀង ។ ចំពោះម្ហូបអាហារសោត ត្រូវការប្រើម្ទេសជាចាំបាច់ តាំងពីមនុស្សចាស់រហូតដល់កូនក្មេង ទាំងប្រុស ទាំងស្រី គឺសម្លក្ដី ទឹកជ្រលក់ក្ដី គេដាក់ម្ទេសយ៉ាងចាស់ដៃជាទីបំផុត ។

នៅកោះកាពិមានវិបត្តិមួយ ដែលពិបាកដោះស្រាយ គឺការខ្វះទឹកសាបទទួលទាន ។ ទឹកដែលគេប្រើប្រាស់ ត្រូវដឹកនាំតាំងពីកោះកុង ឬកោះស្រឡៅ ឬគេត្រងដាក់ពាងនៅពេលមានភ្លៀង ។

# ប្រវត្តិ " ភូមិក្បាលអ្នក "

## ឬ

## " ភូមិ ប៉ូអង់ "

មុននឹងខ្ញុំជូនប្រវត្តិ " ភូមិក្បាលអ្នក ឬ ភូមិប៉ូអង់ " នេះ ខ្ញុំចង់ឲ្យលោកអ្នកស្គាល់ភូមិ "ប៉ាលហាល" សិន ។

នៅចម្ងាយ ៤ គ.ម ពីកំពង់ប្រណាកទិសខាងត្បូង មានភូមិមួយឈ្មោះថា "ភូមិប៉ាលហាល" ដែលតាំងនៅក្នុងឃុំព្រះឃ្លាំងស្រុករវៀងខេត្តព្រះវិហារសព្វថ្ងៃ ។ ភូមិនេះមានផ្ទះប្រហែលជា ៧០ ខ្នង ដែលមានមនុស្សប្រុស-ស្រី វាង ២០០ នាក់សំណាក់នៅ ។ ជាភូមិនៃកុលសម្ពន្ធមួយពួកដែលខ្មែរយើងទម្លាប់ហៅ "កួយ"(១) កួយនៅភូមិប៉ាលហាលនេះជាពួកកួយអន្ទ្រ័ ។

តាមលោកតាលាស់-ឃួន គាត់ជាកួយអន្ទ្រ័ ប្រាប់ខ្ញុំថា : ដំបូងឡើយពុំទាន់មានភូមិប៉ាលហាលហ្នឹងនៅឡើយទេ គឺមានភូមិមួយតាំងនៅខាងជើងភូមិហ្នឹងហៅថា " ភូមិកេងកំ " ។ ភូមិកេងកំនេះដំបូងបង្អស់មានតាចាស់ប្ដីប្រពន្ធគាត់ពីរនាក់ គាត់កាប់គាស់ហែកព្រៃនេះធ្វើជាចំការ មានដាំដំឡូង-ចេក-កំពៅ សព្វសារពើសម្រាប់ផ្គត់ផ្គង់ជីវិតគាត់ តែដោយហេតុមានខ្លាដំរីចេះតែមក ធានៅបៀតបៀនដំណាំគាត់ជាញឹកញាប់ពេក

---

(១) ក្នុងខេត្តព្រះវិហារ មានកួយចំនួន ៤ សាសន៍គឺ ១ កួយអន្ទ្រ័, ២ កួយមេអក, ៣ កួយម៉ាំអៃ, ៤ កួយបាន់ត្រើ ។

ហើយគាត់ក៏ខ្លាចផងដែរ គាត់ក៏នាំយាយសង់រោងមួយយ៉ាងខ្ពស់ចំកណ្ដាល ចំការនេះឡើង ដើម្បីស្រណុកមើលជុំវិញចំការគាត់ ។

លុះក្រោយមកមានអ្នកភូមិខ្លះដើរទៅដើរមកចុះឡើង ឃើញរោងតានេះ ខ្យល់យោលយោកឡើងចុះដូចគេកំក៏សន្ទូតហៅថា ភូមិរោងកំរហូតមក ។ ភូមិរោងកំនេះ តាមដំណាលថា : មានមនុស្សគុះគរច្រើនណាស់សំណាក់ នៅ តែថ្ងៃក្រោយមកមានអាសន្នរោគកើតម្ដង ក៏បណ្ដាលឲ្យស្លាប់មនុស្ស អស់ជាច្រើនក្នុងភូមិទាំង ក្មេង ទាំងចាស់ ព្រមជាមួយនឹងអាសន្នរោគនោះ មានអព្ភូតហេតុមួយកើតឡើងទៀត ដែលពាក្យក្លួយហៅថា "ឡូតកឹន" ប្រែជាខ្មែរ "ព្រះធរណីស្រុត" គឺស្រុតនៅកណ្ដាលភូមិមួយកន្លែងដែល ទឹកហូរធ្លាក់ចុះ មិនដឹងជាទៅពីទីណា ។

ហេតុដូចខាងលើនេះហើយដែលអ្នកភូមិយល់ថាជាភូមិចង្រៃឧត្បាទ មនុស្សនៅចេះតែស្លាប់បន្តៗគ្នា ទើបយប់មួយប្រហែលរំលងអធ្រាត្រ មានចាស់ម្នាក់នៅក្នុងភូមិក្រោកឡើងដុតចន្លុះដាស់គ្នា ប្រជុំហើយរត់ ចេញពីភូមិរោងកំនេះទាំងយប់ ឆ្ពោះទៅរកកន្លែងមួយដែលនៅជុំវិញសុទ្ធ តែត្រពាំង ចម្ងាយពីភូមិរោងកំជាប់ ២ គ.ម. ។

ការដែលនាំគ្នារត់មកតាំងភូមិករថ្មីនេះ ពិតមែនតែអាសន្នរោគមិន តាមមកយាយី ហើយមនុស្សក៏ពុំមានស្លាប់ដូចភូមិចាស់ក៏ទេដែរ តែទាំង អស់គ្នាមានទឹកមុខស្រពាប់ស្រពោនជានិច្ច ជួនកាលក៏ស្រក់ទឹកភ្នែកស្រែក យំសោកសង្រេងព្រោះអាល័យប្ដី-បង-ប្អូន-កូនសំឡាញ់ ដែលស្លាប់

ដោយអាសន្នពេកថ្មី ៗ នេះ ។ ការអាឡោះអាល័យគ្រួសារនេះឯងដែលអ្នកភូមិគេសន្មតឲ្យឈ្មោះភូមិគេថា " ភូមិហេលហាល " ជាភាសាកួយអន្ទីរ ប្រែជាខ្មែរថា "ភូមិអាឡោះអាល័យ" ។

លុះចំណេរក្រោយមកអ្នកភូមិថ្មីនេះ ក៏បានសេចក្ដីសុខសាន្តរហូតពុំមានឧបសគ្គអ្វីឡើយ មានអន្ករត្រីសាច់ បរិភោគហូរហៀរដោយអាស្រ័យមានត្រពាំង ៣ ជុំវិញភូមិ គឺ ត្រពាំងម្រះ ត្រពាំងចិក ដែលខ្មែរប្រែថា: ត្រពាំងកំង និងត្រពាំងមួយទៀតហៅថា: "ដាកត្រែត" ប្រែថា " ត្រពាំងទឹកត្រជាក់" នៅក្បែរភូមិផង ហើយដែលគេជឿជាក់ថាជាភូមិត្រជាក់ត្រជុំផងនោះ ទើបមានអ្នកចំណូលថ្មី ៣ ភូមិទៀតមកសុំនៅជាមួយ "ភូមិហេលហាល" គឺភូមិអន្ទៃ ១ ភូមិខ្វង់ព័រ ១ និងភូមិ "ប៉ូអង់"១ "ភូមិប៉ូអង់" នេះជាភាសាកួយអន្ទីរ ដែលបកមកជាខ្មែរប្រែថា "ភូមិក្បាលអ្នក ,, ។

ភូមិនេះមានរឿងនិទានបរម្បរា ៗ គ្នាមកថា ៖

" មានថ្ងៃមួយកួយអន្ទីរពីរនាក់ បងថ្លៃ-ប្អូនថ្លៃ (គឺបងថ្លៃប្រុស ប្អូនថ្លៃស្រីក្រមុំ) ដោយនៅផ្ទះពុំមានត្រីបរិភោគក៏នាំបងប្អូនជិះទូកទៅបង់សំណាញ់នៅអន្លង់មួយនាស្ទឹងកំពង់ត្រណាកសព្វថ្ងៃនេះ ។ លុះបង់សំណាញ់ទៅសំណាញ់ក៏ពារទៅលើសាកសល់ឈើក្នុងទឹក ជាប់ជំពាក់ទាញមកវិញមិនរួច ទើបហៅប្អូនថ្លៃឲ្យមកអង្គុយលើក្បាលទូកចាំចាប់ទាញខ្សែសំណាញ់ឯខ្លួនឯងក៏ចុះទៅបុជដោះ សំណាញ់កង់ទឹកយយសន្ទះក្រោយមក ដោះ

ពុំទាន់ហើយនៅឡើយទេ តែថប់ដង្ហើមពេក ក៏ងើបផុសមកគោងក្បាលទូក វិញ និមិត្តតែយកដៃជូតមុខហើយបើកភ្នែកភ្លាម ក៏ប្រទះឃើញគ្រឿងសំខាន់ (យោនី) របស់ប្អូនថ្លៃលេចចេញមកក្រៅសំពត់ដែលសាមីខ្លួនគ្នាពុំបានដឹងខ្លួនផង ៗ ពេលនោះនាយយើងពិនិត្យច្បាស់ហើយ លេបទឹកមាត់ក្អឹក មុជក្បាលទៅវិញហើយគិតថា: " អញអស់បងអស់ប្អូនហើយពេលនេះ ,, ធ្វើឧបាយកលយ៉ាងណាឲ្យតែបានធីប្អូនថ្លៃអញ បុរសកំហូចនេះ គិតហើយក៏លើកជើងសំណាញ់ឲ្យត្រីចេញអស់ ហើយងើបផុសឡើងនិយាយថា: ហ៊ឹះ ត្រីសម្បូណ៌ដល់ហើយមេនាង ប៉ុន្តែឈើច្រើនពេក ណ្ហើយយើងទៅរកបង់កន្លែងផ្សេងទៀតទៅ ... ថាហើយនាងក្រមុំក៏ក្រោកទាញប្រវែរ សន្សឹម ៗ ទៅមុខរីឯបងថ្លៃក៏ដំរៀបសំណាញ់ហើយគ្រវាត់ទៅម្តងទៀត ហើយវាធ្វើជាជាប់សំណាញ់រួចវាចុះទៅលើកជើងសំណាញ់ ឲ្យត្រីចេញអស់លើងដូចមុនទៀត ៗ អង្គិតនេះបានធ្វើរបៀបដូចខាងលើនេះជាច្រើនលើកច្រើនគ្រា ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ៗ ម៉្លោះហើយ ១ ថ្ងៃនេះពុំបានត្រីទាល់តែសោះ លុះល្ងាចក៏នាំប្អូនថ្លៃទៅផ្ទះវិញ ៗ

លុះព្រហាមស្រាងឡើង បងថ្លៃ ក៏បាននិយាយទៅកាន់ប្អូនថ្លៃថា យប់មិញ បងដេក ទៅយល់សប្តិ ឃើញអ្នកតាព្រះព្រៃមកប្រាប់ថា "បើបង់បានត្រីក្នុងអន្លង់នោះ លុះណាតែមេនាងឯងយកទៀនធូប ទៅបន់ស្រន់លោកតាបានលោកតាឲ្យ" ៗ

– បន់នៅឯណាអក ! ( ប្អូនថ្លៃនិយាយ )

- ណ្ហើះ ! អ្នកតាព្រះព្រៃជ្រ ហ្នឹះក្បែរអន្ទង់យើងបង់នោះ ។ ពេលនោះប្អូនថ្លៃក៏បានធ្វើតាមពាក្យដែលបងថ្លៃប្រាប់ ។

ក្នុងខណៈដែលនាងកាន់ទៀនធូបដើរតម្រង់ទៅអ្នកតាព្រះព្រៃជ្រ អន្ទិតយើងក៏ដើរតេចតូចទៅនៅចាំបន្ទុំក្រោមខ្នងអ្នកតាដែរ ។ លុះនាងទៅដល់ហើយក៏ចាប់ដុតទៀនធូបផ្កាយរួចហើយ លើកដៃថ្វាយបង្គំ៣ដង និយាយបន់ថាៈ សុំលោកតាអត់ទោសឲ្យកូនទៅផងចុះ, ពីលើកមុនមិនបានសុំ ឥឡូវសុំឲ្យលោកតាអាណិតជួយទៅ ឲ្យបង់បានខ្ញុំផងពីត្រឹមថ្ងៃនេះតទៅសុំកុំឲ្យប្រកាន់ទោសអ្វីសជំណើរអី ។ ថាហើយអ្នកតាក៏ឆ្លើយតបយ៉ាងគ្រលរមកវិញថាៈ "មិនបានទេចៅស្រី បើចៅចង់បានគ្រឺចៅឯងត្រូវរួមរស់ជាមួយនឹងបងថ្លៃចៅឯងចុះ ចៅឯងចង់បានគ្រឺប៉ុន្មានក៏បានដែរ" ទៅវិញចុះ ។

លុះឮអ្នកតានិយាយដូច្នោះ នាងព្រឺក្បាលសំពោងថយខ្លួនដើរមករកបងថ្លៃវិញ ទាំងភ័យអរ . . . ។ រីឯបងថ្លៃក៏ហូចនេះ គ្រាន់តែបន្ទំធ្វើអ្នកតារួចហើយ ក៏ស្ទុះមករង់ចាំប្អូនថ្លៃធ្វើព្រងើយ ប្អូនថ្លៃទៅដល់គេក៏សួរថាៈ "ម៉េចមេនាងបានការយ៉ាងណា ?" ប្អូនថ្លៃមានអាកប្បកិរិយាអៀនខ្មាសបងថ្លៃដែរ . . . តែទីបំផុតនាងក៏បាននិយាយសារស័ព្ទប្រាប់បងថ្លៃដូចពោលខាងលើស្រាប់ ។ បងថ្លៃឮហើយក៏ធ្វើជានិយាយថាៈ "ហ៊ឹះបងទ័លគំនិតដែរ បើលោកតាប្រាប់អ៊ីចឹងហើយ ម៉េចមេនាងឯងគិតយ៉ាងណា ? ។

- នាងក្រមុំអឹមអៀមបៀមដៃហើយនិយាយថា: ចាះខ្ញុំមិនដឹងគិតយ៉ាងណាដែរ... ។ បងថ្លៃក៏បន្តទៅទៀតថា ណ្ហើយយើងប្រថុយម្ដងលមើលមើល៍ តើបានឬមិនបាន ដូចពាក្យអ្នកតាថាទេ ? ។ អើស្រេចតែអ្នកឯងចុះ...ប្រថុយក៏ប្រថុយដែរ...អត់ត្រីស៊ីយូរហើយ...។

- ក្រោយពីចាត់ការរួចហើយ អ្នកទាំងពីរក៏បាននាំគ្នាទៅបង់សំណាញ់ជាលើកទី ២ ទៀត ការបង់លើកនេះបានត្រីត្រីហូតគ្រប់សំណាញ់ កាលបើបានត្រីច្រើនយ៉ាងនេះ អន្ទិតយើងក៏និយាយថា "មេនាងហ្នំ: អ្នកតាព្រះព្រៃជ្រពូកែដល់ហើយថាគ្មានខុសតែម្ដង" ថ្ងៃក្រោយមេនាងឯងទៅបន់ទៀតហ្នំ ។ ប្អូនថ្លៃមិនទិយាយតបទេតែងក់ក្បាលញញឹមសំដែងអាកប្បកិរិយាយល់ព្រមគ្មានជំទាស់ចំពោះបងថ្លៃ ។ កន្ទុំយូរថ្ងៃក្រោយមកទៀតទាំងពីរនាក់បានទៅបង់សំណាញ់ អន្ទង់ដដែលទៀតហើយមិនបានត្រីដូចលើកទី ១ ដែរ ដូច្នោះនាងក៏បានទៅបន់ស្រន់អ្នកតាព្រះព្រៃជ្រម្ដងទៀតតាមបង្គាប់បងថ្លៃ ។ រីឯបងថ្លៃក៏បន្ទុំទៅពួនធ្វើជាអ្នកតាដូចមុនទៀតដែរ ។ ក្នុងខណៈដែលនាងនិយាយបន់ស្រន់រួចហើយអ្នកតាព្រះព្រៃនិយាយដូចមុនទៀត នាងឮសំដីអ្នកតានិយាយឆ្លើយមកនាងក៏ទឹកចាប់ក្អកថា ...យី... សំឡេងអ្នកតាដូចជាសំឡេងបងថ្លៃអញបេះបិទតែកន្លែងប្រលរបន្តិច រួចនាងក៏ទំរើតពិនិត្យមើលតាមសូរសម្លេងដែលនិយាយមករកនាង ស្រាប់តែឃើញក្បាលអៃបទីងបុសព្រៃដែលនៅក្រោមខ្ទម ទើបនាងគាក់ហើយនិយាយជាភាសាក្អួយអន្ទរថា:

"យ៉ៈ បុនិ" ដូចជាប៉ុអង់ ? ប្រែថា ៖

យ៉ះក្បាលនេះ ដូចជាក្បាលអ្នកឬ ?

អទិតយើងកាលបើគេឃើញ ក្បាលខ្លួនច្បាស់ហើយគេចមិនរួចផង ទើបឆ្លើយថា "ប៉ុអង់ ថា មិនប៉ុអង់" ប្រែថា: "ក្បាលអ្នកថាមិនក្បាលអ្នក" រួចចេញពីក្រោមខ្លួនអ្នកតាមក រីឯប្អូនថ្ងៃក៏នឹកហួសចិត្តនឹងអ្នកតា "មនុស្សរស់" នេះណាស់ដែរ តែបានជាជ្រួលហួសទៅហើយៗ

អន្ទង់នេះក្រោយពីមានរឿងកាវ ដូចពោលខាងលើមក ក្នុយអន្ទ័រ គេហៅអន្ទង់នេះថា: "អន្ទង់ប៉ុអង់" បកថា: អន្ទង់ក្បាលអ្នក ៗ លុះក្រោយមកមានមនុស្សមកតាំងភូមិនៅកុះករច្រើននៅមាត់ "អន្ទង់ប៉ុអង់" អ្នកភូមិក៏គេហៅភូមិនេះថា: "ភូមិប៉ុអង់" ទៅវិញ តែអ្នកភូមិនេះបាននាំគ្នារើមកនៅភូមិហោលហាល លុះសព្វថ្ងៃដូចខ្ញុំបាទជំរាបខាងលើស្រាប់

រីឯភូមិហោលហាល ឬ "ភូមិអាឡោះអាល័យ" តាំងពីមានមនុស្សមកពីភូមិផ្សេង ៗទៀត ចូលមកនៅកកកុញច្រើនគ្នា មកកាលណាអ្នកភូមិ ក៏នាំគ្នាឈប់ហៅភូមិហោលហាលនោះទៅ ហើយនាំគ្នាសន្មតហៅថា: "ភូមិប៉ាលហាល" ទៅវិញលុះសព្វថ្ងៃនេះ ៗ

ហ៊ុន-សារី

សមាជិកសមាគមអ្នកនិពន្ធខ្មែរ

# ល្បើកអក

លោកអ្នកអានធ្លាប់បានជ្រាបមកហើយ នូវជីវៈប្រវត្តិលោកវិសេស ដូង ដែល លោកបណ្ឌិតមហា ឈឹម-ស៊ុម បានស្រាវជ្រាវ ហើយរៀបរៀងចុះផ្សាយ ក្នុងទស្សនាវដ្ដី “ កម្ពុជសុរិយា ” កាលពី គ.ស. ១៩៦៨ ហើយក្នុងប្រវត្តិនោះ បានបង្អុលថា លោក វិសេស ដូង បានសរសេរ ល្បើកអក នេះឯង ជាស្នាដៃ សំខាន់របស់លោកផង ។

ដូច្នេះនៅវេលានេះ ខ្ញុំបានស្រាវជ្រាវយកអត្ថបទ “ល្បើកអក” មកចម្លងពី សាស្ត្រាស្លឹករឹត ហើយចុះផ្សាយក្នុងនេះ ដើម្បីបញ្ជាក់ជូនអ្នកអានឲ្យបានជ្រាបច្បាស់ អំពីស្នាដៃរបស់កវីដ៏ឆ្នើមខ្មែរយើងនេះ ។

លី-ធាមតេង

## ពាក្យ ៧

២ នេះនឹងថាថ្លែងថែងសាសង៍   លើកតាមទំនងល្បងប្រាជ្ញា
ប្រាំពីរពាក្យពិតគិតបួនឃ្លា   ចងជាតិទានមានសេចក្ដី ។
គ្រានោះមានសត្វអកទាំងគូ   នៅកំផ្សូរមានកូនខ្ចី
តែងត្រេចជ្រែករកចំណី   មកចិញ្ចឹមនៃកូនប្រពន្ធ ។
លុះដល់ខែចេត្រជួនរីងរាំង   គោកអស់ត្រពាំងគ្មានជោរជន់
សត្វអកទាំងពីរកើតទុកធ្ងន់   មិនត្រេបរកគន់ត្រីពុំបាន ។
ហើរមកប្រឈមមើលមុខគ្នា   ថាឱអនិច្ចាកូនកល្យាណ
ម្ល៉េះសមបាទឹងស្រេកអត់ឃ្លាន   គឺកម្មបុរាណមកតាមហើយ ។

សត្វអកទាំងពីរវែងស្គមពេក ក្រឡេកមើលមេឃឆ្ងាយនៅឡើយ
ឱយើងជាប់ពោះស្លាប់ជើងអើយ កម្មអើយមកឲ្យវេទនា ៗ
ហើយមកនិយាយនឹងប្រពន្ធ ថាថៃប្អូនតន់ស្ងួនពុំងា
បងនឹងចង់ទ្រេចចរលីលា ទៅរកម្ហូបនឹងបរិភោគ ៗ
ចូរប្អូននាងនៅរក្សាកូន ឲ្យមូលនឹងខ្លួនកុំវិយោគ
បងទៅរកបានបង់វិលមក ប្អូនកុំសោយសោកនឹកបងឡើយ ៗ
គ្រានោះអកញីសោតបានស្ដាប់ ឮប្ដីប្រាយប្រាប់ដូច្នោះហើយ
ត្រេកអរក្នុងចិត្តថាអ្នកអើយ ទៅហើយអ្នកវិលមកឲ្យឆាប់
ផ្ដាំថាឈើពុកអ្នកកុំទំ ត្រីណាធំៗអ្នកកុំចាប់
ក្រែងវានាំរត់លិចលង់ស្លាប់ ទៅហើយប្រញាប់វិលវិញផង ៗ
គ្រានោះអកឈ្មោលកាន់ស្លាបហើរ ក្នុងចិត្តស្នាក់ស្នើរគាត់វិលង
ដល់វាលហើយខំហិចហើរខ្លង វិលងវាលនោះចូលព្រៃធំ ៗ
ឮតែសម្លេងសត្វទៀវពោច យាសយំលន្ទោចស្ងាត់ជ្រងំ
តាពើស្រែកខ្លងជងព្រៃភ្នំ បានមុំមាសមកសមសប្បាយ ៗ
បងមើលឯអស់សត្វហ្វូងហ្វូង ទំទឹមទាំងគូពុំព្រាត់ព្រាយ
លលកចាបព្រៃផងទាំងឡាយ ហើរសាយគគ្រឹកក្នុងព្រឹក្សា ៗ
ឱហង្សទាំងគូហើរត្រេសង កម្មអ្វីអញបងមកកំព្រា
ទ្រេចហើរម្នាក់ឯងឥតគ្នីគ្នា ចរចាហើរលេងពុំសប្បាយ ៗ
ស្រណោះរៃយំកណ្ដាលទួល បើអញបានមួលប្អូនដោះស្រាយ

ទឹងនាំមើលឈើផងទាំងឡាយ និយាយប្រាប់ប្រាយឲ្យសព្វគ្រប់ ។
ខ្ចុកផ្កាកំភួនរងតែរក រំពេកស្វាកែតក្រអូបឈ្ងប់
ពប់អស់ព្រឹក្សាផងពុំសព្វ គេសំងដឹងគ្រប់សព្វសាស្ត្រា ។
អកហើរច្ចុងព្រៃដល់ទៅចឹង ឃើញគេទ្រហឹងចាប់មច្ឆា
អកហើរបន្ទាបខ្លួនសិរសា ប្រាជ្ញាទឹងសូមត្រីបរិភោគ ។
អ្នកអើយអ្នកអកអ្នកនៅចឹង ចូរអ្នកកុំខឹងខ្ញុំសូមជ្រក
ឲ្យបានត្រីសាច់គ្រាន់បរិភោគ អនេក្សាគឲ្យខ្ញុំរកស៊ីផង ។
គ្រានោះអកចឹងឆ្លើយទៅថា អ្នកមកពីណានៃអ្នកបង
ចូរប្រាប់មកខ្ញុំតាមទំនង សាសងឲ្យអស់គ្រប់សេចក្តី ។
ទើបអកក្នុំឆ្លើយទៅវិញថា ខ្លួនខ្ញុំនេះជាអ្នកក្រក្រី
នៅក្នុងព្រៃក្តីគ្មានបានអ្វី ស៊ីជាចំណីដល់តិចឡើយ ។
ទឹកសោតក៏គោកស្ងួតសោះផង ដីបែកក្រហែងគ្មានសល់ឡើយ
បានជាហើរមកណាអ្នកអើយ កម្មអើយស្មើរស្លាប់កូនប្រពន្ធ ។
អកចឹងព្មថាអាណិតពេក កម្មអ្វីចំឡែកក្រលើសលន់
នឿយព្រួយលំបាកយ៉ាកអាប់ឲ្ន កែកុនគិតមករកចំណី ។
អ្នកនៅចឹងនេះក្រែងពុំបាន ត្រីពុំសូវមានក្រណាស់នៃ
ទៅរកចឹងទៀតក្រៅដៃ មានត្រីច្រើនណាយទឹងបរិភោគ ។
ទៅចុះខ្លួនខ្ញុំទឹងជូនទៅ ដល់ហើយអ្នកនៅខ្ញុំវិលមក
តាមតែគេស៊ុំអោយល្អូងឯក លៃលកឲ្យបានដើរប្រពន្ធ ។

គិតហើយអកហើរទៅតាំងសង ហើរកាត់រលងផែនដីបន់
ដល់បឹងធំឆ្ងាយទូលាយលន់ ហើយគន់មើលសព្វគ្រប់ទិសា ។
ហើយអ្នកដែលជូនត្រឡប់ទៅ ដល់ទីលំនៅឋានអាត្មា
ចូលទៅនៃបនៅនឹងករិយា ក្រេមក្សាន្តសុខាឥតអំពល់ ។
ថ្ងៃងពីអកក្ដំទំមាត់បឹង គន់គិតជញ្ជឹងនឹកខ្វាយខ្វល់
ហើយហើរចរចុះទៅបានដល់ យន់យល់អកបឹងទំព្រៀបត្រា ។
ទើបអកក្ដំទៅនិយាយសុំ ត្បិតខ្ញុំមកនេះអត់អាហារ
យូរថ្ងៃស្រាំងស្គមតាំងកាយា សូមរកគោត្តាដោយសារអ្នក ។
គ្រានោះអកបឹងស្ដាប់សំដី សួរសាកទៅវិញដោយស្មោះស្ម័គ្រ
និយាយពេះពយពាក្យពក់ពាក់ ថាអ្នកអកមកពីឋានណា ។
ចូរអ្នកប្រាប់មកជាដំណឹង ឲ្យយើងបានដឹងដោយវាចា
អកមកសូមសុំរកគោត្តា យើងក៏មេត្តាព្រមឲ្យអ្នក ។
ចូរមកបរិភោគកុំបារម្ភ មច្ឆាតូចធំតាមចិត្តស្ម័គ្រ
កុំមានគោតក្រែងឡើយណាអ្នក រកបរិភោគកក្សេតាមចិន្ដា ។
អកក្ដំត្រេកអរមុខរីករាយ និយាយប្រាប់ប្រាយពីអាត្មា
ខ្ញុំនៅព្រៃក្ដំអត់អាហារ ចំស្វែងយាត្រាមកដល់អាយ ។
ត្បិតបឹងត្រពាំងឯព្រៃក្ដំ រីងបឹងតូចធំពោះជិតឆ្ងាយ
មច្ឆាតូចធំផងតាំងឡាយ អន្ដពយវិនាសស្លាប់គ្មានសល់ ។
អកបឹងស្ដែងស្ដាប់គ្រប់សេចក្ដី មានចិត្តមេត្រីនឹកខ្វាយខ្វល់

បបួលអកគ្នាទៅបានដល់ ទីដែនមណ្ឌលដើររកស៊ី ។
អកបីនត្រឡប់វិលមកវិញ អកគ្នានោះមិញចាំនៅទី
ត្រីផ្ដៅហែលមកទាំងឈ្មោលញី អកធ្មើមមើលោភក្អាក់ខ្លួន ។
អកលោស្ទុះផ្ទាំងទៅទឹងចាប់ ត្រីនោះបានខ្ជាប់នាំលេបលួន
អកប្រឹងទទះភ័យរងខ្លួន ទុប្រពន្ធកូនសមកញ្ជ្រោ ។
អកភ័យស្ទាំងស្ទឹងក្អែកសព្រោក ខំប្រឹងសង្វាតស្ទុះម៉្មមា
ទទះរបូតរូបហើយណា អកប្រឹងប្រវាដល់មាត់បឹង ។
ហើយទំកំប្រោបានទុនកក្អក មុខស្ទាំងស្ទឹតស្ទក់នៅទ្រមឹង
កំព្រោះផានៅក្បែរថ្កើង រំពៃរំពឹងទឹងគិតគន់ ។
ជាទុអទិប្ធាខ្លួនអញពេក កម្ពុជីចំឡែកក្រលើសលន់
ខំស្វែងម្នាក់ឯងពោលប្រពន្ធ សមទឹងបងជន្ធមិនលែងឡើយ ។
ឃើញត្រីសង្វាតចាប់ទឹងស៊ី រួបទៅទទៅហែលព្រងើយ
វានាំខ្លួនឯងលិចលង់ហើយ អញអើយកុំអីស្លាប់អសារ ។
អកមានកំឡាំងហិចហើរទៅ ឃើញអកញីនៅលើរុក្ខា
មេម៉ាយស្លាប់ប្ដីនៅឯកា កំព្រាកំព្រេនតែម្នាក់ឯង ។
អកគ្នាហិចហើរចូលសំដៅ ដល់ហើយទំនៅគិតថាថ្លែង
និយាយចំអន់ចំអកលេង ចាបែងទៅជានៃនាងអក ។
នាងនៅម្នាក់ឯងក្តីឯកា ឥតគូកំព្រាបងសូមជ្រក
ផើខ្លួនលើបួនសូមអធ្យាក បងមកសង្វាតរកអាហារ ។

សូមឲ្យប្អូនមាសនាងអាណិត　　រំពឹងរិះគិតក្នុងប្រាជ្ញា
ជាម្តេចជាចុះឲ្យឃើញការ　　ចិន្តាបងអ្នកបងស្គាល់ប្អូន ។
ទើបអ្នកញីស្លាប់សងវាចា　　ខ្លួនខ្ញុំនេះជាស្រីសុទ្ធសួន
ពុំគួរមកពឹងពំនាក់ប្អូន　　ផ្ញើខ្លួនដូច្នោះយល់ពុំសម ។
ខ្លួនខ្ញុំមានប្តីស្លាប់ពេលពៅ　　មេម៉ាយមកនៅដូចក្រមុំ
កំព្រារងាដោយព្យុះធំ　　អ្នកអើយអ្នកកុំក្រែងសៅហ្មង ។
មានពាក្យដំនៀលអាស្រូវកាស　　ខ្មាសអស់ទាំងផ្តាសគេថាឆ្គង
មេម៉ាយយកប្រុសមកនៅផង　　កុំចុះអ្នកបងក្រែងកើតវេរ ។
ទើបអ្នកកុំសងសព្វសេចក្តី　　ព្ធពាក្យប្អូនស្រីស្តីគយរ
ត្រូវពិតប្រាកដហើយមែនហ្ន៎　　បារម្ភថ្វីនឹងវរប៉ុណ្ណោះឡើយ ។
បងសោកពោះម៉ាយស្លាប់ប្រពន្ធ　　ដូចប្អូនមាសគន់ថៃនាងអើយ
ស្វែងសុះលាភលះមកជាឈ្មើយ　　កែវអើយចូរប្អូនអាសូរបង ។
បងនឹងសូមបងជាមេត្រី　　នឹងប្អូនស្រស់ស្រីជាគូគ្រង
តាមតែអាណិតចិត្តចុះហោង　　មាសបងសោកប្អូនស្ងួនកំព្រា ។
ទើបអ្នកមេម៉ាយឆ្លាសឆ្លើយទៀត　　ថាអ្នកកុំបៀតហ៊ានពុះពារ
លួងលោមបញ្ជោតឲ្យបានជា　　សង្សារហើយណាបែរដោះដៃ ។
ខ្លួនខ្ញុំពុំសូវជាចេះឆោត　　ឲ្យអ្នកបំពោតដូចអស់ស្រី
ណ្ហើយចុះប្រុសអើយកុំចេតី　　អ្នកទៅរកស្រីឯទៀតវិញ ។
ខ្លួនខ្ញុំពុំបានព្រមនឹងអ្នក　　ជាគូររួមរក្សហាក់បណ្តាញ

ទៅចុះតាមចិត្តរើសស្រឡាញ់ អកច្រើននៅពេញតែមាត់បង ។
អកកុំព្រួយហើយសើចបិទមាត់ ថាទុះគេកាត់ចោលសោះដឹង
អង្ករទៅថាប្អូនកុំខឹង ជញ្ជាំងស្តាប់បងនឹងប្រាយប្រាប់ ។
អំពីដំណើរបងស្រឡាញ់ ស្រីច្រើនពាសពេញមិនមានចាប់
ចិត្តបងស្រឡាញ់ជាគួរគាប់ ឃើញប្អូនស្រនាប់ត្រូវចិត្តបង ។
បងបានជាស្ម័គ្រនឹងប្អូនស្រី សូមប្អូនប្រណីមេត្រីបង
កុំអាលក្រេវក្រោធលោតរំលង មាសបងបងនឹងផ្ញើជីវិត ។
នាងអកព្រួស្ងួរសព្ទសំដី មានចិត្តមេត្រីទិកអាណិត
តែជាពាក្យក្រៅថាមិនស្បៀត ប៉ុន្តែឯចិត្តស្រឡាញ់ណាស់ ។
ទឹងព្រមទៅហាក់អៀនរឹងមាត់ ហើយខ្វះបន្ទាត់ទឹងច្បាប់ចាស់
ណែកតែងទុកមកឲ្យដឹងច្បាស់ ចាំងកេងចាំងចាស់រក្សាកេរ្តិ៍ ។
នាងអកអៀនទុនធ្វើមិច បើធ្លុចបព្រិចភ្នែកមមី
អកកុំដើរចូលជិតទៅទី អកញីថាឃើពេញចិត្តធំ ។
ជិនណាស់កុំមកលេងរែករ យើងមិនស្រីចោរបើកក្រមុំ
បានស្ទុះមកឈរជិតទទឹម ស្ទុះខមធ្វើមុខហើយសោះ ។
នាងអកប្រានផាងថាចុះទៅ កុំអកមកនៅធ្វើនេះនោះ
ររញ៉ាញ៉ូវទៅស្រុកវិញទៅចុះ ធ្វើយ៉ាងដូច្នោះមិនព្រមឡើយ ។
អកកុំថាទុះអកុសលកម្ម នាំនាំអញមកដល់ស្រីហើយ
បានតែជួបមុខខកគាន់សើយ ប្អូនអើយពេញក្តីបេះតាមបុរាណ ។

បើប្អូនបណ្តេញបងចុះទៅ បងនឹងទំទៅម្តេចនឹងបាន
ចិត្តគេគោះតើយស្បើយក្នុងប្រាណ នឹងទៅបំពានម្តេចបានឡើយៗ
នីនៃ ! ប្អូនបែរមកឯអាយ បងនឹងនិយាយលាប្អូនហើយ
ចុះប្អូននាងនៅឲ្យល្ហែល្ហើយ ប្អូនអើយនាងនៅឲ្យសាន្តសុខៗ
ត្បិតបងបានជាអកតើយហើយ ប្អូនអើយបងលាប្អូនទៅស្រុក
កុំទឹកដើមបងក្រែងរាំយុក នាងអកកើតទុក្ខពុំស្តីសោះ ៗ
អកក្តាំផ្តាំស្រេចហើយបើកស្លាប ដាក់ក្បាលទន្ទាបធ្វើនឹងស្លុះ
អកញីចិកស្លាបនឹងដំពុះ ថានៃអកប្រុសកុំសាលទៅ ៗ
អកក្តីបែរមុខវិលមកវិញ ថាប្អូនសំឡាញ់ចិត្តនោមឆ្ងៅ
ប្អូនឃាត់បងប៉ុមិនឲ្យទៅ ប្តឹកបងនៅជាគូគ្រង ៗ
នាងអកអៀនខ្ទនហើយដាក់មុខ ក្នុងពោះបំផ្អកពុំសាសង
ហើយលួចមើលអកក្តុំមួង ៗ គិតពុំធ្លាស់ធ្ងន់ទៅទៀតឡើយ
គ្រានោះអកក្តុំចូលចាប់ស៊ី អកញីក្រេញក្រាបទន្ទាបហើយ
ទទួលពបររងផ្ដងផើបផើយ ដិតហើយអកប្រឹងរឹងទាំងប្រាណ ៗ
អស្ចារ្យនឹងលាន់ពុស្រពុស្គរ ទឹកហូរជន់ជោរលិចគ្រើយគ្រាណ
រលកបោកក្រែងរិចពុំមាន សល់ទានដល់មួយដើមតិចឡើយ ៗ
ក្រពើលលើហែលចុះកោះ លួចចូលក្នុងជ្រោះមុជជើបជើយ
ខ្ពុលទឹកលេងស្រេចហែលថយក្រោយ ងើបហើយមានក្បាលនោះពប់ស្មើ ៗ
អកសត្វតាំងតើរើងស្រេហស្ត្រិទ នៅនឹងរួបរែតពុំល្ហើយល្ហៃ

ចូលចិត្តគិតតែលែកស៊ី ទាំងឈ្មោលទាំងញីពុំឃ្លាតឡើយ ៗ
យើងនឹងឈប់ស្នេះត្រង់នេះនៃ ត្បិតផុតសេចក្ដីប៉ុណ្ណោះហើយ
អកញីនៅក្ដុំពុំព្រងើយ ពុំដឹងដើមឡើយរឹងទន្ទឹង ៗ
សង្កាត់សង្វែងវែងមើលផ្លូវ ពុំឃើញប្ដីក្លូវនៅទ្រមឹង
ស្គាំងស្គមទ្រមខ្លួននៅតែធ្អឹង រំពៃរំពឹងគិតទៅគ្រប់ ៗ
ស្រមើលស្រមៃក្រៃពេក សន្ធៃសន្ធឹកនឹកគ្មានឈប់
វង្វេងស្មារតីប្រឹងតែផ្ទប់ ហើយខប់ពុំបានស្រែកខ្លួញថា ៗ
ថាទុះអ្នកអើយម្នែអ្នកអក លាប្អូនទៅរកចាប់មច្ឆា
ឥឡូវបាត់ស្ងួនយូរពន់វេលា តើមានប្រការហេតុដូចម្ដេច ៗ
ឬមួយអ្នកស្លាប់ទៅដឹងអើយ ឬរស់នៅឡើយហើយគិតគេច
មានស្រីថ្មីទៀតក្រែងអ្នកភ្លេច គិតគេចឲ្យប្អូននៅកំព្រា ៗ
បើពិតប្រាកដដូច្នោះមែន បាត់ហើយផ្អែតណែនក្នុងឧរា
មានស្រីប្ដីទៀតដូចខ្ញុំថា ឧរាតានតឹងស្ទើរនឹងញាយ ៗ
បើអ្នកពុំមែនដូច្នោះទេ ខ្ញុំគិតក្រែងតែអ្នកក្សយកាយ
ពេលភ្លោចម្នាក់ឯងនៅព្រៃឆ្ងាយ ខ្លួនខ្ញុំនៅអាយពុំដឹងឡើយ ៗ
នាងអកទ្រហោយំកន្ទេង សង្រែងស្រែកសព្ទសូរល្វើយៗ
បៀងបែរប្រែមុខងក់ងើបងើយ មួញហើយនាងអកសន្ធប់លង់ ៗ
លុះដល់ព្រលប់យប់ជ្រៅស្ងាត់ ព្រះពាយផាយផាត់ខ្ទាំងពេកពន់
សន្ធៀមសោកស្ងាត់ត្រជាក់ស៊ុន ស្វាងមុខៈក្រោកគន់សព្វទិសា ៗ

ឃើញតែកូនតូចនៅសំបុក    រីឯតែកើតទុក្ខចុកខ្លោចផ្សា
អន់អួលក្តួលក្តៅក្នុងឧក    ខ្ញួញថាឱកូនមាសម្តាយអើយ ៗ
បានៅចាំម្តាយរកក្សាគ្នា    ម្តាយនឹងយាត្រាទៅឆ្ងាយហើយ
តាមរកនំបាណាកូនអើយ    បាអើយចុះនៅសមកណ្តែង ៗ
ហើយអកស្រែកផ្តាំអស់ទេវតា    សូមលោកមេត្តាជួយតាក់តែង
ថែចាំកូនខ្ញុំត្បិតកូនក្មេង    កុំឲ្យត្មាតខ្វែងឆាបឆក់ឡើយ ៗ
ឲ្យបានសាន្តសុខកុំឲ្យខ្វល់    ទុក្ខទោសមកដល់ខ្ញុំលោកអើយ
លោកចម្លងដាក់ឲ្យដល់គ្រើយ    ម្ចាស់អើយលោកជួយឲ្យសព្វគ្រប់ ៗ
អកខ្ជួញស្រេចហើយកាច់ស្វឹកឈើ    មកគ្របពីលើឈើជាម្ជប់
ផ្តាំថាមាសម្តាយចូរអ្នកស្រប់    ចាំងថ្ងៃចាំងយប់កុំចេញក្រៅ ៗ
ក្រែងក្អែកខ្វែងរាមើលឃើញបា    ចូលចាប់គោក្តាគ្មានសល់នៅ
ស៊ីអស់រលីងហើយហើរទៅ    កូនពៅបាកុំប្រហែសប្រាណ ៗ
អកផ្តាំស្រេចហើយស្ទុះហើរទៅ    កងទ្រូងក្តួលក្តៅគិតរំខាន
ប្រឹងកាត់ហើរហាចលុះលេចបាន    ដល់បឹងចឹលមានអកត្រៀបត្រា ។
ប្រឹងគន់មើលប្តីមិនឃើញសោះ    មើលតាមចន្លោះគ្រប់ទិសា
ចូលទៅសួរគេធាប់ម្ញីម្ញា    ថានៃអ្នកអកអ្នកនៅគាយ ៗ
ក្រែងអ្នកយល់ប្តីខ្ញុំផង៎    បើឃើញអ្នកបងអ្នកប្រាប់ប្រាយ
ឲ្យបានស្បើយទុក្ខចិត្តរាយមាយ    និយាយប្រាយប្រាប់ពីទុក្ខខ្ញុំ ៗ
អកបឹងប្រាប់ថាយើងយល់    ឃើញតាតមកដល់បានជួបជួន

និយាយប្រាប់ប្រាប់ពីរឿងខ្លួន ថាប្រពន្ធកូននៅឯភ្នំ ។
ខ្ញុំក្រែងគាត់ទៅបាត់ទៅហើយ ឥឡូវម្តេចឡើយបាត់ជ្រងំ
ទៅរកគាត់ចុះឯបឹងធំ ម៉្លេះសមគាត់មានទៀតដឹងអើយ ។
អកញីស្តាប់ជាក់ហើយលាទៅ ប្រឹងហើរសំដៅដល់បឹងហើយ
ប្រឹងគន់មើលប្តីពុំយល់ឡើយ ជាក់ហើយរកសព្វគ្រប់ទិសា ។
លុះឃើញប្តីជាក់ក្អាក់ខ្លួនព្រើត កន្ទុយងើងខ្ទើតទំទឹមគ្នា
ជាក់កកក្អក់លើព្រឹក្សា ឱកគាត់គឹងស្មើរនឹងផ្កាយ ។
អកញីទំមើលតែពីក្រៅ កងទ្រូងកុលក្តៅគ្មានស្រាយ
ពុះពោរឱកផ្សាក្រហាយ ស្មើរនឹងប្រេះធ្លាយជាពីរភាគ ។
អកក្អំទំទឹមតាំងឈ្មោលញី ដេចក្អែកមម៉ីមិនមានឃ្លាត
ក្អេចកូនប្រពន្ធមិនចាំពាក្យ នឹងមករកខ្លាចប្រពន្ធចុង ។
អនិច្ចាអកញីរឹងកើតទុក្ខ ខ្យល់ស្ទះស្ទុះរត់នៅកងទ្រូង
វង្វេងស្មារតីឡប់ឡិនឡង់ ខំផ្ទង់ស្មារតីញីរចំប្រប់ ។
ចង់ហោះខ្លួនស្លាប់តាមចិត្តខឹង កំដឹងទៅកូននៅកងស្រប់
កូនអើយបាកើតមកឥតគ័ព្ទ ពុំគាប់ពុំគួរប៊េដូប៊េះ ។
ម្តាយស្មែងហោលកូនៈនាឯនាយ ក្រៀមក្រំទ្រូងម្តាយស្មើរនឹងប្រេះ
មិនដឹងជាចិត្តគេដល់ម៉្លេះ បើនេះហោះពេញវង្វេងស៊ុន ។
បើគេបិតគិតកស្ប្រាយ គំនិតនឹងស្លាយទៅកូនគន់
មិនគួរកូនម្តាយឥតលោកលង់ កូនគន់សំឡាញ់មាសម្តាយអើយ ។

ម្តាយក្រុងក្រញូក្រោមរក្សាបា ត្រាំរងវេទនាពុំបានស្បើយ
ជាទុក្ខព្រួយចិត្តឥតល្ហែល្ហើយ កូនអើយគៀតគេចេញចាកទៅ ។
សន្ធតតែត្រឹមបីទិវា ទឹងវិលលីលាមកនៃបទៅ
ក្រុបក្រុងរក្សាគ្រងកូនពៅ ពាក្យម្តាយចាំនៅមិនឃ្លាតឃ្លា ។
ម្តាយតែងទន្ទឹងចាំក្រង្កូវ មើលផ្លូវហួមដល់សត្តទិវា
ទាំងកូនទាំងម្តាយរងវេទនា អាហារសោភគ្មានពោះសោះធេង ។
សុខទុក្ខខ្លួនម្តាយៗមិនគិត អាណិតតែបុត្រៗនៅក្រុង
អត់ទាំងអាហារឃ្លានបន្ទ្រង ដោយពុំដែលរៀបគិតស្រេកឃ្លាន ។
នាងអកស្រែកខ្លួញពីកំសត់ ញាប់ញ័រព្រួតរក់សអង្គប្រាណ
ដោយគត់អាហាររកពុំបាន ស្គមប្រាណរក់ស្ទើងនៅតែឆ្អឹង ។
សោយសោកបោកខ្លួនស្លាប់ទៅជា បុទ្គលរមៀប្រាតិតរំពឹង
អាសូរនាងអកនៅមាត់បឹង ទំប្រឹងកាងស្លាបឡើងវន្ទា ។
គ្រប់ទីគ្រប់ទិសទាំងប្រាំបី ទាំងស្នេហាស្រីធគាមា
ទាំងទេពសោឡសព្រះព្រហ្ម ខ្ញុំនបស្ការថ្វាយបង្គំ ។
សូមជាសាក្សីក្នុងជាតិនេះ ប្រុសចិត្តផ្ដេះខ្ញុំសូមសុំ
លាសព្វគ្រប់ជាតិកុំឲ្យខ្ញុំ ជួបជុំរៀងរួមដល់និព្វាន ។
អកស្រែកឃោសនាដស់ទេវតា សូមសុំសព្វតាំងប្រណិធាន
រូបស្រេចវន្ទតក្នុងអង្គប្រាណ គិតកូនកន្ល្រាណនៅក្នុងព្រៃ ។
ម៉្លេះសមទន្ទឹងមើលផ្លូវម្តាយ កូនកយម៉្លេះសមបាសនៃ

សន្ទឹកទឹកម្តាយអត់ចំណី    ហាលខ្យល់ហាលថ្ងៃតែពីរនាក់ ។
អកក្តុំស្រែកយំទួញក្តែងៗ    អកឈ្មោលនោះតែងស្តាប់ទៀងដាក់
ធ្វើតើយព្រងើយមិនភ្ញាក្ញាក់    ទំទឹមពីរនាក់ប្រពន្ធបុង ។
រីឯរឿងកាវដំណើរនេះ    ទុកស្នេះថ្ងៃងពីកូននៅក្នុង
ព្រៃធំជ្រងំស្ងាត់សូន្យសុង    តែងរងទន្ទឹងមើលផ្លូវម្តាយ ។
សន្ទៃសន្ទឹកញ័រចំប្រប់    ត្រូវថ្ងៃសន្ទប់ទាំងពីរកាយ
លុះភ្ញាក់ស្មារតីធ្វេសកាយមាយ    បើកភ្នែកមើលម្តាយមិញមិនយល់ ។
ជាហេតុកម្មកូនសូន្យទាំងពីរ    ពៀរព្រេងបុព្វកម្មមកផ្តល់
ហេតុសត្វទាំងពីរសាងអកុសល    មិនផ្តល់ឲ្យយល់ឃើញថ្មៗ ។
គ្រានោះមានសត្វត្មាតកំណាច    ជាសត្វកាយកាចចោរអប្រិយ
តែងទឹងឆាបឆក់កូនបក្ស    ស៊ីជាចំណីសព្វទិវា
មានកាលសម័យថ្ងៃនេះនៃ    ត្មាតហើរត្រៀវប្រែសព្វព្រឹក្សា
សំកាំងស្ទាបរកមើលរេក    លើចុងព្រឹក្សាបានឃើញជាក់ ។
បានយល់កូនអកនៅទាំងពីរ    មិនឃើញមានមេនៅរួមរក្ស
ត្មាតត្រេកអរសោទរអរឥតអាក់    ត្មាតភ្ញាក់គិតថាឱលាភហើយ ។
គិតក្នុងត្មាតបរបូលចិកស៊ី    កូនអកទាំងពីរពុំលង់ឡើយ
ហែកយកថ្លើមស៊ីស្រេចព្រងើយ    អស់ហើយទម្លាក់ចោលទៅដី ។
ហើយត្មាតហើរទៅលំនៅបាន    បរិបូណ៌ក្សេមក្សាន្តឥតហេតុអ្វី
រកស៊ីដូចកាលដើមប្រក្រតី    ឥតបីឥតបើមានអំពល់ ។

ឈប់ស្ទះខឹងថ្ងៃងពះមេអក　　ក្រឡាប់វិលមកដល់មណ្ឌល
ពេលក្អែកក្រឡេកមើលមិនយល់　　កូនគូទិមិលនៅសំបុក　　ៗ
អកវង់កើតទុក្ខក្ដៅផ្សា　　ញ័រអស់អង្គាទ្រូងបើសបុក
រំខានគានតឹងរងថែមទុក្ខ　　រំភុកសោយសោកបោកប្រះប្រាណ
បម្រះនទៀលនៅសំបុក　　បែរមុខមើលកូនសព្វទិសឋាន
ពុំឃើញកូនស្ងួនកែវកល្យាណ　　អកប្រឹងប្រែប្រាណចុះដល់ដី　　ៗ
បើកវែករកសព្វស្ទឹកឈើ　　អកមើលទៅបានឃើញជាក់ខ្ចី
ដែលក្អែកតចឹកស្លាប់ធ្លាក់មកដី　　នាងស្រីអកខ្ញូញទំនួញថា　　ៗ
ឱកូនក៏សត់មាសម្ដាយអើយ　　ម្ដេចឡើយបាមកស្លាប់អសារ
ពេលម្ដាយឲ្យនៅអង្គឯកា　　ម្ដាយសូមប្រាថ្នាជួបនឹងអ្នក　　ៗ
ម្ដាយនឹងរស់នៅតែអង្គឯង　　ទ្រូងម្ដាយចំបែងតែងអួលអាក់
នឹងរស់នៅថ្វីពុំយល់ក័ក្រ　　កូនស្ងួនវិរលក្សណ៍ប្រាសអស់ហើយ　　ៗ
នាងអកសោយសោកឱបខ្មោចកូន　　សន្ទប់សុងសួនឲ្យសោះជាត្រើយ
លុះភ្ញាក់ស្មារតីពុំលង់ឡើយ　　អកខ្ញូញល្វើយ ៗ ក្នុងអធ្វា　　ៗ
ហើយអកកាន់ស្លាបឡើងបង្គំ　　ប្រណម្យតាំងចិត្តសូមសច្ចា
និងអស់ឥន្ទព្រហ្មខ្ញូរទេវតា　　ទាំងធកាមាសួគ៌ាល័យ　　ៗ
សូមលោកមួលមកជាប្រធាន　　សាក្សីពេជ្ញាណខ្ញុំនេះនៃ
ជាតិនេះខ្ញុំប្រាសនឹងកូនថ្ងៃ　　ជាតិក្រោយដរៃកុំឃ្លាតឃ្លា　　ៗ
រៀង ៗ ដរបដល់និព្វាន　　បរិបូណ៌ត្រៃមគ្គាឥតទុក្ខា

អកផ្សងរូបស្រេចខ្លួនសិរសា　　បក្សាទទះស្មើរផ្ទុកផ្ទះ ៗ
ហើយឡើងទៅលើអាកាសនាយ　　សង្រួមអង្គកាយសំយុងចុះ
ខ្យល់ផាត់អណ្តែតធ្លាក់ចេញស្លោះ　　ជ្រុះត្រង់ចន្លោះដែលកូនក្ស័យ ៗ
ស្លាប់ប្រួតប្រួតគរលើគ្នា　　មុខគួរអនិច្ចាអាណិតក្រៃ
សត្វទាំងប៉ុន្មានសឹងក្សិណក្ស័យ　　ប្រល័យស្លាប់មួយមួយនឹងគ្នា ៗ
ហៃអស់សប្បុរសផងទាំងឡាយ　　គួរខ្លាចគួរណាយកម្មវេរ
សត្វហោងមនុស្សហោងសឹងដូចគ្នា　　គួរគិតអនិច្ចាដល់រូបកាយ ៗ
បញ្ឈប់រឿងក៏ឈប់ទៅនេះ　　យើងនឹងគិតតែប្រែនិយាយ
ពីអកឈ្មោលដែលនៅឯនាយ　　និយាយល្អួងលោមប្រាប់ប្រពន្ធ ៗ
ថាហៃមាសស្នេហ៍តែព្រលឹង　　ប្អូនស្ងួនកុំខឹងអើយប្អូនតម
បងសូមទៅទៅរកដំបន់　　ប្អូនតន់នាងនៅរក្សាប្រាណ ៗ
ត្បិតបងមានកូននៅឯនាយ　　កំព្រាតម្កាយណាកល្យាណ
បងលាប្អូនពៅទៅទីឋាន　　សួរកូនកល្យាណបើកម្រទេ ៗ
អកញីឮហើយក្រាកខ្លួនព្រើត　　ចំអើតស្តីទៅថាខុមេ
ខ្ញុំស្មានជាអ្នកគ្មានកូនទេ　　ម្តេចឡើយប្រុសស្នេហ៍មិនប្រាប់ប្អូនៗ
ថាបើអ្នកមានកូនឯនោះ　　អញ្ចើញទៅចុះរកសួរកូន
អ្នកទៅកុំនៅយូរពេលប្អូន　　ស្ងាត់ស្ងួនទៅអាយមើលផងហ្ន៎ ៗ
អកឈ្មោលត្រេកអរឥតឧបមា　　និយាយផ្តាំគ្នាគ្រប់ទៅ(១)

---

១- ត្រង់នេះពាក់ក្លួន ប៉ុន្តែយើងមិនហ៊ានកែ ទុកតាមក្បាប់ដើមស៊ីករ៉ិត ។

ផ្ដាំហើយស្ទុះផ្ទះលោកសំដៅ　　តម្រង់ត្រង់ទៅឯព្រៃភ្នំ ។
អកទឹកអំពីកូនប្រពន្ធ　　ក្នុងទ្រូងអួលអន់មុខក្រៀមក្រំ
ខំហើរកាត់ដោយដងព្រៃភ្នំ　　ពិតពុំសម្រាន្តកាយឈរឈប់ ។
ខំប្រឹងហើរស្រូតរូតសំដៅ　　ដល់ទីលំនៅទៀបព្រលប់
អកឡើងរកមើលគន់សព្វគ្រប់　　ក្នុងសំបុកសព្វមិញមិនយល់ ។
ទាំងកូនទាំងម្ដាយបាត់ស្ងាត់យើង　　អករឹងតែងកើតទុក្ខរំពល់
គន់សព្វព្រឹក្សាពុំបានយល់　　អកឆ្ងល់ក្នុងចិត្តហើយគិតថា ។
ទុកូនទាំងពីរមាសឳអើយ　　ម្ដេចឡើយបាបាត់ទៅឯណា
មកឲ្យឪពុកកើតទុក្ខា　　មាតាបាសោកក៏ព្រាត់ទៅ ។
អកស្រែកទ្រហោយំក្តួង ៗ　　ពួសព្វល្វើយល្វើងក្នុងព្រៃជ្រៅ
នទៀលប្រះប្រាណសុងសុបសៅ　　សន្ទប់សូន្យនៅបាត់វិញ្ញាណ ។
លុះភ្ញាក់ស្មារតីឡើយសោយសោក　　សែនសល់អមោក្ខបោកប្រះប្រាណ
បម្រះនទៀលនៅនាឋាន　　គិតស្មានថាទុកូនអញអើយ ។
ឬជាសត្វអ្វីមកចឹកចាប់　　ឬស្លាប់ដាច់ពោះទេដឹងអើយ(១)
ទាំងម្ដាយទាំងកូនពុំយល់ឡើយ　　កូនឡើយម្ដេចមកស្លាប់អសារ ។
បើដឹងស្លាប់សល់លែងឲ្យបាន　　ឃើញប្រាណខ្មោចកូននៅតិចក៏
ទុរញ្ញាព្រោះស្រើចដោយតណ្ហា　　ប្រហែលសង្សារនៅឯនាយ ។
គិតស្មានបានសេរួបជន្មា　　ប្រឹងចាប់មច្ឆាផងទាំងឡាយ

---

១- បុរាណ អានថាដឹង-អ៊ើយ ទើបបានជាប្រើចាប់ដូនជាមួយ អញអើយ ។

ពាំពីនាយមកដល់អាយ ឱកូនឆោមឆាយមាសឪពុក ៗ
មិនដឹងមកដល់បាត់កូនទៅ ក្ដួលក្ដៅក្នុងចិត្តគិតវិតក្ក
រកកូនមិនឃើញនៅសំបុក ឱស្រស់ឪពុកម្ចាស់ អើយ ៗ
សត្វអកសោយសោកពីប្រពន្ធ ថាឱប្អូនគន់មាសបងអើយ
ពុំគួរបើបងធ្វើតោះតើយ ស្រីអើយពីកាលប្រើទៅតាម ៗ
ស្រីខ្ញួញស្រីតូចស្រីអំពល់ ស្រីស្រស់និមិលយំរហាម
មុខស្រីមុខស្រស់មុខស្រក់ឈាម ខំតាមខំហើរខំរកបង ៗ

(នៅមានត)

# កវីន្ទ្របណ្ឌិត

អ្នកនិពន្ធសតវត្សទី ១០

ដោយ

# ឌីក-គាម

---

## លំនាំដើម

ការសរសេរប្រវត្តិនិងស្នាដៃរបស់អ្នកនិពន្ធ កវីន្ទ្របណ្ឌិតនេះ បាន ជួបនឹងសេចក្ដីលំបាកជាច្រើន ព្រោះឯកសារដែលត្រូវយកមកសរសេរនេះ មិនមែននៅជុំគ្នាទេ ។ ខ្ញុំចង់ក្រងឲ្យបានជាកូនអត្ថបទមួយដ៏ខ្លីនេះ ដោយ ខ្ញុំបានប្រមែប្រមូលឯកសារត្រង់នេះបន្តិចត្រង់នោះបន្តិចឲ្យបានជាប្រវត្តិនេះ ឡើង ។

ជីវប្រវត្តិនិងស្នាដៃអ្នកនិពន្ធនេះ នៅមានកំបាំងទៀត តែខ្ញុំមិនមាន រកឃើញ ខ្ញុំរកឃើញបានតែត្រឹមប៉ុណ្ណេះៗ ដូច្នេះ ក្នុងការសរសេរមិនបាន វែងឆ្ងាយ មិនបានគ្រប់គ្រាន់ សូមលោកអ្នកអានមេត្តាអភ័យទោស ហើយ បើមានយោបល់ឬ បានជួបប្រទះប្រវត្តិ និងស្នាដៃរបស់អ្នកនិពន្ធនេះ សូម ជួយបំពេញ ឲ្យបានត្រឹមត្រូវ ដើម្បីជួយរចនាជីវប្រវត្តិនិងស្នាដៃនេះឲ្យ បានគ្រប់គ្រាន់ ។

អ្នកនិពន្ធ

# កវិន្ទ្របណ្ឌិត

តាមឯកសារនៃសិលាចារឹក ដែលខ្ញុំបានប្រមូលជូនយកមកចងក្រង នូវស្នាដៃ និងជីវប្រវត្តិនៃអ្នកនិពន្ធដ៏ល្បីឈ្មោះ នៅសតវត្សទី ១០នេះ មិនបានអធិប្បាយនូវប្រវត្តិនិងស្នាដៃអ្នកនិពន្ធនេះ ឲ្យបានវែងឆ្ងាយឬក្បោះក្បាយទេ ។ ទោះបីឯកសារដ៏ស្តួចស្តើងក៏ដោយ ក៏ឯកសារនេះបានទុកជាជំហានឬទុកជាពន្លឺមួយក្នុងការសរសេរនេះដែរ ហើយបន្ទាប់នេះទៅនឹងបានជាប្រយោជន៍ដល់អ្នកដែលស្រាវជ្រាវ ខាងក្រោយជាមិនខាន ។

ប្រវត្តិនិងស្នាដៃរបស់អ្នកនិពន្ធកវីន្ទ្របណ្ឌិត អាចចែកទៅដូចខាងក្រោមនេះ ៖

១- ត្រកូល

ទុកណាជា យើងមិនអាចស្រាវជ្រាវរកថ្ងៃខែ ឆ្នាំកំណើតរបស់កវីន្ទ្រ-បណ្ឌិតឃើញក៏ដោយ ក៏យើងអាចរកវង្សត្រកូលរបស់លោកនេះបានដែរ។ ការដែលយើងស្រាវជ្រាវរកឃើញនូវជីវប្រវត្តិ និងស្នាដៃអ្នកនិពន្ធកវីន្ទ្របណ្ឌិតនេះឃើញ ក៏ដោយសារតែសិលាចារឹកខ្មែរ ។

កវីន្ទ្របណ្ឌិត មុននឹងបានឈ្មោះជា កវីន្ទ្របណ្ឌិតនេះ សឹងតែ-

ចារឹកត្រពាំងរុន បានប្រាប់ថា លោកមានឈ្មោះថា ព្រះកម្តែងផលប្រិយ[1] ជាបុត្ររបស់ទានវនាថ[2] ហើយត្រូវជាចៅរបស់លោកគោវិន្ទ ។ គោវិន្ទនេះសោត ត្រូវជាកដបំរើផ្ទាល់របស់ព្រះបាទជ័យវរ្ម័ន នៅដើមសតវត្សទី ៩ ។

អាស្រ័យឯកសារបរទេស និងសិលាចារឹក យើងអាចពិនិត្យទៅឃើញថាកវិន្ទ្របណ្ឌិតមានបុត្រប្រុសម្នាក់ ឯបុត្រដទៃទៀតយើងរកមិនទាន់ឃើញ ។ បុត្រប្រុសរបស់លោក មាននាមប្រាដកថា នាកយណៈឬ កវិន្ទ្រវិជ័យ ។ តែបំណែកមាគាទិងកិរិយារបស់លោកមិនអាចរកឃើញឡើយ ។

កូននេះក៏មានឈ្មោះល្បីល្បាញទៅសម័យនោះដែរ លោកបានធ្វើជាអាចារ្យនៅក្នុងកដពិធីទៀតផង ។

ដើម្បីឲ្យឆាយយល់នូវវង្សត្រកូលនៃកវិន្ទ្របណ្ឌិត សូមលោកអ្នកមើលតាកង់ត្រួសារ ដូចតទៅនេះ :

1- Inscription du Cambodge, volume III. page 271.
2- Inscription of Kambuja, by R. Majumdar, page 332.



គោវិន្ទ
ជយេន្ទ្រទាស ឬ ជយេន្ទ្រលោក : នៅអនិន្ទិតបុរី (កវីជ័យវរ្ម័នទី២)
វាសុទេវ ឬ រុទ្រេន្ទ្រលោក : (កវីជ័យវរ្ម័នទី៣ និងឥន្ទ្រវរ្ម័នទី១)
ប្រទ្យុម្ន ឬ នរវរ (បានសាងលិង្គមួយ នៅឆ្នាំ៨៨០)
សំកមិណា (កវីព្រះបាទយសោវរ្ម័ន, ហស៌វរ្ម័ននិងឥសាណវរ្ម័នទី២)
វរិនាថ (កវីជ័យវរ្ម័នទី៤, ហស៌វរ្ម័នទី២ និងរាជេន្ទ្រវរ្ម័ន)
កូន
បញ្ចាស្យ ឬ កវីន្ទ្របណ្ឌិត
នាគយណ: ឬ កវីន្ទ្រវិជ័យ

២– ងារសក្តិ

ដូចខ្ញុំបានជំរាបមកហើយថា កវិន្ទ្របណ្ឌិតមិនមែនមានឈ្មោះដូច្នេះទេ តែដល់លោកមានចំណេះវិជ្ជាគ្រប់គ្រាន់ហើយ ទើបលោកបានទទួលងារនេះជាខាងក្រោយថា កវិន្ទ្របណ្ឌិត ។ កវិន្ទ្របណ្ឌិតជាសិស្សរបស់ជយេន្ទ្រ បណ្ឌិត តែក្រោយមកព្រះបាទសុរិយវង្សទី ១ បានព្រះរាជទានងារសក្តិពីផលប្រិយ ទៅជាកវិន្ទ្របណ្ឌិតដូចមានគាថា ថា:

តស្សាសិប្បិម្ហិវយ្យៅ យ:
ផលប្រិយ ឥតិរិត:
ត្រីកវិន្ទ្រាតាមាម
បណ្ឌិតាន្តន៍ ឥប្បាជ្ញយា

ប្រែថា :

"សិស្សដ៏ធំរបស់ (ជយេន្ទ្របណ្ឌិត)

ឈ្មោះផលប្រិយ បានទទួលងារសក្តិពីព្រះរាជាថាកវិន្ទ្របណ្ឌិត ។

លោកបានធ្វើជាព្រះរាជគ្រូនៃព្រះបាទជ័យវរ្ម័នទី ៥ (ព្រះបរមវីរលោក" ។

មិនតែប៉ុណ្ណោះ លោកជាអ្នករៀបចំពិធីសព្វសារពើ ថ្វាយព្រះ

បាទជ័យវរ្ម័នទី ៤ ដែលត្រូវរៀបចំធ្វើនៅក្នុងសម័យនោះ ដូចគាថាថា : :

សបញ្ចគវ្យស្តស្យាសី ទ្រាជ្ញគ៌ត្រីជយវម៌្មណៈ
អភិសេកក្រិយាការី គបិាបាយ៉ស្បទាប្តិតៈ

ប្រែថា :

"លោកជាអ្នករៀបចំពិធីថ្វាយព្រះបាទជ័យវរ្ម័ន ឈ្មោះបញ្ចគវ្យបាន ជាកជគ្រូ ដ៏ជាទីគោរពរបស់ព្រះអង្គរហូតមក" ។

លោកបានធ្វើជាតង់ហ្វាងខាងតុលាការនៅ ម.ស. ៩២៦(១) ។

មិនតែប៉ុណ្ណោះ លោកជាសាស្ត្រាចារ្យមួយរូបដែលមានសិស្សគណចូលចិត្តកប់គានសិក្សាជាមួយលោកជាច្រើន។

៣– ចំណេះវិជ្ជា

កវីន្ទ្របណ្ឌិត ជាអ្នកប្រាជ្ញខាងភាសាសំស្ក្រឹតយ៉ាងធំមួយរូប ដែលបានទុកស្នាដៃរហូតមកដល់សព្វថ្ងៃនេះ ។ លោកចេះក្បួនវេយ្យាករណ៍សំស្ក្រឹតយ៉ាងហ្មត់ចត់ ជាអ្នកចេះចាំខាងការតែងពាក្យ ចេះក្បួនខាងសាសនា ការគៈនិងកមាយណៈ ។ ក្រៅពីអក្សរសាស្ត្រ លោកក៏ជាអ្នកនយោបាយមួយរូបសម័យនោះដែរ ។

៤– ស្នាដៃ

លោកកវីន្ទ្របណ្ឌិតជាអ្នកអក្សរសាស្ត្រដែលចេះវេយ្យាករណ៍យល់

1— Insciption of Kambuja. by R. Majumdar, p.315.

ព្យាស់ហើយជាសាស្ត្រាចារ្យទៀតនោះ  បានចារសិលាចារឹកត្រពាំងរុនតាំងផ្នែកសំស្ក្រឹតនិងខ្មែរ ។ សិលាចារឹកត្រពាំងរុននៅខាងនិរតីភូមិដំដែក ខេត្តកំពង់ធំ ចម្ងាយប្រហែល៤គ-ម នៅបស្ចិមភូមិរុន ចម្ងាយពីផ្លូវជាតិគីឡូម៉ែត្រ ២៨០ ផ្លូវភ្នំពេញ សៀមរាប ប្រហែល ១ គីឡូម៉ែត្រកន្លះប៉ុណ្ណោះ ។

៥– បែបអក្សរ

សិលាចារឹកត្រពាំងរុនមានលំនាំបែបអក្សរ  ដែលប្រើសម័យនោះ ដូចតទៅនេះ

ក)- បែបព្យញ្ជនៈ



ខ)- បែបស្រៈនិស្ស័យ :





សិលាចារឹកត្រពាំងរុន ភាសាខ្មែរ ។

# អត្ថបទនៃសិលាចារឹកត្រពាំងរុន

ជាភាសាសំស្ក្រឹត ចារដោយកវីន្ទ្របណ្ឌិត (១)

---

សិទ្ធិ ស្វស្តិ ជយ នមោ ភគវតេ វាសុទេវាយ

១. យេនាធិឞ្ឋិតមវ្យក្ត- មលំ សកលសម្ភវេ
បុរុឞ៑ ស យទិ យោគ្គា វាសុទេវន្នមន្តុ តម៑ ។

២- យស្យ នាភិគវាម្ភោជ- ជន្មនាម្ភោជជន្មនា
ខ្យាតំ បរមកិត្តំ ស្រព្រាគេបតន្ទក្ខតាម៑ ។

៣- មាហាត្ម្យមទ្យ៑ យស្យាស្ត- នាភិជាម្វុជសម្ភវ:
មេរុយិត្រ៑ បទ្មយោនទ្យាទិ- ទេវានាមាទិកលយ: ។

៤- បាទាទ៑ យស្យ ជគទ្វន្ទ្យាត៑[2] ប្រភវន្តី សុរាបគា
ត្រៃលោក្យបាវនី ប្រោហ មហត្វំ បរតោធិកម៑ ។

៥- វាមនស្យ ត្រិភិល្លោកាន៑ ក្រមតោ វិក្រមក្រមៃះ
យស្យាគ្រាហ្យស្វភាវត្វំ វិទ្វទ្ភិរនុមីយតេ ។

៦- វាហុណាបិ វិរុទ្ធានាំ យទ៑យាការគម្ភិណាម៑
អចិវិទ្វិច្ឆ នាមៃវ គតៈទ្វយត្វមុទាហ្ឫតម៑ ។

៧- អនុភេក្យា ‘នុត្តមោ’ វ្យក្តំ យស៑ សវិត្រៃ ប្រវេបនាតិ
អន្តិនិវេគយន៑ ស្វិ មហាទ្រាបិៈ មហាត្តមះ ។

---

១- ខ្ញុំចំលងសិលាចារឹកសំស្ក្រឹតនេះ តាមតែលំនាំដើមទេ ឯអក្ខរាវិរុទ្ធខ្ញុំទុកនៅដូចដើម ។

២.ជគទ្វន្ទ្យ ប្រែភវន្តិ ។

៨. សាម្យំ សវិត្រិ ក្ខុតេហុ          យស្ស សំសេវ្យសេវិនាមី
អគ្គ្យាទេវិ គតិស្តុ          កញ្ញិតាប្បនកប្ពិកត ។
៩. បុរុហោត្តមនាម្វៃ          សមស្តាស្ត្យជតា បកទ
សវិតះ ស្តុជមាខ្យាតំ          បរមត្ថមក្ខ្រិមមី ។
១០. ក្រមេណ ក្រមតោ យស្ស          ត្រិលោកី វរិកគតះ
មុហុលិលាដិកោរស្ត.          មណិហោមាឡ្វិបីថតាមី ។
១១. យត្រៅធសំប្រសត្តិក្យំ          រុទ្រាជៅ សិវក្ខុវតុះ
នមស្តាត្វតាន្តសៃ          វិបុវេ ប្រកវិបុវេ ។
១២. នមត្វំ គុលិនំ យស្ស          ត្រិគុលានិ វិវេជិវេ
យុគបត្រ្តិបុរពោត្.          ជិយស្តុមា ឥវ ត្រយះ ។
១៣. ហិរណ្យរេតសា តត្ត-          ហិរណ្យសត្តូមាច្ចិយេ
ហិរណ្យគេតិយ នមោ          ហិរណ្យាក្សាវជន្ទយេ ។
១៤. អាសីតាការិតេវ្យ៉មី          វហន្ទេវតាធិក្ខធវៃះ
កជា ត្រីជយវម្មិតិ          មហេន្ទ្រាទ្រិក្ខុតាស្យទះ ។
១៥. សោមាន្វយប្រទីបោ យ-          សោក្រមស្យដ្ឋជីវនេ
សោមេគ្វរេ សទា ភត្តះ          សោមសោមោ្យ វហុមត្រិយោ ។
១៦. ជរយេន្ទ្រធាសនាអាក្ខុ- (១)          ខឌ្គិតបុរេពត្តវះ
ជយេន្ទ្រវិលុកាក្សំ យេ-          ស្តស្យ ក្ខុតេក្យាវហត្យុទះ ។

---

១ . . . ក្ខុទគ្គិត . . . > ក្ខុទិ + អគ្គិត . . . ។

១៧- គោវិន្ទនាមោ វិប្បស្ស
វេទវេទង្គវេទិនះ
គោវិន្ទកត្តស្ស សុតោ
យោ គោវិន្ទនិមាប្បតះ ។

១៨- អាត្មានេគ តំ វុឌ្ឍាម្មិ
វលិតប្បិរនាម្មិ ច
កុលទេវានរក្សន្យស៏(១)
សូយញ្ញា សមតិប្បិបតិ ។

១៩. ជយេន្ទ្រវល្លកគ្រាតា
វាសុទេវោ ជយន្យជះ
ក្បតេហ្ប៉កវន្យស្តត្យនោ
រាជ្ញម៏(២) គ្រីជយវម្មណះ

២០- នបេន្ទ្រវល្លភាខ្យាំ យម៏
គ្រីឡាំ គ្រីជយវម្មណះ
តតះ ប្រាប បុនក្បតេហ្ប
វក្ប គ្រីន្ទ្រវម្មណះ ។

២១. តយោគ្រាតា កនីយ្ហោយះ
ប្រខ្យុម្នស្យ គ្រីន្ទ្រវម្មណះ
ក្បត្យម៏ គ្រីនវីពខ្យា-
មណាខ យោ កក្បិកក្តិតះ ។

២២. គ្រីន្ទ្រត្ពលយេ លិង្គំ
មហេក្ការជាម្ភុកប្តិតះ
សំស្ថាប្យ យោខ ទៅ តត្រ
ទាសៃសស៏ សិទ្ធបុរំ យុតម៏ ។

២៣- ភាគិនេយវរស្តចាំ យសិ
សង្កម៏ណនាមប្បក
គ្រីន្ទ្រវម៏សុតស្យាប្តិ
គ្រួយគោវម្មណោ កវតិ ។

២៤- គ្រួយគេវម្មណោ ក្បត្យ-
ស្យ រាជ្ញាស្តខបត្យយោះ
គ្រីមាតិវម្ម គ្រីគាន-
វម្មណោរបិ ចារកះ ។

២៥. សង្កម៏ណស្យ តស្យាបិ
ភោគិនេយោ វក្ប យះ
វវិនាថាហ្វយោ ក្បត្យគិ
គ្រេបគ្រីជយវម្មណះ ។

---

១- កុលទេវានរក្សត្យ-ស្យ . ស្យ . . ។ ២- រាជ្ញគ្រីជយវម្មណះ ។

២៦- យស្តត: ព្រាប្តសន្មានោ ភក្សស្ត ត្បូត្រយោរបិ
ត្រីហបិវម្មិក្ខបាល- ត្រីមព្រាជដ្ឋនូវម្មិណោ: ។

២៧- តស្ស ទប្តា វិក្ខរយិ- សព្វាត្តតស្ស មតស្សតាមិ
បញ្ចតវក្រិកិងានោ យះ បញ្ចវក្រតវណានគ្គ: ។

២៨- គព្ហថាកមតា ស្រោណិ កាវរំ កាវតវិស្តរមេ
ពមាយណញ្ច យោធីត្ស តីមព្រាទបញ្ញដីគបត ។

២៩- កុលកម្មិគ្រគិទ្រវៃរ- វុឌ្ឍ គោះបិ ស្មភាវតះ
វិនយោវិស្មយាគព្រំ យោ ទីថៃពក្ខតិកវគៅ ។

៣០- ជាត្បន្ធ: បវវទ្រុមុ ភ្ញ៉ាវ: បវត្ថហោមុ យះ
ករលៅ បវក្រ ក្ខតាបាវ- មបិ កាលានុប្បវត្ត ។

៣១- (ក) ទព្រាម្ពតស្រុតា យស្ស សត្រៀត្បុទធិវេវ ន
វវិធ សន្ធិគ្គាបិ កាសេវវន្នាហិមាទ្រិត: ។

៣២- ត្រីមព្រាជដ្ឋនូវម្មិត្រ្យ- ស្វទ្ធិយស្សយសន្និក:
ពជា ត្រីជយវម្មិត្រ វៀមមាគ្គាមួកជ្យតាគ ។

៣៣- មហាវិធីកោលក្សវា ទ្វមទ្វិវធវិទ្វិហាមី
អហីនកោគសន្ធា យោ វកៅ វិមវិកបវះ ។

៣៤- ធម្មិជាំ វលិទំ គួរំ ក្ខតវិទ្យ ប្រិយមួទម
យំ ប្រាប្បែកបតិមី ប្បជ ដហាស ទ្របតាគ្គជាមី ។

៣៥- កីណ្ណាដស្ស រណឲប ទ្វមទ្វិវធវិទ្វិហាមី

ស្រស្ដាគ្គនាកបាមោទ- លុវ្វេឌ្ឍភិ យស្ស កីស្សមា ។

៣៦- យស្ស ធូបិតទេត្រេវ កិត្តិយិជ្ជហាវិកុជាមី

ធូមេរកិទ្រុតា ទិក្ស វិវេគាវិបុកណ្យបិ ។

៣៧- សបញ្ចគវ្យស្តស្យាសី- ទ្រាជ្ជគិ គ្រីជយវម្មិណះ

អភិសេកក្រិយាការី តថាបាយិស្សទោច្ចិតះ ។

៣៨- សវៃវណ្ណវមិមាមញ្ចាមិ វិបុណ្កកោ្ត វិធានតះ

បហីធរគតិទ្វារៈ បុរះសិទ្ធិ សមត្តិម្ពបគ ។

៣៩- សកេត្រ្យ កិង្ករគ្រោមមិ សបគុទ្រវ្យ សំយុតមិ

កក្តរាក់ហេរ្យាបបាកចំ ទទៅ ទានវៃរណេ ។

៤០- ធាតាមហាសុតស្តស្យ បញ្ចគវ្យស្យ យោ យតិះ

កៃវសិទ្ធាន្តទិណ្ហាគោ វិធីនាតិម្ពបគ(១)ក្បតី ។

៤១- បក្បកក្តតយា ទេវេ វៃបក្បកេស បិនាកិនះ

លីង្គំ វិនាយកញ្ចមំ វីធីនាតិម្ពបត ក្បតី ។

៤២- និសេវ្យមទម្រាវនិបាលមៅលិ មាលាៈជោក្សិត្រតុគ្គបិថះ

វេទាធិវេទ្ទ្រធិណុំនុធានោ យោ កូបិតគិ គ្រីជយវីរវម្មា ។

៤៣- ទគ្គះ ស្វគិ គីកកលះ កលង្កី

កាន្តិកិវេតិ កុត្រ មទីយសគិ

---

១ -តាបសេចក្តីដើមថា; នន្ទិតាបាយ្បិតាមក្បត់ ។

ឥតិ សុសត្តិតិគយាកិលាហគ្គុំ

កាន្ត្យធិកោ យោ វិវេកេ វិជាគ្រោ ។

៤៦. និច្ចិតពោចា មហាតះ ប្រវត្តា

វិហាយ ក្កុប្បនិវហានវ្យន៑

គវេគ្គវ វិទ្យោ យមនេកមាគ្គ៌

ជគាម ក្ឞ្មា គុណរត្នសិទ្ធម៑ ។

៤៧. ទវោត្ប្យលគ្នាមរុចាមសិនា-

មាឃុណ្ណិតានាម៑ សមទន ទ្វិមទ្ធិះ

ទ្ធពេ្តា ទ្ធតាម៑ រា ហរិរោណក្យណាកិ-

វិរោយាទ្ធិរោគា យស៑ សមជ័រ្ក្កុវ ។

៤៨. ស្វវទ្ធមធ្យ បិ គតារសេនា

សសាធនាប្រាត្ថសុហ្ទ្វតាបិ

ឯកេវ និគ្មាសបរា សមុគ្ឍា

សំស្ទូត្យ យំ កាមវគេវ យោបិត៑ ។

៤៩. ក្រោកំវិជាយោទ្ធតរាហិនីនាម៑

ដេតាសក្កូទ្យោ យុធិ រាជនាគាន៑

យគោសម្ទូតំ លោកកុជាម៑ សមក្យ-

ញ្ចហារ បក្យ្រទ្ធ ឥរោរុសត្វះ ។

៥០. មត្តីតិទេ បេ្យម វិនម្រវគ្គិះ

ព្រាក្សាជិតាយោ មម វញ្ចិតាយោ៖

កិញ្ញាវតេនេតិ រុមេវ កិត្តិំ៖

ប្រិយាបិ យាតា ទបទិក្យ ។

៩១- ស បញ្ចាគវ្យស្តសហ្រាបិ នូបសហ្រាបារយិប្រុង្គវ៖

វក្ខូវតិមតោ មន្ត្រី សទ្ទៈ បុរទគនៈ ។

៩២- កវិន្ទ្របណ្ឌិតាខ្យាមិ សគ្រីញ្ញាមិ វិក្រកន្ទូនធៈ

តោលាទិវិកវៃស្តេន សគ្បតៈ កម្មុក្បតា ។

៩៣- បុរស្តាទស្យ តេស្រ្តមេតិ កប្បាវធិ

តស្មិន្ទ មន្ត្រីវរ ប្រាទា- ញ្ញាម្មោ់ថ ស មហីបតិៈ ។

៩៤- ទត្តមេតតិ ក្សីតេគន តេស្រ្តំ កិលាង្គិតំ កប្បី

ស សូយំ ស្តាបិតេប្រាទាទិ កក្តរា តេតកវិទ្ធិ ។

៩៥- សៅជន្យជន្តុក្វិត្តិន កុលីនំ កុលនន្ទនៈ ។

នាពយណាហ្វយស្តស្យ ស្ទុស្ស្យវិគុនណាករ៖

៩៦- ប្រេម្នា ប្រេយសិ សត្យនៅ តស្មិន្ទ ស សមកល្បយតិ

សតេស្រ្តកិង្គក្រោម ន្ទេវតាច្ចិនបាលនំ ។

៩៧- វិវៃធៈ បត្រៃគលៃខ្យ- ទ្វិជគាលាន្តៃគត្ថសៈ

សាក្សិកិប្បបវៃក្សេត្ថ ម្មិតតក្បវន្ទធំ ។

៩៨- កវិន្ទ្រវិជយាខ្យាំ យតិគ្រិមតិមិ គ្រីបតិប្រិយៈ

វគ្គិ នាពយណាវិទ្យានា- ប្តវិន ពធសម្មតៈ ។

៥៩. តេន ទេវលុកំ រក្សយំ សទាសក្សេត្របាគវំ

បិត្រយញ្ញាបិ កុលំ សវ៌មិ តិ បិត្រា ប្រកល្បិតំ ។

៦០. កត្តិវ្យ នានាវិធយាគនាហំ

គិក្សញ្ញារក្តិយិមកិង្ករៅវៃយះ

លក្ស្មីកឫតស៑ សោៈស្ក សទា យុគាន្តាទិ

យោ លង្ឃយេត៑ កល្បិតមស្យ សិវំ ។

## សេចក្តីប្រែសម្រួលពីអត្ថបទសំស្ក្រឹត

របស់កវិន្ទ្របណ្ឌិត

១_សូមថ្វាយបង្គំព្រះវាសុទេវ ដែលជាម្ចាស់នៃបឋមវត្ថុដ៏បរិបូណ៌ ដើម្បីបង្កើតនូវពិភពលោក ដែលមានព្រះបុរុសៈ មួយចំណែកៈក្នុងពិភពលោកនេះ ។

២- ព្រះអង្គមានគុណសម្បត្តិជាបឋមហេតុ ហើយដែលបានប្រកាសដោយអាទិទេព និងដោយសត្វលោកទាំងអស់ និងដោយព្រះព្រហ្មដែលកើតអំពីផ្កាឈូក ដែលដុះចេញអំពីព្រះនាភីរបស់ព្រះអង្គ ។

៣- ដោយសុតវាចារបស់ព្រះអង្គ គឺព្រះមេរុដែលមានពីកំណើតព្រះព្រហ្ម ហើយនិងអាទិទេពដទៃទៀតក៏ចេញមកអំពីផ្កាឈូកដែលចេញមកអំពីនាភីរបស់ព្រះអង្គដែរ ។

៤– កើតចេញអំពីព្រះបាទ ជាទីគោរពនៃសព្វសត្វទាំងឡាយ នទីទាំងឡាយដែលអាចជម្រះឲ្យបរិសុទ្ធនូវលោកទាំង ៣ បានប្រកាសនូវមហិទ្ធិភាពដ៏ឧត្តមខ្ពង់ខ្ពស់ប្រសើរជាងអ្វីទាំងអស់ ។

៥ រំលែងនូវពិភពៈលោកក្នុងការនិមិត្តរូបជាមនុស្សតឿ ដោយវិរិយៈជំហាន ៣ ធ្វើឲ្យអ្នកប្រាជ្ញមុនីប្រមើលឃើញវិសាលភាពនៃធម្មជាតិរបស់ព្រះអង្គ ។

៦– សូម្បីច្បាំងនឹងមនុស្ស ១.០០០ នាក់ ជនណាដែលមានកិរិយាត្រឹមត្រូវ បានប្រកាសនូវសេចក្ដីស្មោះស្ម័គ្ររបស់ខ្លួន ដោយនាមតែមួយគឺវិស្ណុ ដែលពេញដោយអត្ថន័យ ។

៧– បាក់ធ្លុះទៅក្នុងសម្ភារៈវត្ថុគ្រប់យ៉ាង ព្រះអង្គជាអតិបរមាណូតូចបំផុត ជ្រាបចូលទៅក្នុងចក្រវាឡរបស់ព្រះអង្គទាំងអស់ ព្រះអង្គជាបុគ្គលធំបំផុតជាងវត្ថុដែលធំបំផុតទាំងអស់ទៀត ។

៨– សមត្ថភាពរបស់ព្រះអង្គចំពោះសព្វសត្វទាំងអស់ ដែលមានអនុភាពស្មើនឹងព្រះអគ្និ ហើយនឹងស្មើនឹងអាទិទេពដទៃទៀត គឺព្រះអង្គសម្រាប់ជាអ្នកគោរពបូជាចំពោះអ្នកដែលគោរពបូជាទាំងឡាយ ។ ហើយព្រះអង្គជាមូលហេតុ នៃសោមនស្សនិងទោមនស្ស នៃតណ្ហារបស់សត្វលោក ។

៩– ព្រះនាមរបស់ព្រះអង្គ គឺបុរសុត្តមៈតែមួយប៉ុណ្ណោះ ដែលអាចកំចាត់ចេញនូវសត្រូវដទៃ ១ ហើយប្រកាស នូវឧត្ដមភាពគ្រប់ទីកន្លែងទាំងអស់ ។

១០– ក្នុងពេលដែលពិភពលោកកើតឡើងបន្តិចម្ដង ១ ព្រះអាទិត្យបានទៅជាគ្រឿងអលង្ការខាងមុខព្រះអង្គបន្ដមកទៀត ហើយបានទៅជា

វដីកល្អារសំកប់ព្រះឧក ហើយនឹងអាសន ជាវិការនៃមាសរបស់ព្រះអង្គ ។

១១- សូមគោរពព្រះវិស្ណុដ៏រុងរឿង ដែលមានក្រោធនិងសន្តិឲ្យជាកំណើតនៃរុទ្រៈនិងអជព្រហ្ម ។

១២- សូមថ្វាយបង្គំចំពោះព្រះសិវៈ ដែលមានត្រីសូលជាពុំនឹងនៃជយជំនះដ៏មហាស្ចារ្យលើត្រីបុរ ៖

១៣- សូមគោរពព្រះព្រហ្ម ដែលមានរស្មីដូចជាមាសដែលគេដុតដោយភ្លើងដល់ហិរណ្យគភ៌ៈជាបុត្រនៃបច្ចាមិត្តរបស់ហិរណ្យក្ស ។

១៤- កាលណោះ មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមស្រីជយវម៌ន[1] ទ្រង់សោយរាជ្យរហូតដល់ទៅសមុទ្រ នៅស័ក ៧២៤ (គ.ស. ៨០២) ហើយមានព្រះរាជដំណាក់នៅលើភ្នំមហេន្ទ្រ[2] ។

១៥- ព្រះអង្គជាពន្លឺនៃព្រះវង្សរបស់សោមា ជាព្រះចន្ទធ្វើឲ្យសប្បុរសជនមានអាយុជីវិតឡើងជាថ្មី គោរពព្រះឥស្សូរនិងឧមា ព្រះអង្គមានព្រះទ័យទន់ភ្លន់ដូចព្រះចន្ទ ហើយមានព្រះកាយប្រកបដោយលំអ ។

១៦- កាលណោះ មានបុរសម្នាក់ឈ្មោះជយេន្ទ្រភាសៈ បានទទួលនាមជាជយេន្ទ្រវល្លភៈ មានដើមកំណើតនៅអនិន្ទិតបុរៈ ជារាជបំរើរបស់ព្រះរាជា ។

១៧- រាជបំរើនេះ ជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ឈ្មោះគោវិន្ទ ដែលជាអ្នកចេះចាំច្បាស់នូវវេទៈនិងវេទង្គៈ គាត់ជាអ្នកគោរពគោវិន្ទ(វិស្ណុ) ហើយ

---

១- ជ័យវម៌ន ។ ២ ភ្នំគូលេន ។

បានធ្វើរូបសំណាកគោវិន្ទផង ។

១៨. នៅក្នុងស្រុកកំណើតរបស់គាត់ឈ្មោះតំរ៉ុង និងវលិការបុរ:គាត់គោរពទេវតាដែលនៅក្សេត្រ របស់គាត់ ហើយគាត់សាងរូបទេវតាថ្មីៗទៀតជាច្រើននៅក្នុងភូមិតាំងនោះ ។

១៩. ប្អូនរបស់ជយេន្ទ្រវល្លភ: ឈ្មោះរ៉ាសុទេវជាព្រះរាជបំរើ នៃព្រះបាទជយវរ្ម័ន(១)ជាព្រះរាជបុត្រនៃព្រះឧទជយវរ្ម័នទី ១ ។

២០- គាត់បានទទួលនាមដ៏គាប់ប្រសើរ ម្យ៉ាងទៀតថានរេន្ទ្រវល្លភ: អំពីជយវរ្ម័នហើយបន្ទាប់មកបានធ្វើជារាជបំរើ នៃព្រះបាទឥន្ទ្រវរ្ម័នទី(២) ។

២១. ប្អូនបន្ទាប់នៃបងទាំងពីរនាក់ខាងដើមឈ្មោះប្រទ្យុម្ន ជាព្រះរាជបំរើនៃព្រះបាទឥន្ទ្រវរ្ម័ន ហើយដោយភក្តីភាពចំពោះព្រះអង្គ គាត់បានទទួលគោរមងារជាគ្រឹនវើរ: ។

២២- គាត់បានកសាងសម្ភុលិង្គនៅសកករាជ ៨០២ ហើយតម្កល់ទុកនៅក្នុងប្រាសាទគ្រឹតវេន្ទ្រគិរ:(៣) ហើយគាត់បានថ្វាយសទ្ធាបុរ:និងខ្ញុំកំដរជាច្រើនទៀតផង ។

២៣- កូនប្រុសរបស់បងស្រីគាត់ ឈ្មោះសំកសិណ:បានទទួលនូវសេចក្តីប្រោសប្រាណឲ្យនៅក្នុងសំណាក់ព្រះបាទយសោវរ្ម័ន ជាព្រះរាជបុត្រនៃព្រះបាទឥន្ទ្រវរ្ម័ន ។

---

១ ជយវរ្ម័នទី ៣ វិស្ណុលោក (គ.ស.៨៥៤-៨៧៧) ។ ២- ឥន្ទ្រវរ្ម័នទី ១ (ឥស្វរលោក គ.ស. ៨៧៧-៨៨៩) ។ ៣ ប្រាសាទនេះសព្វថ្ងៃហៅថាប្រាសាទបាគងនៅរលួស ។

២៤- រាជបំរើ(សំកសិណា) របស់ព្រះបាទយសោវរ្ម័ន បានធ្វើជារាជបំរើនៃព្រះរាជបុត្រទាំងពីររបស់ព្រះអង្គ គឺហសិវរ្ម័ននិងឥសានវរ្ម័ន (១) ។

២៥- កូនរបស់បងស្រីសំកសិណា: ឈ្មោះវិនាថា ជាព្រះរាជបំរើដ៏ជំនិតរបស់ព្រះបាទជយវរ្ម័ន(២) ។

២៦- ដោយបានទទួលកិត្តិយសអំពីព្រះអង្គលោក(វិនាថ)ក៏បានធ្វើជារាជបំរើព្រះរាជបុត្រទាំងពីរព្រះអង្គ នៃព្រះបាទយសោវរ្ម័នគឺព្រះបាទហសិវរ្ម័ននិងរាជេន្ទ្រវរ្ម័ន (៣) ។

២៧- ចៅរបស់លោកដែលជាសិស្សដ៏ឧត្តមនៃក្រិស្នះ (សាត្តក:) ហើយជាមនុស្សមានធម៌សប្បុរសបានទទួលនាមថា: បញ្ញាគវ្យ: ជាអ្នកចេះចាំស្ទាត់នូវវេយ្យាករណ: ។

២៨- ដោយលោកបានចេះវេយ្យាករណសាស្ត្រ នយោបាយសាស្ត្រសាសនសាស្ត្រ កាវ្យសាស្ត្រ ក្បួនកាត:និងរាមាយណ: យ៉ាងស្ទាត់ លោកក៏បានធ្វើជាសាស្ត្រាចារ្យថែមទៀតផង ។

២៩- ទោះជាមានវណ្ណ:ដ៏ឧត្តមក្តី ទោះជាបានបំពេញកិច្ចដ៏ថ្លៃថ្នូក្តី, ទោះជាមានចំណេះវិជ្ជា និងសម្បត្តិដ៏បរិបូណ៌ក្តី លោកក៏នៅតែកាន់កិរិយាសុភាពរាបសាស្រគត់ស្រគំជាដរាប ។

៣០- កំហុសរបស់អ្នកដទៃ លោកមិនអើពើជាចំអហង្ការ លោក

---

១- ហសិវរ្ម័នទី ១ (រុទ្រលោក) ។ ២- ជយវរ្ម័នទី ៤ បរមសិវលោក ៩២៨-៩៤២ ។
៣- ហសិវរ្ម័នទី ២ (៩៤២-៩៤៤) និងរាជេន្ទ្រវរ្ម័ន (៩៤៤-៩៦៨) ។

វៀរចាកគិលេសតណ្ហាជាដាច់ខាតទាំងអស់ សូម្បីតែទៅក្នុងពារបរិយក៏
លោកប្រតិបត្តិនូវក្កូត សាស្ត្រដែរ ។

៣១- លោកមានគុណវិស័យដូចសាគរ ប្រកបដោយកក្តីជំនិងនិន
សំដែងអាការៈដ៏ថ្លៃថ្នូរមានតម្លៃដូចទឹកអម្រឹត ប្រៀបដូចជាថ្មសិលាមួយមិន
អាចនឹងរំពេរលេដោយសារដំណក់ទឹកដ៏ត្រជាក់ ដែលធ្លាក់មកពីលើមហា
មេឃ ។

៣២. ព្រះរាជបុត្រច្បងនៃព្រះបាទពកដេន្ទ្រវរ័ន្ទ មានបារមីដូចជាព្រះ
អាទិត្យទ្រង់ព្រះនាមថាព្រះបាទជ័យវរ័ន្ទ (១) បានឡើងគ្រងរាជ្យនៅសក:
៨៩០ ។

៣៣- ព្រះអង្គមានចរិយាសមសួនឥតខ្ចោះ ប្រកបដោយព្រះរាជ
សម្បត្តិបរិបូណ៌ មានព្រះទ័យស្អប់បច្ចាមិត្រនៃព្រះអាទិទេព ទ្រង់ស្ថិត
នៅក្នុងព្រះបរមសុខប្រកបដោយគតិបណ្ឌិតដ៏ថ្លៃថ្នូរ ដូច្នេះហើយបានជា
ព្រះអង្គមានស្នេហ៍ដូចជាព្រះវិស្ណុមួយព្រះអង្គទៀត ។

៣៤. ព្រះធរណីចំអកមើលងាយក្សត្រីនៃទ្រុបទ: កាលដែលស្រី
នេះរៀបអភិសេកជាមួយព្រះអង្គឯក អ្នកប្រាជ្ញខាងធម្ម មានមហិទ្ធិឫទ្ធិក្លា
ហានមានវិជ្ជាច្រើនមានព្រះមធុរវាចា ។

៣៥- សព្រួញរបស់បច្ចាមិត្រ ដែលបាញ់មកនៅក្នុងពេលចម្បាំង
ទៅលើស្ដេចអង្គនោះ ដែលមានព្រះអង្គរាងធំទូលាយ ធ្វើឲ្យព្រះអង្គព្រឺ

---

១- ព្រះបាទជវរ័ន្ទទី ៥ (ឃរមរិរពេក ៩៦៨-១០០១) ។

ស៊ើបត្រឹមស៊ើនឹងទ្រទិចឃ្មុំ ដែលស្រែកឃ្លានក្នុងកេសា នៃស្ត្រីទន់ខ្សោយៗ

៣៦- កិត្តិគុណរបស់ព្រះអង្គ ផ្សាយទៅក្នុងចតុទិស រហូតទៅដល់ធានីនៃបច្ចាមិត្ររបស់ព្រះអង្គ វិស័យដូចផ្សែងនៃគ្រឿងសក្ការៈបូជាដែលធ្វើឲ្យក្អកល្អក់នឹងផ្សែង ។

៣៧- លោកដែលរៀបចំពិធីថ្វាយព្រះបាទជយវរ្ម័ន ឈ្មោះ បញ្ចគវ្យ បានធ្វើជាកដគ្រូដ៏ជាទីគោរពរបស់ព្រះអង្គរហូតមក ។

៣៨- លោកជាអ្នកគោរពព្រះវិស្ណុ បានឲ្យសាងរូបព្រះវិស្ណុមួយ ទុកជាទីសក្ការៈបូជានៅក្នុងទីក្រុងនោះ ។

៣៩- លោកបានធ្វើអំណោយ ដោយសេចក្តីមេត្តាចំពោះបច្ចាមិត្រនៃពានរ: ដែលបានបំពេញកិច្ចការក្រៅជូនលោកនូវក្អមមួយ ព្រមទាំងចំការច្បារដំណាំមានទាំងមនុស្សបំរើ គោក្របី និងប្រាក់កាសផង ។

៤០- អ្នកចាត់ចែងពិធីនោះជាបុត្រដ៏ល្បីល្បាញរបស់បញ្ចគវ្យ ជាអាចារ្យដែលចេះចាំច្រៀងស្រែះទូលទ្ធិព្រះឥស្សូរ ហើយបានកសាងបដិមា-ករព្រះឥស្សូរមួយតាមទំនៀម ។

៤១- ដោយសេចក្តីស្នេហាចំពោះបិតាព្រះអង្គ ទ្រង់បញ្ជាក្នុងព្រះយោបល់ដ៏ឈ្លាសវៃនិងគម្រូវតាមទំនៀមទាន ឲ្យសាងសិវលិង្គ និងរូបគណេសក្នុងស្រុកបិតាព្រះអង្គ ។

៤៦ • ព្រះបាទជ័យវរ្ម័ន បានជាម្ចាស់ផែនដីនៅសកកដ ៩២៤ ។ ព្រះអង្គមានកំណល់ព្រះបាទជាវិការនៃមាស ស្ថិតនៅលើសុវណ្ណមាលា ដែលធ្លាក់ពីសិរសា នៃស្តេចទាំងឡាយ ដែលយាងមកក្រាបថ្វាយបង្គំព្រះអង្គ ។

៤៣ ដោយសេចក្តីស្នេហាបាននាំមកឲ្យមានការគាក់ខាន ព្រះចន្ទមានការគាប់អួរ តើធ្វើដូចម្តេចនឹងរកសិរីសួស្តីក្នុងការស្ថាបនា?ហេតុដូច្នោះ ដោយព្រះអាទិទេពដែលមានព្រះទ័យចង់បង្កើតឋានៈសត្វដែលលោកបង្កើតឡើងឲ្យមានឋានៈខ្ពស់ ទើបព្រះអង្គបន្ថែមនូវកល្យាណធម៌ទៀត ។

៤៨· វិទ្យាសាស្ត្រមានមាតិច្រើន តម្រង់ឆ្ពោះទៅរកមហាសាគរនៃ ( កល្យាណធម៌ ) ពីព្រោះវិទ្យាសាស្ត្រនោះបរិសុទ្ធដោយអំណាចព្រះអាទិទេព ដោយមិនបានយកបត្តុទុកដាក់ជល់ក្នុងទាំងឡាយលើផែនដី តួយ៉ាងដូចទឹកទន្លេគង្គា ។

៤៩· ទោះជាឃើញមុខងាររបស់សត្រូវ ឆាគ្រីដោយសេចក្តីប្រណែនប្តូនត្រារបស់ស្ត្រីសំឡក់មកចំពោះព្រះអង្គ ព្រះអង្គនៅតែមានសេចក្តីអង់អាចជាដំកប នៅតែរក្សាទឹកព្រះទ័យឲ្យស្ងប់ស្ងៀម មិនឲ្យរន្ធត់ញាប់ញ័រដូចជាផ្កាល្អូកៈដែលរក្សានូវពណ៌ទៀត ។

៤៦. កិរិយារបស់បច្ចាមិត្តនៃព្រះអង្គ សូម្បីតែនៅជួបជុំគ្នាក្នុងគ្រួសារ ប្រកបដោយកាយពលបរិបូណ៌ មានមិត្តភក្តិនៅជុំវិញក្តី កាលបើទីពបច្ចាមិត្តទៅបាត់ហើយក៏នៅតែនឹកមមៃចំពោះព្រះអង្គ ហាក់ដូចជានៅស្ងាត់ម្នាក់ឯង ត្រមង់ត្រមោចអាណោចអធមព្រោះលង់ទៅក្នុងសេចក្តីស្នេហា ។

៤៧. ព្រះអង្គមានជ័យជំនះលើស្តេចទាំងអស់ ក្នុងពេលសង្គ្រាមជាច្រើនលើក ដោយហេតុព្រះអង្គមានឫទ្ធានុភាពធ្វើកងទ័ពមានអំណាចឲ្យមានកង្វល់ ហើយព្រះអង្គដណ្តើមបានទូកិត្តិយសដ៏អស្ចារ្យក្នុងចំបាំងប្រៀបដូចបក្សីព្រាបដែលមានថាមពលខ្លាំងក្លា ។

៤៨. បើនរណាកូតសរសើរព្រះអង្គ ព្រះអង្គទម្លាក់ព្រះភក្ត្រចុះដោយអឹមអៀន ។ បើខ្ញុំត្រូវស្រូបហារបោកបញ្ឆោតហើយ តើមានប្រយោជន៍ធ្វើដឹងនៅរស់ ។ ប្តីបើកិត្តិគុណជាការពាំបាច់របស់ខ្ញុំតែកិត្តិគុណនេះហាក់ដូចជាមានកំហឹងហើយ បេញចាកទៅក្នុងទិសទិស ។

៤៩. បញ្ញាវ្យជាអាចារ្យធំរបស់ព្រះរាជាអង្គនេះ ជាទីប្រឹក្សា ដ៏ជាទីគោរពមានសិទ្ធិចូលក្រាបបង្គំគាល់ព្រះអង្គក្នុងព្រះរាជដំណាក់ផ្ទាល់បាន ។

៥០. ដោយលោកមានប្រាជ្ញាដ៏វាងវៃ លោកបញ្ញាវ្យក៏បានទទួលនាមជាកវិន្ទ្របណ្ឌិត ហើយព្រះរាជានៃប្រទេសកម្ពុជា បានព្រះរាជទានអគ្រង៏នស្នេងព្រមទាំងលក្ខណសញ្ញាដទៃទៀតជាច្រើន ។

៥១. ព្រះរាជាបានមានព្រះឧង្ការ ឲ្យបោះគោលចំណាដមួយដុំក្នុងព្រះរាជអាណាចក្រ ហើយព្រះរាជទានទីនោះឲ្យលោក (កវិន្ទ្របណ្ឌិត) ជា

ទីប្រឹក្សារបស់ព្រះអង្គដើម្បីសង់ទីលំនៅ ។

៩២. ដីដែល (គរិន្ទ្របណ្ឌិត) បានទទួលពីព្រះរាជានោះ លោកក៏បានវេរថ្វាយចំពោះវិស្ណុ ហើយលោកបានកសាងរូប (ព្រះវិស្ណុ) ដោយខ្លួនលោក ដោយសេចក្តីអនុគ្រោះ ។

៩៣. កូនរបស់លោកឈ្មោះ នារាយណៈនេះ ជាបុត្រមានត្រកូលខ្ពង់ខ្ពស់ ជាអ្នកប្រាជ្ញ ជាអភិជន ជាទីសួស្តីក្នុងគ្រួសាររបស់លោកបានន័យថាជាវរជនមានលក្ខណៈដូចជា (បិតា) ។

៩៤. ដោយសិនេហាភាពចំពោះកូន បិតាបានឲ្យកូនព្រមទាំងស្រែចំការខ្ញុំកំដរ ហើយប្រគល់ភារៈឲ្យកូនជាអ្នករក្សាអាទិទេព (ព្រះវិស្ណុ) ។

៩៥. លោកបានបញ្ជាក់នូវអំណោយនោះ ជាលាយលក្ខណ៍អក្សរសរសេរនៅលើស្លឹករឹត ហើយនៅលើផ្ទាំងសិលានៅក្នុងសាលាព្រាហ្មណ៍ដោយមានកសិណផងនឹងតាមព្រះរាជបញ្ជាផង ។

៩៦. នារាយណៈនោះជាកូនគោរពព្រះវិស្ណុមានវោហារ ដ៏ពីរោះព្រះរាជាបានលើកតម្កើងឋានៈជាគរិន្ទ្រវិជ័យ ។

៩៧. ដោយគរិន្ទ្រវិជ័យនេះហើយបានជាប្រាសាទតម្កល់រូបព្រះវិស្ណុមានអ្នកថែរក្សា ព្រមទាំងខ្ញុំកំដរស្រែចំការសត្វពាហនៈ ព្រមទាំងគ្រួសារទាំងបិតាទាំងអស់នោះហើយព្រមទាំងបណ្តាំនៃបិតា :

៩៨. បើនរណាមិនគោរពតាមសេចក្តីបង្គាប់របស់ (គរិន្ទ្របណ្ឌិត) ទេ អ្នកនោះនឹងត្រូវទណ្ឌកម្មរបស់ពលយមករហូតអស់មួយយុគៈ ។

# អត្ថបទនៃសិលាចារឹកត្រពាំងរុន

## ជាភាសាខ្មែរ

កវីន្ទ្របណ្ឌិតនិពន្ធ

(១)[១] ៩២៩ សកបិកេតជ្យេស្ឋ គុក្រវារអារទនក្សត្រធ្ធ-លិវ្រះកម្រតេងអញ គ្រិជយវីរម្មទេវ (២) ស្វេយវ្រះរាជ្យនុគ ក ៩២៤·០ [២] ស្តាប (ឆ) វ្រះគិលាតតាក [៣] វ្រះគិយគោ ធរបុរីបិ (៣) ម្រតាញខ្លោង គ្រិកវីន្ទ្របណ្ឌិត ស្រុកវិវង្ក្រៅ . . . បុរនិវេទកគ្លោកបិ ស្ទុំ ភូមិវ្រះករុណាប្រសាទលេង(៤) ជាវ្រះទានបិជ្វន្តវ្រះកម្រតេងអញឆាវាយនម៉ន ម្រតាញខ្លោញស្ទាបឆាតស្រុក វ្រៃករងតិអជិ (៥) ម្រតាញខ្លោញ តោយមាត្របក្សទារវ្រះករុណាប្រសាទគិវ្រះរាជ្យវ្រះបាទបរមគុរ[៤] ០វ្រះករុណាកម្រតាញ (៦) តនត្បូងវ្រភូមិបិខ្មុម្រតាញខ្លោញបង្គ្បើងនិវេទឆម៉នមាន ភូមិអនិគ្សិបបុតនិម្មិល(៧) បិអាយត្តតាកផ្ទាលគុសតោយប្ដូរ ស្រុកវ្រៃករងបិសមិបនុវ្រះម្រតាញខ្លោញនោះគិបិម្រតាញ (៨) ខ្លោញស្ទុំលេងវ្រះទាន បិជ្វន្តវ្រះ អាយ

---

១- លេខរៀងបន្ទាត់សិលាចារឹកនៅផ្ទាំងថ្ម ។ ២- ០ ជាល្បះដែលគេប្រើនៅសម័យនោះ។ ៣- ប្រហែលជា „វ្រះ. លាតតាក” ប្រែថាស្ពានភ្នំ ទេដឹង ។ ៤- ស្តាយណាស់ដោយគ្រឿ មិនសម្បូណ៌ អក្សរ [illegible] ។

ព្រៃករងបុស្សនៃព្រះករុណាកម្រតាញខ្លាញ ឱយប្រសាទ (៩) ភូមិនោះជាព្រះទាន ០ អ្នកសញ្ញក្តសេរិតនោះនាព្រះទ័យប្រសាទ ភូមិកម្រតាញខ្លាញ (១០) ម្រតាញខ្លាញគេ៌ប្រឹ ឞិរិន្ទ្រវម៌្ម ០ ម្រតាញតោញខ្លាញគេ៌ភាគិ គួរវម៌្មស្តេង អ័ញតរញ៉រៀងម្រតាញ ខ្លាញឞិ(១១) គេ៌ករិន្ទ្រវិជយស្បង្តគុណទោមទរស្ស៊ែស្តេង ទន្លេ ព្រៃអាចាយ៌្យប្រធាន សភាសត ០ ម្រតាញខ្លាញ(១២) គេ៌រា សម្កស្ស សូតព្រះធម្មសាស្ត្រ ០ ម្រតាញខ្លាញ គេ៌ក្សិតិន្ទ្រវម្ម ខ្លាញគ្លំឯក០ ម្រតាញខ្លាញគេ៌នួបតិន្ទ្រ(១៣) វម៌្មខ្លាញគ្លាំង ទោម្រតាញខ្លាញគេ៌ក្សិតិន្ទ្រវម៌្មខ្លាញគ្លាំងត្រិណិម្រតាញខ្លាញ គេ៌ នរេន្ទ្រ បណ្ឌិតបាមព្រះបញ្ជិយ (១៤) ព្រះ បន្ទូលស្តេង អ័ញ ទន្លេព្រៃប្រទៅឱយភូមិនោះ កម្រតាញខ្លាញ ជាព្រះ ទានព្រះបន្ទូលប្រស្តេង (១៥) អ័ញទន្លេព្រៃគុណទោ រ៉ែទ ត្តុំផៅង ស្បង្គបុញ្យកឋាតកម្រងតេងអ័ញព្រះគុរម៉ែន ឱយករុណា ប្រសាទ(១៦) ភូមិកម្រ តាញខ្លាញ គេ៌ករិន្ទ្របណ្ឌិត ព្រ សបក្ស្ល ព្រះសភាផៅង អាយព្រះសភាស្តេងអ័ញទន្លេព្រៃ (១៧) គុណទោ ... ប្រៅងស្ត្គញ ... បានោះជាព្រះគាសបគពិកប្រ

តេងអ៊ញព្រះគ្រូកម្រតេងអ៊ញព្រះគរុបន្ទូល (១៨) ព្រះគាសនត
លោញ គ្រឹធរភាគវតបម្រេព្រះក្រលាសោងតខ្លោញ សំតា
បន្ទាបយោគ្យ៉ងរ្យវិបារាធិ (កាធិ) (១៩) ការិ ន្ទាបរាបទគ
ធិតតរង្វាងឯកប្រេទៅន្ទស្តេងអ៊ញខ្នេព្រៃ ប្រេច្ញុំយោព្រះគា
សនស្តេងអ៊ញខ្នេព្រៃ (២០) ន្ទព្រះសភា រង្វាងទៅល្មោះតគិ
ស្រុកព្រៃករងស្តេងអ៊ញខ្នេព្រៃប្រេ រង្វាងទៅបោគ្រាមវ្ទូ
បុរស (២១) ប្រធានតសម៌បន្ទស្រុកព្រៃករងបុំប្វាន តោយ
បន្ទូលព្រះគាសនប្រេស្យង តយុគបតនាគង្វោលតភូមិ (២២)
តោះបិឱយកម្រតាញខ្លោញគ្រឹកវិន្ត្របណ្ឌិតតគិ ទគម៌រោបធ្យេ
ម្ហតោសៅរវារវេរតិនក្សត្រស្តេងទខ្នេព្រៃ (២៣) ន្ទព្រះសភា
បង្គោល តភូម្យតោះឱ្យជាព្រះទានកម្រតាញខ្លោញរោះបាព្រះ
គាសន (២៤) ម្រតាញខ្លោញជួន្តព្រះកម្រតេងអ៊ញនរាយន
អាយព្រៃករង គ្រាមវ្ទូតជាសាក្សិនាំសង្គោលខ្លោញ (២៥)
វលប្វាញត្រេះរើលា ០ វាបទគគ្រាមស្រុកអង្វាជិត ០ វាបបាំ
ស្រុកត្រវាងគ្រូ ០ វាបគម ប្រធាន (២៦) ស្រុកកំលុងលំវាង
០ វាកេត្យរ ទគគ្រាអត្រាកកំពុងពាំវាងតរុត ០ ម្រតាញព្រះទូក

លេ យោគរាយគខ្ញុំព្រះ (២៧) ប្ដ្វលបាសស្រុកវ្រៃករងសិប្បទ្ធ យវិន្ទុខ្ញុំកំស្តេង បរាជិតស្រុក្កត្ដាលវលរាបព្រៃគ្រាប្បទ្ធ ស្តេញ (២៨) ប្រត្យុយស្រុកសម្វិប រាបទគគ្រាមស្រុកទាន្យកតិក រាបគិរព្រាហ្មណ រាបប្រ រាបទាន បរាឯមរាប (២៩) វិទ្យាមយ ខ្លោញផ្កាលអ្និន[1] រាបបិត មេអ្សក មេនំមេទេស មេសាន មេទូត នេះស្បេង ស្រុកអមរាលយ (៣០) ម៉នស្តេងអ៉ញទន្លេ ជ្រៃវិងអំវិសង្គោល ត ភូមិបិ ឱយកម្រតាញខ្លោញ ០ ព្រះស្តាប អាយព្រះបតុទ្វារ (៣១) នាមេលព្រះរម្ពតគិប្រេប្វៃនម្នាណ ០ ម្រតាញខ្លោញ គ្រឹករន្ទ្រិបណ្ឌិត ស្វតគ្លោកនាព្រះវីប្ណុ ធម្មបង្គម ប្យេង (៣២) និវេទនពោះហាផលផ្លេយឱយ ទានភូមិស្តេងអញ ទន្លេជ្រៃបង្គំ ប្យេងនិវេទនម៉នមានភូមិតគិខ្លោញផ្កាល (៣៣) អនិនលកផ្ដាត អ្នកតបួលកំលុងប (ង្វា) ត គោលនោះបិអ្នក រោលរាទព្រះគាសនិប្រេទៅស្វេងបិត្យង (៣៤) នាមានភូមិតនិ អូលិ ប្រេឱយស្មោង ៰ ស្តេងអ៉ញទន្លេជ្រៃនុម្រតាញខ្លោញគ្រឹ ប្រឹបិវិន្ទ្រវម្មិនគុណទោគទស្សិ៍ (៣៥) ផោង្វបុញកបាពោះហាព្រះ

---

(១) ជាពាក្យសង្ខេបពីពាក្យថា អនិន្ទិតបុរ

គាសនតកម្រតាញអញគ្រីគុរុ ០ កម្រតែងអញវ្រះគុរុបន្ទូលវ្រះ
(៣៦) គាសនគលោញវ្រហ្មភាគវិតបម្រេតខ្មោញសំតាបនុម្រ
តាញគ្រីគ្រុតភក្តិតជិតខ្លោញសំតាបនុ (៣៧) រង្វាងឯក ប្រេ
ទៅថ្ងៃពោះឞាវ្រះគាសនវ្រះសភាតពោះឞានេះទៅ ល្វោះតស្រុក
វ្រៃកង្វ ប្រេរង្វាង (៣៨) ឞៅគ្រាមវ្នុទបញ្ជូតោយស្រុក្ក
បន្ទូលវ្រះគាសនឱយគបឋិតឆ្បងទឞមានភូមិ វិណ្ណាំគ្រមតនិ
(៣៩)ម្ទិល ០ គ្រាមវ្នុទស្បង្គគបឋកជារភូមិ អនិនតនិម្ទិល
តោយក្រៅគោល ០ វ្រះសភាវិសអំរុងភូមិតមាន (៤០)អបវិទ
កំលុង គោលទេបវិសអំរុងភូមិតនុជាស្តោងម្វាយអំរុងសង្គោល
សមក្បូនុគ្រាមវ្នុទបុរុប (៤១)ប្រធានផោងបន្ទូលវ្រះគាសនតវិ
បតិមត្វយ្យស្រុក្កលុងលំវាងនុភិក្បុវ្រះស្រមោតមានភូមិ (៤២)
ប្វលកំលុងគោល . . . ភូមិនោះស្តោងម័នវ្រះស្តាបនាវ្រះគិលាត
តាកនាវ្រទិកតវ្រះទានបិឱយត (៤៣ ) វ្រះបំ ( . . . ម្រតា ) ញ
ខ្លោញគ្រីករិត្រ្មបណ្ឌិតបង្គំប្រ្យុង្ស៊ិវេទនម័នភូមិស្រាបតិវ្រះសភាទៅ
(៤៤) ឱយស្តោង . . . ផោង ០ វ្រះគាសនប្រេសិទ្ធភូមិនោះ
អ័នឱយភានកម្រតាញខ្លោញតរាបផ្ទេកបៅ (៤៥) នោះមាន. . .

(ម្រតាញខ្លោញ) បង្គំប៉្បងនិវេទសោតលេងអាប្តិទុក្តព្រះវក្តអា
យព្រះសភាលេង (៤៦) អាប្តិបារតិគិលា... ព្រះព្រាហ្មុគាណា
លេងអាប្តិទុក្តផ្កាត នាប់រេព្រះក្រលាស្រោងលេងអាប្តិទុក្ត (៤៧)
ប្រគស្តត... (ស្រុ)ក វៀកវងលេងវ៉ាអាប្តិ កុលសត្តានម្រ
តាញខ្លោញយោកភូមិនេះបលក (៤៨) ផ្តាតអ្នក.. .អវធិត
អំបាលនេះរោះបាតិប្តូម្រតាញខ្លោញ ០ ភូមិព្រះទានតទិង (៤៩)
ផ្វាយ... បិតទិងប្វាយប្លូវិគតវ្យៀវផែបិ ១៩ បន្តោយប្វាយ
ស្លឹកគត..(ប្វា)ន (៥០ )ភូមិ.. .ល្មោះគោលឱត្តរឱត្តរតេរី
នៅវិស្លិក ១គតវ្យេះ ៥០(៥១)ក្វនម្រ (តាញខ្លោញគ្រីកវិន្ទ្រ)
បណ្ឌិតតង្ហះលោញនារាយណទារង្ហះម្រតាញគ្រីកវិន្ទ្រ (វិជ័យ
...) កន្ទ្រង្ស៊ (៥២ )បម្រេព្រះក្រលាស្រោងជារាជបុរោហិតឱត្តរ
ម្រតាញខ្លោញតាបាម្រតាញបង្គំប៉្បង (៥៣)និវេទនកុលេម្រ
តាញគ្រីកវិន្ទ្រវិជយម្វាយមូលនុលេម្រតាញខ្លោញ នាភាគវិតបំ
ប្រេទហ (៥៤)កុលេម្រតាញខ្លោញ មលតកលេម្រតាញគ្រីក
វិន្ទ្រវិជយអាបទហាកុលេម្រតាញគ្រីកវិន្ទ្រវិជយ (៥៥) មូលតកុ
លេម្រតាញខ្លោញអាចារ្យភាគតា ព្រះកម្រតេងអញតារាយ

ណានភូម្យាក[១]ខ្ញុំ (៥៦)ផ្លើយនោះអាយត្តតកុលម្រតាញ គ្រឹក
វិន្ទ្រវិជយនាភាគព្រះកម្រតេងអញគិរិលិង្គនុ(៥៧) ខ្ញុំភូម្យាផ្លើយ
អាយត្តតក្វនម្រតាញខ្លាញ តោយភាគកុលេស្តេងនត្និកាបាយ្ស៊
(៥៨)អាយ្ស៊ប្រោមបិចាំតសំមូលនុម្រតាញខ្លាញផ្លើនាភាគវិត
បំរេនេះ កល្បនាតពោះនេះ(៥៩) នៅរកុលេម្រតាញខ្លាញ
កុលអ្នកនេះតរ្យូវ លោះតមានភក្តិបរិបាលនលេងពោះហានេះ វ្វំ
(៦០)អាប្តបនហ្យតទមាន្តបនហ្យតកល្បនានេះបញ្ចុ (?) តរិ្យូវ
បារ កម្រតេងផ្អែកពោំ ឆិណ្ណាយត (៦១)តបរលោកព្រះយមយា
នាតនរកតទំទេប្រអវិបីល្វះសង្ស្វារ ០ នាភូមិភាគ ០ ភូមិ ឧត្តរនុ
(៦២ ភូមិព្រះទានតិម្រតាញខ្លាញផ្ទន្តព្រះម្រតេងអញនារាយណ
ភូមិតិទក្សិកណានុស្រេះព្រះទានបិ (៦៣) តិម្រតាញខ្លាញផ្ទន
តកម្រតេងអញគិរិលិង្គ ។

## បទានុក្រម

*សិលាចារឹកនេះ ខ្ញុំមិនបាច់សរសេរតាមបែបភាសាខ្មែរយើងសម័យ បច្ចុប្បន្ននេះទេ ខ្ញុំគ្រាន់តែជូនពាក្យខ្លះដែលលោកអ្នកអានមិនធ្លាប់បាន ឃើញដូចតទៅនេះ :*

---

១ កកតី ភូបិ ភូបិក ក្រកកាក់កាក់ភូបិ ។

| | | | |
|---|---|---|---|
| កអោំ | ក្រោម | ផោង់ | ផង |
| កម្រតេង | គម្ដែង | ផ្លើយ | ផ្លែ |
| កេត | កើត | ម័ន | មុ័ន |
| ក្រលះស្រោង | ក្រទ្បាស្រង់ | ម្រតាញខ្មោញ | គម្ដែងខ្លោង |
| គ្ល័ង | ឃ្លាំង | ម្វាយ | មួយ |
| ឃោ | ឃោសកៈ | ឈោញ | ខ្លោញ |
| ញាម | ញាំ | ល្ងោះ | លុះ |
| ជ្ងត្ត | ជួនដ៏ | វល | ពល |

# ផ្នែកកំណត់-ប្រវត្តិការណ៍

ពុទ្ធសាសនបណ្ឌិត្យ ព្រះរាជាណាចក្រកម្ពុជា

## សេចក្តីជូនដំណឹង

## អំពីលទ្ធផលនៃការប្រឡងប្រជែងខាងទំនៀមទម្លាប់

## នៅឆមាសទី ១ ឆ្នាំ ១៩៦៩

ក្រុមទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ មានសេចក្តីរីករាយ ទន្ទឹងផ្សាយដំណឹងចំពោះព្រះតេជព្រះគុណ អស់លោក-អ្នកជាសមាជិក ផ្ញើខ្លួន និង បេក្ខជនទូទៅថា : នៅក្នុងឆមាសទី ១ ឆ្នាំ ១៩៦៩ កន្លងទៅនេះ ក្រុមទំនៀមទម្លាប់បានបើកការប្រឡងប្រជែងខាងទំនៀមទម្លាប់ខ្មែរ ២ មុខគឺ : "អំពីប្រផ្នូលផ្សេងៗ និងអំពីសត្វដែលគេចិញ្ចឹមនៅក្នុងប្រទេសកម្ពុជា" ដើម្បីប្រមូលឯកសារផ្នែកនេះមកតម្កល់ទុក សម្រាប់ធ្វើជា គោលចារិកនៃប្រពៃណីខ្មែរតទៅ ។ តាំងពីបើកសម័យប្រឡងប្រជែងមក មានបេក្ខជនទាំងបព្វជិតទាំងគ្រហស្ថ បានផ្ញើអត្ថបទជាច្រើនមកចូលរួមប្រឡងប្រជែង ។ ក្រុមទំនៀមទម្លាប់ បានពិនិត្យនូវវិញ្ញាសាទាំងនោះយ៉ាងហ្មត់ចត់ហើយបានសម្រេចលទ្ធផល ដូចតទៅនេះ :

### អំពីប្រផ្នូលផ្សេងៗ

ក្នុងចំណោមឯកសារផ្នែកនេះ គ្មានឯកសារណាមួយល្អល្មមឲ្យជាប់

ដល់លេខ ១ បាន ក្រុមជំនុំក៏សម្រេច ជូនត្រឹមតែរង្វាន់លេខ ២ ចុះមក ដូចតទៅនេះ :

- រង្វាន់លេខ ២ : ភិក្ខុ ទុំ-យី គង់នៅវត្តខ្នារ សង្កាត់ព្រៃទឹង ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ត្រូវបានរង្វាន់ ៨០០៛០០

- រង្វាន់លេខ៣ : លោក ចាប-រិត គ្រូបង្រៀននៅសាលាបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ត្រូវបានរង្វាន់ ៦០០៛០០

- រង្វាន់លេខ ៣ : លោក សាំង-ឡុង គ្រូបង្រៀននៅសាលារៀនជ្រៃ សង្កាត់ព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង ត្រូវបានរង្វាន់ . . . . . . ៦០០៛០០

- រង្វាន់លេខ ៤ : លោក ប្រាក់-មៃ ភូមិស្នាច់ដែង សង្កាត់ពាម ស្រុកព្រៃនប់ ខេត្តកំពត ត្រូវបានរង្វាន់ . . . ៤០០៛០០

## អំពីសត្វដែលគេចិញ្ចឹមនៅក្នុងប្រទេសកម្ពុជា

- រង្វាន់លេខ ១ : លោក ចាប-រិត គ្រូបង្រៀននៅសាលាបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ត្រូវបានរង្វាន់ ១.០០០៛០០

- រង្វាន់លេខ ២ : លោក ស៊ូ-សែម នាយត្រួតរងថ្នាក់ទី ១ នៅទីបញ្ជាការផ្នែក ក-រ-គ ស្រុកត្រាំកក់ ខេត្តតាកែវ ត្រូវបានរង្វាន់ . . . . . . . ៨០០៛០០

- រង្វាន់លេខ ៣ : លោក សេក-សេព សង្កាត់តាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ត្រូវបានរង្វាន់ . . . ៦០០រ០០

- រង្វាន់លេខ ៤ : លោក ទិត-សុន្ទ ហៅ សាត សង្កាត់កំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល ត្រូវបានរង្វាន់ ៤០០រ០០

រង្វាន់ទាំងនេះ ក្រុមទំនៀមទម្លាប់ បានចាត់ការផ្ញើទៅជូនសាមីខ្លួន តាមរយៈប្រៃសណីយ៍ និង ទូរគមនាគមន៍រួចហើយ ។

ម្យ៉ាងទៀត នៅក្នុងឆមាសទី ២ ឆ្នាំ ១៩៦៩ នេះ ក្រុមទំនៀមទម្លាប់បានបើកការប្រឡងប្រជែង ២ មុខទៀត គឺ ៖

១- ចម្រៀងប្រជាប្រិយ

២- ទោសនិងការផ្ដន្ទាតាមរបៀបបុរាណ

ឯប្រកាសប្រឡងប្រជែងដែលមានសេចក្ដីពិស្ដារនោះ ក្រុមទំនៀមទម្លាប់បានចាត់ការ ផ្ញើទៅជូនសមាជិកឆ្ងើយឆ្ងង និង បេក្ខជនព្រមទាំងផ្សាយទៅគ្រប់សាលាខេត្ត សាលាស្រុក និងចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយារួចអស់ហើយ ។ យើងសង្ឃឹមថា នឹងមានអស់លោក-អ្នកដែលចេះដឹងរឿងនេះ ផ្ដល់ឯកសារជាច្រើនទៅក្រុមទំនៀមទម្លាប់ជាមិនខាន ។

ក្រុមទំនៀមទម្លាប់ សូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះព្រះតេជព្រះគុណអស់លោកដែលបានយកព្រះទ័យ យកចិត្តទុកដាក់ជួយរក្សាកេរ្តិ៍ដំណែលរបស់ជាតិ ដ៏ថ្លៃថ្លាទាំងឡាយបានគង់វង្សតទៅអនាគត ។

ភ្នំពេញ ថ្ងៃទី ៧ សីហា ១៩៦៩

នាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ

ហត្ថលេខា : លាង-ហ័បអាន